លេខ ១០
ឆ្នាំ២០២១

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

# ព្រឹត្តិបត្រ

## កម្មវិធីកែទម្រង់
## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



# បុព្វកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីកែទម្រង់ស្នូលមួយ ក្នុងចំណោមកម្មវិធីកែទម្រង់ សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានឆ្ពោះទៅពង្រឹងអភិបាលកិច្ចល្អ។ កម្ពុជានឹងកសាងបាននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយរឹងមាំ ដែលឈានទៅសម្រេចបានលទ្ធផលហិរញ្ញវត្ថុចុងក្រោយ (Fiscal Outcomes) ទាំង៣ នៃមុខងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល រួមមាន (១) បូរណភាពនៃការគោរពវិន័យថវិកា, (២) ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ ទាំងក្នុងផ្នែកប្រតិបត្តិការ (៣) ស័ក្តិសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ ។

នៅក្នុងបរិការណ៍ នៃឆ្នាំ២០២០, ពិភពលោកទាំងមូល បានឆ្លងកាត់នូវបទពិសោធន៍ និងស្ថានភាពខុសពីការរំពឹងទុកដោយសារការរាតត្បាត នៃជំងឺកូវីដ-១៩ ហើយព្រះរាជាណាចក្រកម្ពុជា ក៏ពុំត្រូវបានលើកលែងផងដែរ ។  មានសំណួរជាច្រើនត្រូវបានចោទសួរថា តើកិច្ចការកែទម្រង់នានាអាចសម្រេចបានតាមគោលដៅដែលបានគ្រោងទុក ឬយ៉ាងណា? ខ្ញុំអាចសន្និដ្ឋានបានថា វិបត្តិនៃជំងឺកូវីដ-១៩ បានក្លាយជាវិញ្ញាសា ដើម្បីសាកល្បងភាពរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ។ ឆ្លងកាត់ដំណាក់កាលដ៏លំបាកនៃឆ្នាំ ២០២០, ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជានៅរក្សាបានស្ថានភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈការធានាបានចីរភាព នៃការប្រមូលចំណូលជារួមមិនឱ្យធ្លាក់ចុះខ្លាំង និងលទ្ធភាពវិភាជឡើងវិញនូវចំណាយក្នុងឆ្នាំ ឆ្លើយតបបានទៅនឹងកិច្ចការអាទិភាព ដែលកើតមានថ្មីៗ ក៏ដូចជាដោះស្រាយបញ្ហាប្រឈមនានា ក្នុងផ្នែកសេដ្ឋកិច្ច និងសង្គម ។ ជាមួយនឹងស្ថានភាពដែលអាចគ្រប់គ្រងបាន និងលទ្ធផលល្អប្រសើរកន្លងមកនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ បានផ្តល់ជាមូលដ្ឋានចម្បងឱ្យរាជរដ្ឋាភិបាលកម្ពុជាមានលទ្ធភាពក្នុងការដោះស្រាយនូវវិបត្តិផ្នែកសុខាភិបាលជាយថាហេតុជូនប្រទេសជាតិ ក៏ដូចជាការសម្រាលជីវភាពប្រជាពលរដ្ឋក្រីក្រ តាមរយៈការដាក់ចេញនូវវិធានការនានាជាច្រើន ក៏ដូចជាសម្របសម្រួល, បន្ធូរបន្ថយភាពតានតឹង និងលើកស្ទួយស្ថានភាពអាជីវកម្មជាពិសេស សហគ្រាសធុនតូច និងមធ្យម ឱ្យល្អប្រសើរក្នុងអភិក្រមប្រុងប្រយ័ត្នខ្ពស់ ។ ប្រការនេះបានបង្ហាញយ៉ាងច្បាស់លាស់ថា កិច្ចខិតខំប្រឹងប្រែងក្នុងការងារកែទម្រង់បានផ្តល់ផលវិជ្ជមាន ក្នុងការកសាងសមត្ថភាពនៃប្រព័ន្ធហិរញ្ញវត្ថុមួយឱ្យរឹងមាំ ដែលជា “ឧបករណ៍គោលនយោបាយ” បម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច- សង្គមនៅកម្ពុជា ។

ទោះបីជាយ៉ាងនេះក្តី, ប្រសិនបើប្រៀបធៀបទៅនឹងស្តង់ដារ និងឧត្តមានុវត្តជាអន្តរជាតិ, ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា នៅមានគម្លាតនៅឡើយ ហើយទិសដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច- សង្គមកម្ពុជាក៏ស្ថិតនៅលើវិថីវែងឆ្ងាយបន្តទៀត ក្នុងការសម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន ដែលក្នុងនោះកាលានុវត្តភាព និងបញ្ហាប្រឈមនានា នឹងកើតមានឡើងជាបន្តបន្ទាប់ដែលចាំបាច់ទាមទារ ឱ្យបន្តយកចិត្តទុកដាក់កែលម្អ និងពង្រឹងបន្ថែមទៀត លើការងារកែទម្រង់ និងធ្វើអាទិភាវូបនីយកម្មលើសកម្មភាពសំខាន់ថ្មីៗទៀត ដើម្បីឆ្លើយតបជាមួយស្ថានភាពជាក់ស្តែង ព្រមទាំងការតម្រង់ឆ្ពោះទៅរកគណនេយ្យភាពសមិទ្ធកម្ម នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ។

សម្រាប់ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលេខ១០ សម្រាប់ឆ្នាំ២០២១ នេះ នឹងក្លាយជាឧបករណ៍ជំនួយស្មារតី និងផ្តល់តម្លៃបន្ថែមជូនមន្ត្រីរាជការ ជាពិសេសសាធារណជនដើម្បីបន្តលើកកម្ពស់ការយល់ដឹង ព្រមទាំងគាំទ្រដល់ទិសដៅ និងចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា៕

ថ្ងៃពុធ ១៣កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

ក្នុងឆ្នាំ២០២០នេះ សេដ្ឋកិច្ចកម្ពុជាក៏ដូចជាសេដ្ឋកិច្ចពិភពលោកទាំងមូល បាននិងកំពុងទទួលរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលធ្វើឱ្យកំណើនសេដ្ឋកិច្ចធ្លាក់ចុះពុំធ្លាប់មានក្នុងប្រវត្តិសាស្ត្រទំនើបរបស់ខ្លួន ។ ទោះបីជាយ៉ាងណា, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅបន្តដំណើរទៅមុខក្នុងការពុះពារឧបសគ្គដើម្បីធានាបាននូវការសម្រេចគោលដៅចុងក្រោយរបស់កម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ។ ជាក់ស្តែង, ថ្មីៗនេះអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ. គ. ហ.) បានធ្វើការត្រួតពិនិត្យវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ និងវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដោយប្រើប្រាស់ឧបករណ៍វាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure and Financial Accountability-PEFA)។ ផ្អែកលើលទ្ធផលត្រួតពិនិត្យ និងការវាយតម្លៃនេះ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាត្រូវបានកែលម្អជាបណ្តើរៗ ហើយនៅមានការងារសេសសល់មួយចំនួន ដែលត្រូវជំរុញបន្ថែម ទោះបីជាមានវឌ្ឍនភាព និងទិសដៅច្បាស់លាស់ឱ្យស្របតាមបរិការណ៍កម្ពុជា និងសមស្របតាមស្តង់ដា និងឧត្តមានុវត្តអន្តរជាតិ ។

ជាការពិត, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកំពុងស្ថិតនៅលើគន្លងដែលយើងអាចរក្សាបាននូវភាពជាម្ចាស់ទាំងស្រុង ហើយរាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានជ្រើសរើសអភិក្រមប្រតិបត្តិ ដែលមានភាពប្រាកដនិយម និងអាចអនុវត្តបាន ជាពិសេសដែលផ្តល់នូវលទ្ធផលជាក់ស្តែងជាបន្តបន្ទាប់នៅតាមដំណាក់កាលនីមួយៗ។ លើសពីនេះ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទទួលបានការគាំទ្រ និងការចូលរួមអនុវត្តយ៉ាងផុសផុលពីគ្រប់ស្ថាប័ន ព្រមទាំងអង្គភាពនៃរាជរដ្ឋាភិបាល ហើយសមិទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែងទាំងនេះក៏ទទួលបានការសាទរ និងកោតសរសើរពីសាធារណជនទូទៅផងដែរ ។

ដើម្បីបន្តលើកកម្ពស់ការយល់ដឹង និងគាំទ្រដល់ទិសដៅ និងចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា, **អ.គ.ហ.** តែងតែធ្វើការបញ្ជ្រាបការយល់ដឹងថ្មីៗបន្ថែម ក៏ដូចជាផ្សព្វផ្សាយនូវសមិទ្ធផលដែលសម្រេចបានជាបន្តបន្ទាប់ តាមរយៈការបណ្តុះបណ្តាល, សិក្ខាសាលា, ការផ្សព្វផ្សាយ, និងកិច្ចប្រជុំនានា ។ តួយ៉ាង, សម្រាប់ព្រឹត្តិបត្រកម្មវិធីកែ-ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលេខ១០ នេះ នឹងចងក្រងនូវព្រឹត្តិការណ៍ថ្មីៗ, សុន្ទរកថា និងទស្សនមតិរបស់ថ្នាក់ដឹកនាំ ព្រមទាំងអត្ថបទពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានតម្លៃជាច្រើន ដែលអាចផ្តល់តម្លៃបន្ថែមជូនមន្ត្រីរាជការ ជាពិសេសសាធារណជន ដែលចង់ស្វែងយល់អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល៕

ថ្ងៃអង្គារ ១១កើតខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកា

*ព្រឹត្តិបត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ - លេខ១០- ឆ្នាំ២០២១*

## ព្រឹត្តិការណ៍


### ទំព័រទី០១
កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីការត្រួតពិនិត្យវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាសទី៣ ឆ្នាំ២០២០

### ទំព័រទី០៤
សិក្ខាសាលាផ្សព្វផ្សាយសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិការនៃការអនុវត្តចំណូល ពីកម្រៃសេវារបស់អង្គភាពច្រកចេញ-ចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលបាននៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត

### ទំព័រទី១១
ពិធី “ ដាក់ឱ្យដំណើរការសន្ធានកម្មជាផ្លូវការរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ ”

### ទំព័រទី១៣
ការចែករំលែកបទពិសោធស្តីពីការងារកែទម្រង់ហិរញ្ញវត្ថុ-សាធារណៈ ជូនគណៈប្រតិភូមីយ៉ាន់ម៉ា


## អត្ថបទ


### ទំព័រទី១៥
ការអនុវត្តគោលការណ៍ស័ក្តិសិទ្ធភាពនៃកិច្ចសហការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ទំព័រទី១៩
វឌ្ឍនភាពនៃការដាក់ឱ្យអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មគយ

### ទំព័រទី២៣
វិធីសាស្ត្រអនុវត្តការប្រមូលពន្ធលើចំណេញមូលធន

### ទំព័រទី២៦
ដំណើរឆ្ពោះទៅរកការបោះផ្សាយមូលបត្ររដ្ឋនៅកម្ពុជា

### ទំព័រទី២៨
ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការថវិកា

### ទំព័រទី៣០
អភិបាលកិច្ចនៃសាលាបឋមសិក្សាវត្តបូពិ

## ទំព័រទី៣៥

វឌ្ឍនភាពនៃការអនុវត្តគម្រោង FMIS ឆ្នាំ២០២០

# សុន្ទរកថា

## ទំព័រទី៣៨

សុន្ទរកថារបស់ ឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# ទស្សនៈ និងមតិ

## ទំព័រទី៤៣

ប្រសាសន៍ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ តាមប្រព័ន្ធវីដេអូ (Video Conference) នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

## ទំព័រទី៤៣

ប្រសាសន៍ ឯកឧត្តម **ទី តាឃី** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ ថ្លែងក្នុងឱកាសកម្មវិធីដាក់ឱ្យដំណើរការជាផ្លូវការកម្មវិធីសិក្សាគណនេយ្យជំនាញកម្ពុជា នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០

## ទំព័រទី៤៤

ប្រសាសន៍ ឯកឧត្តមបណ្ឌិត **ជុំ គីមឡេង** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងក្នុងពិធីបើកសិក្ខាសាលាស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក នៅខេត្តសៀមរាប

## ទំព័រទី៤៤

មតិរបស់ដៃគូអភិវឌ្ឍន៍លើរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២០





# ផ្នែកទី ១

# ព្រឹត្តិការណ៍

# កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រីមាសទី៣ ឆ្នាំ២០២០

*នាព្រឹក ថ្ងៃចន្ទ ១៥កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ក.ហ.) បានដឹកនាំកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) តាមរយៈប្រព័ន្ធវីដេអូ (Video Conference) នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។*



*កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីការត្រួតពិនិត្យវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ តាមរយៈប្រព័ន្ធវីដេអូ (Video Conference) នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០*

កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំ និងសមាជិកក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត។ កិច្ចប្រជុំបានពិភាក្សាលើរបៀបវារៈចំនួនពីរ, **ទី១.** គឺពិនិត្យលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ និង**ទី២.** គឺពិភាក្សាលើសេចក្តីព្រាងក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៤។

មុននឹងកិច្ចចាប់ផ្តើមពិភាក្សាលើរបៀបវារៈទាំងពីរ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានក្រើនរំលឹកលើការណែនាំ និងវិធានការប្រុងប្រយ័ត្នខ្ពស់ក្នុងការទប់ស្កាត់រួមទាំងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដែលជាកិច្ចការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានធ្វើការអំពាវនាវ និងជំរុញការអនុវត្តតឹងរឹងបំផុតដើម្បីធានាបាននូវសុខសុវត្ថិភាពប្រជាពលរដ្ឋទូទាំងប្រទេស។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានផ្តល់អនុសាសន៍ណែនាំដល់អង្គភាពពាក់ព័ន្ធក្រោមឱវាទ ឱ្យមានការគិតគូររៀបចំថវិកាបម្រុងឱ្យបានគ្រប់គ្រាន់ សម្រាប់រាជរដ្ឋាភិបាលក្នុងការដោះស្រាយសភាពការណ៍បន្ទាន់ចំពោះមុខ ក្នុងស្ថានភាពពេលនេះ។

តាមរយៈរបាយការណ៍វឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅត្រីមាសទី៣នៃឆ្នាំ២០២០បានបង្ហាញថាការអនុវត្តការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ស្ថិតនៅក្នុងស្ថានភាពដែលអាចគ្រប់គ្រងបាន និងនៅតែរក្សាបាននូវលទ្ធផលល្អប្រសើរ បើទោះបីស្ថានភាពបច្ចុប្បន្នកំពុងទទួលរងការគំរាមកំហែងពីការរាតត្បាតនៃជំងឺកូវីដ-១៩ ក៏ដោយ ។ ជាក់ស្តែង, សមិទ្ធផលគន្លឹះៗ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងត្រីមាសទី៣នេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់រួមមានជាអាទិ៍÷




*ប្រភព÷ អ.គ.ហ.*

## ១. វឌ្ឍនភាពតាមផ្នែកនៃ GDAP3

ដំណាក់កាលទី៣នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានរយៈពេលអនុវត្តចាប់ពីឆ្នាំ២០១៦ រហូតដល់ឆ្នាំ២០២០។ ឆ្នាំនេះ គឺជាឆ្នាំចុងក្រោយនៃការត្រូវបញ្ចប់ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ជាក់ស្តែងគិតមកត្រឹមត្រីមាសទី៣ សន្ទុះនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទៅតាមសូចនាករ ដែលបានកំណត់ក្នុងផែនការសកម្មភាពរួម នៅមានល្បឿនល្អប្រសើរ និងអាចគ្រប់គ្រងបាន ដែលក្នុងនោះសម្រាប់ (១) ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា សម្រេចបានក្នុងរង្វង់៩២% (២) ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ សម្រេចបានក្នុងរង្វង់ ៩៧%, (៣) ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ សម្រេចបានក្នុងរង្វង់៨៧%, (៤) ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់សម្រេចបានក្នុងរង្វង់ ៨៨%, និង (៥) ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព សម្រេចបានក្នុងរង្វង់ ៩៤%។ បើធៀបនឹងពីរត្រីមាសកន្លងមក, ការអនុវត្តការងារកែទម្រង់របស់អង្គភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅរក្សាវឌ្ឍនភាពល្អប្រសើរ។




## ២. ការសម្រេចរបស់គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ

គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈហៅកាត់ថា “គ.ក.ហ.” ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញនូវការសម្រេចចំនួន ៣០ ចំណុចនាកិច្ចប្រជុំត្រីមាសទី២ កន្លងទៅ។ ចំណុចទាំង៣០ នោះ រួមមាន÷

❖ **ច្បាប់ចំនួន៦** ក្នុងនោះមានច្បាប់ចំនួន ២ បានបញ្ចប់ពេញលេញដោយទទួលបានការអនុម័តដោយសភា ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ គឺ (១) ច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម និង (២) ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ។ ដោយឡែកច្បាប់ចំនួន១ គឺសេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ បានអនុម័តដោយគណៈរដ្ឋមន្ត្រីនាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២០ និងបានបញ្ជូនទៅសភាដើម្បីពិនិត្យ និងអនុម័ត។ រីឯច្បាប់ចំនួន៣ ទៀតកំពុងស្ថិតក្នុងការបន្តរៀបចំ ក្នុងកម្រិតជំនាញ រួមមាន (១) សេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន, (២) សេចក្តីព្រាងច្បាប់ស្តីពីច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) និង(៣) សេចក្តីព្រាងស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

❖ **ឯកសារយុទ្ធសាស្ត្រចំនួន៤** ដែលកំពុងបន្តការរៀបចំ និងប្រមូលធាតុចូលរួមមាន÷ (១) សេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ “គណនេយ្យភាពសមិទ្ធកម្ម”, (២) សេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដារគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានបង្គរឆ្នាំ២០១៩-២០៣១, (៣) សេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់

*ដោយសារវិបត្តិជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានធ្វើវិចារកម្មថវិកាចំនួន២ លើក លទ្ធផលការអនុវត្តថវិកាបានសម្រេច៥៦% ធៀបនឹងច្បាប់ ប៉ុន្តែវឌ្ឍនភាពនេះ មិនមានភាពខុសគ្នាពីការអនុវត្តក្នុងពេលវេលាដដែលនាឆ្នាំ២០១៩ កន្លងទៅ ដែលជាការឆ្លុះបញ្ចាំងអំពីវិន័យ នៃការអនុវត្តថវិកានៅរក្សាបាន។*

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ដំណាក់កាលទី៤), និង (៤) សេចក្តីព្រាងចក្ខុវិស័យ និងយុទ្ធសាស្ត្រការងារកែទម្រង់៣ បូក ១ រយៈពេល ១០ ឆ្នាំ។

❖ **ក្របខណ្ឌចំនួន៣** គឺ(១) សេចក្តីព្រាងក្របខណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី៤ ឆ្នាំ២០២១-២០២២ (CAP4 Framework) បានរៀបចំ និងពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍រួចរាល់ព្រមទាំងត្រៀមឆ្លងក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាសទី៣ ។ ដោយឡែកក្របខណ្ឌ២ ផ្សេងទៀតគឺ (១) សេចក្តីព្រាងក្របខណ្ឌនិងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច, និង(២) សេចក្តីព្រាងក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ នៅមិនទាន់មានសេចក្តីព្រាងនៅឡើយ ដោយសារក្រុមការងារកំពុងរៀបចំក្រុមការងារ និងប្រមូលធាតុចូល។

❖ **គោលការណ៍ណែនាំ**រួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបន្តរៀបចំជាមួយនឹងសេចក្តីព្រាងលើកទី២ ដោយប្រើប្រាស់ជំនាញការក្នុងស្រុក និងគ្រោងសិក្ខាសាលាពិគ្រោះយោបល់ ជាមួយអង្គភាពពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននាខែវិច្ឆិកា ឆ្នាំ២០២០។

❖ ផែនការពង្រីកការអនុវត្តគម្រោង FMIS ជំហានទី៣ សេចក្តីព្រាង BluePrint 3

ទទួលបានការអនុម័តដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តម-អគ្គបណ្ឌិតសភាចារ្យ និងគ្រោងប្រកាសបើកការអនុវត្តគម្រោង FMIS ជំហានទី៣ នេះ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០។

❖ ការធ្វើសន្ទានកម្មប្រព័ន្ធចំនួន៣ រួមមាន (១) រវាងប្រព័ន្ធ FMIS ជាមួយនឹងប្រព័ន្ធ EFMIS របស់ក្រសួងអប់រំ យុវជន និងកីឡា, (២) រវាងប្រព័ន្ធ FMIS ជាមួយនឹងប្រព័ន្ធបៀវត្សរបស់ក្រសួងមុខងារសាធារណៈ, និង (៣) រវាងប្រព័ន្ធពន្ធដារ ជាមួយនឹង ASYCUDA មានវឌ្ឍនភាពតាមផែនការ។

❖ ចំណុច១៣ ផ្សេងទៀត ដែលពាក់ព័ន្ធនឹងការពង្រឹងការអនុវត្តទាំងប្រព័ន្ធ និងការវាយតម្លៃ មានវឌ្ឍនភាពល្អប្រសើរ។

## ៣. វឌ្ឍនភាពលើការងារកែទម្រង់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### ផ្នែកទី១. ភាពជឿទុកចិត្តនៃថវិកា

❖ ទិដ្ឋភាពចំណូល

ការប្រមូលចំណូលរដ្ឋសរុបសម្រេចបាន ៦៣% ធៀបនឹងច្បាប់។ ប្រសិនបើពិនិត្យ



ប្រភព: GDNT (as of 30 Sep 2020)

លើការវាយតម្លៃ នៃការអនុវត្តថវិកាពាក់កណ្ដាលឆ្នាំ ការប្រមូលចំណូលត្រូវបានប៉ាន់ប្រមាណ៧៩% ធៀបនឹងច្បាប់។ ក្នុងរយៈពេល ១ត្រីមាសចុងក្រោយការប្រមូលចំណូលរដ្ឋអាចនឹងសម្រេចបានតាមការប៉ាន់ស្មានជាវិជ្ជមាន។

ការប្រមូលចំណូលជារួមសម្រេចបានក្នុងរង្វង់ ៦៣% គឺមានការធ្លាក់ចុះដោយសារវិបត្តិនៃជំងឺកូវីដ-១៩ ៖

- ចំណូលសារពើពន្ធ៖ សម្រេចបាន៦៥% ធៀបនឹងច្បាប់។
- ចំណូលមិនមែនសារពើពន្ធ៖ សម្រេចបាន៤៨% ធៀបនឹងច្បាប់ ។




*ប្រភព៖ អគ្គនាយកដ្ឋានរតនាគារជាតិ (គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០)*

ជាការកត់សម្គាល់, ចាប់តាំងពីរាជរដ្ឋាភិបាលប្រកាស ឱ្យរឹតបន្តឹងការទប់ស្កាត់ជំងឺកូវីដ-១៩នៅចុងត្រីមាសទី១ ឆ្នាំ២០២០ មក អាជីវកម្មមួយចំនួនធំជាពិសេសក្នុងវិស័យអប់រំ ទេសចរណ៍ ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ និងសកម្មភាពអាហារ៍ណ- នីហារ៍ណ មានសន្ទុះយឺត ឬឈប់សម្រាក ឬផ្អាកទាំងស្រុង ដែលនិន្នាការប្រមូលចំណូលក៏ចាប់ផ្តើមថយចុះជាបណ្តើរៗផងដែរ។

❖ ទិដ្ឋភាពចំណាយ

ដោយសារវិបត្តិជំងឺកូវីដ-១៩, រាជរដ្ឋាភិបាលបានធ្វើវិចារណកម្មថវិកាចំនួន ២ លើក ជាលទ្ធផលការអនុវត្តថវិកាបានសម្រេច៥៦% ធៀបនឹងច្បាប់ ប៉ុន្តែវឌ្ឍនភាពនេះ មិនមានភាពខុសគ្នាពីការអនុវត្តក្នុងពេលវេលាដដែលនាឆ្នាំ២០១៩ កន្លងទៅ ដែលជាការឆ្លុះបញ្ចាំងអំពីវិន័យ នៃការអនុវត្តថវិកានៅរក្សាបាន។ បើពិនិត្យទៅលើការព្យាករណ៍ក្នុងរបាយការណ៍វាយតម្លៃការអនុវត្តថវិកាពាក់កណ្ដាលឆ្នាំ ចំណាយអាចសម្រេចបានក្នុងរង្វង់៨៨%។ ប្រសិនបើវិន័យនៃការអនុវត្តថវិកានៅបន្តរក្សាបាន នោះការអនុវត្តជាក់ស្តែងអាចឈានទៅសម្រេចបានតាមការគ្រោងនេះ។

**ការប្រមូលចំណូលចរន្តរយៈពេល៩ខែ ឆ្នាំ២០២០ (គិតជាលានរៀល)**




*ប្រភព៖ អគ្គនាយកដ្ឋានរតនាគា...*

### ផ្នែកទី២. គណនេយ្យភាពហិរញ្ញវត្ថុ

● E-Transfer ៖ សម្រេចបានក្នុងរង្វង់ ៧០% ដោយបានរៀបចំឯកសារលក្ខខណ្ឌតម្រូវការបច្ចេកទេស និងអភិវឌ្ឍផ្នែកបច្ចេកទេសរួចរាល់ជាបឋម សម្រាប់ការធ្វើតេស្តសាកល្បង លើតំណភ្ជាប់រវាងប្រព័ន្ធ FMIS និង ប្រព័ន្ធរបស់ធនាគារកាណាឌីយ៉ា។




● **តារាងឧបសម្ព័ន្ធចំណូល-ចំណាយសម្រាប់រៀបចំ ច្បាប់ទូទាត់ ឆ្នាំ២០១៩ត្រូវបានផលិតសាកល្បងចេញពីប្រព័ន្ធ FMIS ÷** សម្រេចបានពេញលេញ ដោយរបាយការណ៍ និងតារាងឧបសម្ព័ន្ធចំណូល-ចំណាយថវិកាសម្រាប់ច្បាប់ទូទាត់ត្រូវបានធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍកែសម្រួលបន្ថែមរួចរាល់ និងបានដាក់ឱ្យប្រើប្រាស់នៅក្នុងប្រព័ន្ធ FMIS ។




● **ការតម្រង់ទិស និងកែលម្អនីតិវិធីអនុវត្តការងារបច្ចុប្បន្ន÷** សម្រេចបានក្នុងរង្វង់ ៩០%។ កិច្ចការនេះ ផ្តោតលើមុខសញ្ញាចំណាយការបើកផ្តល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិក ដែលមានគោលរបបច្បាស់លាស់បានដាក់ ឱ្យដំណើរការជាផ្លូវការ នៅ កសហវ និងក្រសួង-ស្ថាប័នចំនួន៧ ។ មុខសញ្ញាលើការទូទាត់ត្រង់ក្រោមបន្ទុកបុគ្គលិក ដែលមានវេទយិតភាពទាបបានដាក់ឱ្យអនុវត្តជាផ្លូវការនៅកសហវ និងកំពុងបន្តសិក្សារៀបចំសម្រាប់ក្រសួង-ស្ថាប័នចំនួន៧ ដែលបានជ្រើសរើស រួមមាន **១.** ក្រសួងអប់រំ យុវជន និងកីឡា, **២.** ក្រសួងសុខាភិបាល, **៣.** ក្រសួងមុខងារសាធារណៈ, **៤.** ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ, **៥.** ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេក-វិទ្យា និងនវានុវត្តន៍, **៦.** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, **៧.** ក្រសួងប្រៃស-ណីយ៍ និងទូរគមនាគមន៍។

● **មុខងាររៀបចំផែនការថវិកា និងលទ្ធកម្ម÷** អង្គភាពជំនាញ កំពុងបន្តរៀបចំ "មុខងាររៀបចំផែនការថវិកា" ក្នុងជំហានទី ១a រីឯ "មុខងារលទ្ធកម្ម" ក្រុមការងារបានធ្វើតេស្តសាកល្បងលើផ្នែកគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ ដោយឡែកផ្នែកផែនការលទ្ធកម្មនៅបន្តកែសម្រួល។

● **ចំណាត់ថ្នាក់មុខងារ និងចំណាត់ថ្នាក់ភូមិសាស្ត្រ÷** សម្រេចបានក្នុងរង្វង់៨០% ដោយបានបញ្ចប់ការរៀបចំឯកសារ ទស្ស-នាទាន សម្រាប់ផ្សារភ្ជាប់ពីចំណាត់ថ្នាក់កម្មវិធីជាមួយចំណាត់ថ្នាក់មុខងារ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ឱ្យអនុវត្តប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់ភូមិសាស្ត្រ នៃមាតិកាថវិកា។ អង្គភាពជំនាញ នៅកំពុងបន្តសិក្សាអំពីការអនុវត្តចំណាត់ថ្នាក់មុខងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

● **របាយការណ៍តាមចំណាត់ថ្នាក់ថវិកាទាំង ៧ តាមប្រព័ន្ធ FMIS ÷** សម្រេចបានក្នុងរង្វង់៩០% ដោយបានដាក់ឆ្លងរបាយការណ៍ស្ថិតិចំណាយតាមចំណាត់ថ្នាក់ទាំង៧ ជូនថ្នាក់ដឹកនាំ ដើម្បីពិនិត្យ និងបន្តពិនិត្យ ហើយកែលម្អនូវកំហុសឆ្គងក្នុងការកត់ត្រាចំណាត់ថ្នាក់នៃមាតិកាថវិកាទាំង៧ ក្នុងប្រព័ន្ធ FMIS ចំពោះក្រសួង-ស្ថាប័ន ទាំង ៣៧ ដែលបានអនុវត្តប្រព័ន្ធ FMIS។

● **ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (SARMIS)** សម្រេចបានក្នុងរង្វង់៤០% ដោយសារតែប្រព័ន្ធនេះមិនទាន់ដាក់ឱ្យអនុវត្តជាផ្លូវការនៅឡើយទេ ពីព្រោះនៅមានចំណុចកែសម្រួលបន្ថែមច្រើន។ គិតមកត្រឹមពេលនេះ មាន ១០ ក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត ដែលបានដាក់ឱ្យប្រើប្រាស់សាកល្បងលើប្រព័ន្ធ SARMIS នៅមានបញ្ហាប្រឈមនៅឡើយ ដោយសារតែត្រូវបានអនុវត្តក្នុងស្ថានភាព Offline គឺត្រឹមបញ្ចូលព័ត៌មាន ជាទម្រង់ EXCEL សិន ។

● **សន្ទានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ÷** សម្រេចបានពេញលេញ ដោយបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ កន្លងទៅ។

## ផ្នែកទី៣. ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

សម្រាប់ផ្នែកនេះ ក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF), ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF), ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ គឺត្រូវបានបន្តតាមដានជាអាទិភាពតាមរយៈយន្តការនៃរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសនីមួយៗ។

● **ក្របខ័ណ្ឌ MTBF ÷** សម្រេចបានពេញ-លេញ ១០០ភាគរយ ដោយបានរៀបចំនូវទស្សនាទានស្តីពីក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ២០២០-២០២២ និងបានដាក់ឱ្យអនុវត្តសាកល្បងសម្រាប់រដ្ឋបាល

ថ្នាក់ជាតិ ដោយមានកំណត់ពិដានសម្រាប់រៀបចំថវិកាប្រចាំឆ្នាំ។

● **ក្របខ័ណ្ឌ MTFF ÷** អង្គភាពជំនាញ បានរៀបចំត្រឹមកម្រិតបច្ចេកទេស។ ដោយសារវិបត្តិជំងឺ Covid-19 ថ្នាក់ដឹកនាំ កសហវ. បានសម្រេចពន្យារពេលក្នុងការដាក់ឱ្យអនុវត្តMTFF និងជំនួសវិញដោយក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ឆ្នាំ២០២១ ស្របតាមចំណារ ដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០។

● **ការធ្វើសមាហរណកម្មថវិកាចរន្ត និងមូលធន÷** សម្រេចបានពេញលេញ ដោយបានធ្វើសមាហរណកម្មថវិកាចរន្ត និងវិនិយោគតាមកម្មវិធី នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣។

● **ការពង្រីកការអនុវត្តថវិកាកម្មវិធី ÷** សម្រេចបានពេញលេញ ដោយបានរៀបចំគោលការណ៍ណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការួមនៃរាជធានី-ខេត្ត ត្រូវបានរៀបចំរួច និងដាក់ឱ្យអនុវត្ត។ លើសពីនេះ, មន្ត្រីរដ្ឋបាលរាជធានីខេត្តចំនួន ១២៥រូប ក៏បានទទួលការបណ្តុះបណ្តាលលើកទី២ ផងដែរ។

● **បង្កើនការផ្ទេរធនធានពីថវិកាជាតិជូនមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់÷** សម្រេចបានក្នុងរង្វង់៨០% ដោយសារសេចក្តីព្រាងអនុក្រឹត្យស្តីពីមូលនិធិឃុំ សង្កាត់ បានដាក់ប្រជុំពិភាក្សាជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងកំពុងរៀបចំកែសម្រួល នៅឡើយ។

## ផ្នែកទី៤. គណនេយ្យភាពសមិទ្ធកម្ម

ផ្នែកទី៤នេះ គឺមានសារៈសំខាន់ក្នុងការចូលរួមកសាងបង្កើននូវមូលដ្ឋានគ្រឹះសម្រាប់បោះជំហានទៅដំណាក់កាលបន្ទាប់។

● **ការរៀបចំច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី÷** សម្រេចបានក្នុងរង្វង់៤០% ដោយក្រុមការងារជំនាញបានបន្តពិនិត្យ និងកែសម្រួលទៅតាមជំពូកនីមួយៗ ដែលសរុបមានចំនួន៩ ជំពូក។

● **ការដាក់ឱ្យអនុម័តអនុក្រឹត្យ៨១÷** សម្រេចបានក្នុងរង្វង់៤០% ដោយត្រឹមរៀបចំបាននូវសេចក្តីព្រាងបឋម និងបានពិភាក្សាក្នុងកម្រិតនាយកដ្ឋាន ព្រមទាំងបានដាក់ជូនជំនាញការបារាំងដើម្បីផ្តល់យោបល់។

● **រៀបចំសេចក្តីព្រាងអនុក្រឹត្យ៨២÷** សម្រេចបានពេញលេញ ដោយក្រុមជំនាញបានរៀបចំនូវសេចក្តីព្រាង និងបានប្រជុំពិគ្រោះយោបល់ ប្រមូលធាតុចូលបន្ថែមលើការរៀបចំសេចក្តីព្រាងបឋមនៃអនុក្រឹត្យថ្មីស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ។

● **ទម្រង់បឋមចំណាត់ថ្នាក់សេដ្ឋកិច្ចបំពេញ÷** សម្រេចបានក្នុងរង្វង់៩០%។

● **ទម្រង់ព័ត៌មានសមិទ្ធកម្មប្រចាំឆ្នាំ និងទម្រង់របាយការណ៍ព័ត៌មានសមិទ្ធកម្មនៃការអនុវត្តថវិកាប្រចាំឆ្នាំ÷** សម្រេចបានពេញលេញ ដោយអង្គភាពជំនាញបានបញ្ចប់ការរៀបចំ និងដាក់ឱ្យអនុវត្ត។

● **សេចក្តីព្រាងក្របខ័ណ្ឌទស្សនាទាន នៃការតាមដាន និងត្រួតពិនិត្យព័ត៌មានសមិទ្ធកម្ម÷** សម្រេចបានពេញលេញ ដោយបានរៀបចំឯកសារទស្សនាទាននៃសេចក្តីព្រាង



*កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្តីពីការត្រួតពិនិត្យវឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ តាមរយៈប្រព័ន្ធវីដេអូ (Video Conference) នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០*

ក្របខ័ណ្ឌតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម។ លើសពីនេះ ក្រុមការងារក៏កំពុងរៀបចំជាសេចក្តីព្រាងបឋម នៃក្របខ័ណ្ឌតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម។

- **ក្របខ័ណ្ឌសវនកម្មពេញលេញ និងក្របខ័ណ្ឌអធិការកិច្ចហិរញ្ញវត្ថុ÷** សម្រេចបានក្នុងរង្វង់៩០% ។ គោលការណ៍ណែនាំស្តីពីការធ្វើសវនកម្មលើសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន បានប្រកាសដាក់ឱ្យអនុវត្ត រីឯអនុក្រឹត្យស្តីពីក្របខ័ណ្ឌមុខងារភារកិច្ចរបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ចក៏ទទួលបានការអនុម័តផងដែរ។ ប៉ុន្តែ ក្រុមការងារនៅបន្តរៀបចំសេចក្តីព្រាងបឋមផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុ ២០២១-២០២៥ នៅឡើយ។

## ផ្នែកទី៥. ការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយចីរភាព

ការយកចិត្តទុកដាក់ក្នុងការបន្តបង្កើនគុណភាពធនធានមនុស្ស និងបង្កើនឆន្ទៈព្រមទាំងភាពជាអ្នកដឹកនាំគឺជាធាតុដ៏សំខាន់សម្រាប់ការគាំទ្រនូវផ្នែកនេះ។ គិតត្រឹម ត្រីមាសទី៣ នេះ អង្គភាពក្រោមឱវាទ កសហវ. បានបន្តយកចិត្តទុកដាក់ក្នុងការផ្តល់នូវវគ្គបណ្តុះបណ្តាលតាមជំនាញជាក់លាក់ទាំងលើទិដ្ឋភាពចំណូល ការប្រើប្រាស់ប្រព័ន្ធ និងជំនាញហិរញ្ញវត្ថុសាធារណៈផងដែរ។

ក្នុងត្រីមាសទី៣នេះ, អង្គភាពមួយចំនួនមានសកម្មភាពដែលត្រូវអនុវត្ត ប៉ុន្តែមិនអាចអនុវត្តបានដោយសារវិបត្តិកូវីដ-១៩។ សកម្មភាពទាំងនោះ ត្រូវបានសម្រេចមិនរាប់បញ្ចូលក្នុងការវាយតម្លៃសមិទ្ធកម្ម និងការផ្តល់ប្រាក់បៀវត្សនោះឡើយ ។ ជារួម សកម្មភាពសរុបរបស់អង្គភាព កសហវ. ក្នុងត្រីមាសទី៣ មានសរុប៣០៣ ក្នុងនោះមានចំនួន៣២ សកម្មភាពមិនរងការវាយតម្លៃនោះទេ ហើយសកម្មភាពចំនួន២១៨ សម្រេចបាន១០០% ។ បន្ថែមពីនេះក្នុងចំណោមអង្គភាពទាំង១៨ ដែលអនុវត្តផែនការសកម្មភាពកែទម្រង់ គឺមានតែអង្គភាពភាពជាដៃគូរដ្ឋនិងឯកជន (PPP) សម្រេចបានក្រោម៥០% ។ ជារួម ក្នុងក្របខ័ណ្ឌអង្គភាពជំនាញ ដែលបានអនុវត្ត GDAP មានវឌ្ឍនភាពការងារកែទម្រង់ល្អប្រសើរដោយសម្រេចបានជាមធ្យមក្នុងកម្រិត៩០% ព្រមទាំងខិតខំរៀបចំ និងបានផ្តល់របាយការណ៍វឌ្ឍនភាពបានទាន់ពេលវេលាផងដែរ។

*ថ្នាក់ដឹកនាំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានណែនាំ និងតម្រង់ទិសឱ្យគិតគូរក្នុងការបង្កើនរយៈពេល ២ ឆ្នាំបន្ថែមទៀត ដើម្បីកសាងមូលដ្ឋានគ្រឹះដំណាក់កាលទី៣ និងការងារគន្លឹះៗ ដែលនៅសេសសល់ផ្សេងៗទៀត ដើម្បីធានា ឱ្យបានចីរភាព នៃការងារកែទម្រង់ និងការដើរស្របគ្នាជាមួយនឹងកិច្ចការងារកែទម្រង់ផ្សេងៗទៀតមុននឹងឈានបោះជំហានទៅដំណាក់កាលបន្ទាប់*

ក្នុងក្របខ័ណ្ឌស្ថាប័ន, កសហវ. បានសម្រេចនូវការរៀបចំលិខិតគតិយុត្តិជាច្រើន ក្នុងនោះមានច្បាប់ចំនួន២ ត្រូវបានអនុម័តដោយសភា, ច្បាប់ចំនួន១ បានបញ្ចប់ការរៀបចំ និងដាក់ឆ្លងសភាអនុម័ត, ច្បាប់ចំនួន៣ ទៀត កំពុងដាក់ត្រៀមបញ្ចប់ និងអនុម័ត, ឯកសារយុទ្ធសាស្ត្រចំនួន៤ កំពុងរៀបចំបញ្ចប់, ក្របខ័ណ្ឌយុទ្ធសាស្ត្រចំនួន៣ កំពុងរៀបចំបញ្ចប់, គោលការណ៍ណែនាំ និងការធ្វើសន្ទានកម្មត្រូវបានបន្តរៀបចំ និងពង្រឹង ។ល។ ជាការកត់សម្គាល់, កសហវ. បានបន្តយកចិត្តទុកដាក់ក្នុងការអនុវត្តថវិកាកម្មវិធី ដែលជាស្នូលក្នុងដំណាក់កាលទី៣ នេះ ដោយអនុវត្តនូវយន្តការតាមដានជា



ប្រចាំតាមរយៈកិច្ចប្រជុំតាមដានការអនុវត្តថវិកាកម្មវិធីពាក់កណ្ដាលឆ្នាំ ។ម៉្យាងវិញទៀត ការចូលរួមតាមដានការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តែងតែត្រូវបានអនុវត្តជាប្រចាំត្រីមាស ។ យន្តការលើកទឹកចិត្ត គឺជាការយកចិត្តទុកដាក់ខ្ពស់របស់ថ្នាក់ដឹកនាំក្រសួងផងដែរ។

## ៤.វឌ្ឍនភាពការអនុវត្តការងារកែទម្រង់របស់ក្រសួង-ស្ថាប័ន

សម្រាប់ត្រីមាសទី៣នេះ, ក្រសួង-ស្ថាប័នចំនួន០៨ ដែលសម្រេចបានទាបជាង៨៦% ដែលរួមមាន÷ (១)រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល (៨៤%), (២)ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(៨៥%), (៣)ក្រសួងសាធារណៈការ និងដឹកជញ្ជូន (៨១%), (៤)ក្រសួងអប់រំ យុវជន និងកីឡា (៧៥%), (៥)ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (៨០%),(៦) អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (៨១%), (៧)អគ្គលេខាធិការដ្ឋានរដ្ឋសភា(៥០%), (៨)ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម (៦០%)។

ទោះជាយ៉ាងណាក៏ដោយ បើពិនិត្យលើសមិទ្ធផលផ្សេងទៀត ក្រសួង-ស្ថាប័នភាគច្រើននៅតែបន្តការចូលរួមលើការងារកែទម្រង់ និងបន្តមានវឌ្ឍនភាពប្រសើរ ក្នុងនោះការបន្តរៀបចំយន្តការក្នុងការពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធ, ការរៀបចំនិងអនុវត្តថវិកា រួមទាំងការចូលរួមតាមដានលើការអនុវត្តការងារកែទម្រង់តាមរបបប្រជុំជាទៀងទាត់ ។

**●ទិដ្ឋភាពប្រមូលចំណូលមិនមែនសារពើពន្ធរយៈពេល៩ ខែ (គិតជាលានរៀល)÷**

- ការអនុវត្តចំណូលមិនមែនសារពើពន្ធគិតត្រឹមត្រីមាសទី៣សម្រេចបានប្រមាណ **៤៨%** (ប្រមាណ១ ៤៤៧ប៊ីលានរៀល)
- ការកត់ត្រាក្នុងប្រព័ន្ធ NRMIS គឺត្រូវបានអនុវត្តគ្រប់**២៣** ក្រសួង-ស្ថាប័ន ។

**●ទិដ្ឋភាពប្រមូលចំណាយ÷**

ការអនុវត្តចំណាយក្រសួង-ស្ថាប័នគិតត្រឹមត្រីមាសទី៣។ ជារួមសម្រេចបាន ៦៥,៥៥% ធៀបនឹងច្បាប់ប្រចាំឆ្នាំ។

**●នីតិវិធីតម្រង់ទិសការអនុវត្តការងារតាមប្រព័ន្ធ FMIS÷**

ក្រសួង-ស្ថាប័នចំនួន៧ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនូវស្វ័យប្រវត្តិកម្មតាមប្រព័ន្ធ FMIS លើការបើកផ្ដល់បៀវត្ស និងចំណាយលើបន្ទុកបុគ្គលិកផ្សេងៗដែលមានគោលរបបកំណត់ច្បាស់លាស់ជាផ្លូវការនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ និងកំពុងបន្តនីតិវិធីសម្រាប់ដាក់ឱ្យអនុវត្តនីតិវិធីថ្មីសម្រាប់ការចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប។

**●ឆន្ទៈនិងភាពជាអ្នកដឹកនាំ÷**

- គ្រប់ក្រសួងស្ថាប័ន (លើកលែងតែក្រសួងផែនការ) បានបន្តចូលរួមសហការក្នុងការងារកែទម្រង់តាមរយៈការខិតខំក្នុងការផ្ដល់នូវរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស
- ក្នុងចំណោមក្រសួងស្ថាប័នអនុវត្តកម្មវិធីកែទម្រង់ទាំង៣៩ មានក្រសួង-ស្ថាប័នចំនួន២៤ ដែលបានគិតគូររៀបចំតាមដានការអនុវត្តថវិកាកម្មវិធីពាក់កណ្ដាលឆ្នាំ។

ដោយឡែក ការពិភាក្សាអំពីការរៀបចំសេចក្ដីព្រាងក្របខ័ណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី៤ ជាការងារចាំបាច់សម្រាប់ការត្រៀមខ្លួនអនុវត្តការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈនៅក្នុងជំហានបន្ទាប់។ ក្របខ័ណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី៤ មានលក្ខណៈទូលំទូលាយដោយផ្ដោតការគ្រប់គ្រងធនធានមនុស្ស និងរចនាសម្ព័ន្ធចាត់តាំង ព្រមទាំងការបញ្ចប់ការងាររៀបចំមូលដ្ឋានជាសារវន្តនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរយៈពេលជាង ២០ឆ្នាំនេះក្នុងគោលដៅឆ្ពោះទៅរកការកែទម្រង់ “ការអនុវត្តការងារប្រចាំថ្ងៃ” ឬ “លទ្ធផលចុងក្រោយ”។

ថ្នាក់ដឹកនាំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានណែនាំ និងតម្រង់ទិសឱ្យគិតគូរក្នុងការបង្កើនរយៈពេល ២ឆ្នាំបន្ថែមទៀតដើម្បីកសាងមូលដ្ឋានគ្រឹះដំណាក់កាលទី៣ និងការងារគន្លឹះៗ ដែលនៅសេសសល់ផ្សេងៗទៀត ដើម្បីធានាឱ្យមានចីរភាពនៃការងារកែទម្រង់ ព្រមទាំងការដើរស្របគ្នាជាមួយនឹងកិច្ចការងារកែទម្រង់ផ្សេងៗទៀតមុននឹងបោះជំហានទៅដំណាក់កាលបន្ទាប់។ **ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានរំលឹកបន្ថែមថាក្នុងកាលៈទេសៈនេះ គឺបង្កឱ្យគ្រប់អង្គភាពក្រសួង-ស្ថាប័នសម្របខ្លួនទៅនឹងវិបត្តិ និងប្រើប្រាស់នូវគំនិតច្នៃប្រឌិតខ្ពស់ក្នុងការដោះស្រាយបញ្ហាប្រឈមដែលកើតមានជាមួយនឹងការប្រុងប្រយ័ត្នខ្ពស់បំផុត។

ជាចុងបញ្ចប់ **ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងកន្លងមករបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគ្រប់អង្គភាពនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រហូតសម្រេចបានសមិទ្ធផលនៅត្រីមាសទី៣ នេះ ទោះបីកម្ពុជាកំពុងស្ថិតក្នុងវិបត្តិកូវីដ-១៩ ក៏ដោយ ។ **ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានស្នើគ្រប់អង្គភាពក្រោមឱវាទក្រសួង បន្តជំរុញការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ ដើម្បីសម្រេចតាមគោលដៅ ដែលបានគ្រោងទុក៕■

*រៀបចំដោយ÷ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.*

# សិក្ខាសាលាផ្សព្វផ្សាយសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូល ពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត

*នៅថ្ងៃពុធ ៨កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១៤:៣០ នាទីរសៀល នៅសណ្ឋាគារភ្នំពេញ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) សហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ រៀបចំសិក្ខាសាលាផ្សព្វផ្សាយសារាចរលេខ ០០៦ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូល ពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ។*

សិក្ខាសាលាផ្សព្វផ្សាយនេះ ដឹកនាំដោយឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គ-លេខាធិការ នៃ អ.គ.ហ. តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច-និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) ដោយមានការចូលរួមផ្ទាល់នៅសណ្ឋាគារភ្នំពេញ ពីរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តព្រៃវែង ព្រមទាំងតាមរយៈប្រព័ន្ធវិឌីអូ (video conference) សម្រាប់រដ្ឋបាលខេត្តចំនួន ២៣ ផ្សេងទៀតរួមជាមួយនឹងអង្គភាព និងមន្ទីរជំនាញពាក់ព័ន្ធ ដោយមានការសម្របសម្រួលពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត។

គោលបំណងនៃការរៀបចំសិក្ខាសាលាផ្សព្វផ្សាយនេះឡើង គឺដើម្បីធានាប្រសិទ្ធភាព




*សិក្ខាសាលាផ្សព្វផ្សាយសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូល ពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត តាមរយៈប្រព័ន្ធវិដីអូ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០*

នៃការអនុវត្តអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រក-ចេញចូលតែមួយរាជធានី ខេត្ត និងជាពិសេសដើម្បីដោះស្រាយបញ្ហាដែលកំពុងប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការបែងចែកប្រាក់រង្វាន់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ក្នុងកម្មវិធីបើកសិក្ខាសាលាផ្សព្វផ្សាយ, ឯកឧត្តម **រស់ សីលវ៉ា** បានលើកឡើងអំពីសារៈតារ នៃការរៀបចំសិក្ខាសាលានេះ ដោយកាលពីអំឡុងត្រីមាសទី១ ឆ្នាំ២០២០ ក្រុមការងារ **អ.គ.ហ.** បានចុះប្រមូលព័ត៌មាន នៅឯរដ្ឋបាលរាជធានីភ្នំពេញ

រដ្ឋបាលខេត្តកណ្តាល និងរដ្ឋបាលខេត្ត-ព្រៃវែង ព្រមទាំងមានការចូលរួមពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, រតនាគាររាជធានី-ខេត្ត, និងមន្ទីរជំនាញប្រមូលចំណូលជុំវិញរដ្ឋបាលរាជធានី-ខេត្ត ក្នុងគោលបំណងផ្តល់នូវធាតុចូលបន្ថែមសម្រាប់ រៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០១៩ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ។ ក្នុងអំឡុងពេលចុះប្រមូលព័ត៌មាន, ក្រុមការងារ អ.គ.ហ. បានរកឃើញបញ្ហាប្រឈមពាក់-ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារ-ពើពន្ធ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបញ្ហាប្រឈមនេះ ទាមទារឱ្យមានការចាត់វិធានការដោះស្រាយជាបន្ទាន់ ។


ឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ. និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត តាមរយៈប្រព័ន្ធវិដីអូ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០

ក្នុងស្មារតីនេះ, ដោយប្រតិបត្តិតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** និងការណែនាំផ្ទាល់របស់ឯកឧត្តម **រស់ សីលវ៉ា**, ឯកឧត្តម **យ៉េត វីណែល** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃ អ.គ.ហ. បានដឹកនាំកិច្ចប្រជុំកម្រិតបច្ចេកទេសចំនួន ៥ លើក ជាមួយអង្គភាពពាក់ព័ន្ធ ក្នុងគោលបំណងជំរុញការរៀបចំសេចក្តីព្រាងសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី-ខេត្ត ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអនុវត្តអនុក្រឹត្យ លេខ២៥ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត។ ជាលទ្ធផលសារាចរខាងលើនេះ ទទួលបានការអនុម័តដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយក-រដ្ឋមន្ត្រី** នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០។


សិក្ខាសាលាផ្សព្វផ្សាយសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូល ពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត តាមរយៈប្រព័ន្ធវិដីអូ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០

ផ្អែកតាមប្រសាសន៍ណែនាំរបស់ឯកឧត្តម **រស់ សីលវ៉ា** ក្នុងសិក្ខាសាលាផ្សព្វផ្សាយ,



ហ.) ក្នុងសិក្ខាសាលាផ្សព្វផ្សាយសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូល ពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា

*គោលបំណងនៃការរៀបចំសិក្ខាសាលា ផ្សព្វផ្សាយនេះឡើង គឺដើម្បីធានាប្រសិទ្ធភាព នៃការអនុវត្តអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការ គ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រក ចេញចូលតែមួយ រាជធានី ខេត្ត និងជាពិសេស ដើម្បីដោះស្រាយបញ្ហា ដែលកំពុងប្រឈម ពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែន សារពើពន្ធ និងការបែងចែកប្រាក់រង្វាន់ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។*

អង្គសិក្ខាកាមបានផ្តោត ការពិភាក្សាលើចំណុចគន្លឹះៗ រួមមាន ÷ (១) ការគ្រោងចំណូលថវិកាពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយ រាជធានី-ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលបាននៅមន្ទីរអង្គភាពជំនាញរាជធានី-ខេត្ត, (២) ការគ្រោងឥណទានចំណាយថវិកានៃចំណូលដែលប្រមូលបាននៅអង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត និងមន្ទីរ អង្គភាពជំនាញរាជធានី-ខេត្ត, និង(៣) កិច្ចបញ្ជិកាគណនេយ្យទាក់ទងចំណូលដែលជាគុណប្រយោជន៍ដល់ថវិការបស់រដ្ឋបាលរាជធានី-ខេត្ត (ចំណូលពីសេវាដែលប្រមូលបាននៅតាមអង្គភាព ច្រកចេញចូលតែមួយរាជធានី-ខេត្ត និងប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត) ព្រមទាំងជាពិសេសបញ្ហាប្រឈមជាក់ស្តែង ដែលកំពុងកើតមានពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ នៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ។

សិក្ខាសាលាកន្លះថ្ងៃនេះ បានដោះស្រាយបញ្ហាស្មុគស្មាញមួយចំនួនធំ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅសល់ បញ្ហាប្រឈមមួយចំនួនទៀត ដែលត្រូវបន្តយកចិត្តទុកដាក់ ។ ក្នុងន័យនេះ ដោយទទួលបានការប្រគល់ភារកិច្ចពីឯកឧត្តម **រស់ សីលវ៉ា** ក្នុងការដឹកនាំកិច្ចពិភាក្សា និងប្រមូលសុបលទ្ធផលនៃសិក្ខាសាលា, ឯកឧត្តម **យ៉េត វីណែល** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរង នៃ អ.គ.ហ. បានលើកឡើងជាវិធានការ មួយចំនួនបន្ថែមទៀត ជាអាទិ៍ ការពិនិត្យមើលលើការគ្រោងចំណូល, ការរៀបចំកិច្ចបញ្ជិកាគណនេយ្យ, ការកែសម្រួលប្រកាសអន្តរក្រសួង, ការរៀបចំវគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធ, និងការរៀបចំសិក្ខាសាលានៅតាមរដ្ឋបាលរាជធានី-ខេត្តបន្ថែមទៀត ។

ជាទីបញ្ចប់, ឯកឧត្តម **យ៉េត វីណែល** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរង នៃ អ.គ.ហ. បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គភាពពាក់ព័ន្ធក្នុងការខិតខំប្រឹងប្រែងសហការរៀបចំ និងធ្វើបទបង្ហាញសារាចរខាងលើ និងតំណាងរដ្ឋបាលខេត្ត, តំណាងក្រសួងពាក់ព័ន្ធ, តំណាងរតនាគារខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំង ២៥ខេត្ត ដែលបានសម្របសម្រួល និងចូលរួមសិក្ខាសាលាខាងលើនេះ ប្រព្រឹត្តទៅដោយរលូន និងប្រកដោយផ្លែផ្កា៕■

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃ អ.គ.ហ.*

# ពិធី "ដាក់ឱ្យដំណើរការសន្ទានកម្មជាផ្លូវការរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ"

*នៅថ្ងៃពុធ ៦កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំពិធី "ដាក់ឱ្យដំណើរការសន្ទានកម្មជាផ្លូវការរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និង ប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ" ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។*

ការងារនេះបានសម្រេចនូវទំនើបកម្ម និងស្វ័យប្រវត្តិកម្មនៃការចែករំលែកទិន្នន័យចំណូលពន្ធដារទៅវិញទៅមករវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារជាមួយនឹងប្រព័ន្ធ FMIS លើមុខងារចំនួនពីរ គឺ÷

❶. ការបញ្ជូនទិន្នន័យចំណូលថវិកាចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារទៅប្រព័ន្ធ FMIS ជំនួសឱ្យការចេញក្រដាស់សលាកបត្របង់ប្រាក់ចូលថវិកាជាតិ និងថ្នាក់ក្រោមជាតិ ដែលពីមុនត្រូវការពេលវេលាយូរ, ប្រើប្រាស់ក្រដាសស្នាម និងនីតិវិធីស្មុគ្រស្មាញជាច្រើន។

❷. ការបញ្ជូនទិន្នន័យចំណូលពន្ធដារ ដែលបានកាត់ទុកដោយអគ្គនាយកដ្ឋានរតនាគារជាតិ និង រតនាគាររាជធានី-ខេត្តចេញពីប្រព័ន្ធ FMIS ទៅប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារដោយបែង-ចែកយ៉ាងលម្អិតច្បាស់លាស់ទៅតាមប្រភេទពន្ធ និងអាករនានា ។

ក្នុងពិធីនេះ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារបានថ្លែងអំពីវឌ្ឍនភាព និងអត្ថប្រយោជន៍សំខាន់ៗនៃការធ្វើសន្ទានកម្មនេះ និងបានថ្លែងអំណរគុណដល់ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** ដែលបានដឹកនាំការ ឱ្យសម្រេចបានការធ្វើសន្ទានកម្មរវាងប្រព័ន្ធទាំងពីរនេះតាមគោលដៅចង់បានរបស់ឯកឧត្តមអគ្គបណ្ឌិត-សភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ក្នុងការធ្វើទំនើប-កម្ម និងស្វ័យប្រវត្តិកម្មការប្រមូលចំណូលថវិកាជាតិ ហើយរហូតមកដល់ពេលនេះ អគ្គនាយកដ្ឋានពន្ធដារសម្រេចបាននូវការងារទំនើបកម្មជាបន្តបន្ទាប់នានា ក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងចំណូលពន្ធដារ និងអាករនានា។ ជាពិសេសប្រព័ន្ធផ្តល់សេវាផ្សេងៗជូនអ្នកជាប់ពន្ធ ជាមួយនឹងការខិតខំប្រឹង-ប្រែងធ្វើសន្ទានកម្មទៅកាន់ប្រព័ន្ធនានារបស់រាជរដ្ឋាភិបាលរួមមាន÷ប្រព័ន្ធប្រមូលពន្ធគយនិងអាកររបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ប្រព័ន្ធគ្រប់គ្រងមធ្យោបាយយានយន្តរបស់ក្រសួងសាធារណការនិងដឹកជញ្ជូនដែលនឹងសម្រេចបានក្នុងពេលដ៏ខ្លីខាងមុខ ពោលគឺដូចនឹងនេះគឺសម្រេចបាននូវការតភ្ជាប់ជាមួយប្រព័ន្ធ FMIS។ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** បានបញ្ជាក់ជូនអង្គពិធីថា បើគិតមកដល់ពេលបច្ចុប្បន្ននេះ ប្រព័ន្ធ FMIS បានដាក់



*ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS ក្នុងពិធីប្រកាសដាក់ឱ្យដំណើរការសន្ទានកម្មរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០*



ពិធីប្រកាស់ដាក់ឱ្យដំណើរការសន្ទានកម្មរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០

*ការធ្វើសន្ទានកម្មប្រព័ន្ធទាំងពីរនេះ គឺជាការសម្រេចបានដោយជោគជ័យនូវផែនការគន្លឹះមួយនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលជាចក្ខុវិស័យរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាក្នុងការបង្កើនប្រសិទ្ធភាពដល់ការងារគ្រប់គ្រងការប្រមូលចំណូលថវិកាជាតិ, ការសន្សំសំចៃចំណាយថវិកាជាតិតាមរយៈការកាត់បន្ថយការប្រើប្រាស់ក្រដាសស្នាម និងនីតិវិធីស្មុគ្រស្មាញនានា។*

ឱ្យដំណើរការស្មើរតែគ្រប់អង្គភាពសាមីទទួលបន្ទុកហិរញ្ញវត្ថុ និង ថវិកានៅទូទាំងប្រទេស ដែលរួមមានអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័នទាំងអស់, អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រតនាគាររាជធានី-ខេត្តទាំង ២៥ ។ លើសពីនេះ, ប្រព័ន្ធ FMIS ក៏បានតភ្ជាប់ជាមួយប្រព័ន្ធផ្សេងៗជាច្រើនទៀត ក្នុងនោះមាន ÷

- ❖ ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយនិងប្រព័ន្ធអេឡិចត្រូនិកគយ
- ❖ ប្រព័ន្ធធនាគាររបស់ធនាគារជាតិ នៃកម្ពុជា និងធនាគារពាណិជ្ជដៃគូជាច្រើន
- ❖ ប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ
- ❖ ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

ការធ្វើសន្ទានកម្មប្រព័ន្ធទាំងពីរនេះ គឺជាការសម្រេចបានដោយជោគជ័យនូវផែនការគន្លឹះមួយនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដែលជាចក្ខុវិស័យដ៏មោះមុត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការបង្កើនប្រសិទ្ធភាពដល់ការងារគ្រប់គ្រងការប្រមូលចំណូលថវិកាជាតិ, ការសន្សំសំចៃចំណាយថវិកាជាតិតាមរយៈការកាត់បន្ថយការប្រើប្រាស់ក្រដាសស្នាម និងនីតិវិធីស្មុគ្រស្មាញនានា, ចូលរួមបង្កើនផលិតភាពការងាររបស់មន្ត្រីពន្ធដារ និងរតនាគារ។ ជាពិសេសគឺការផ្តល់ព័ត៌មានស្តីពីចំណូលថវិកាជាតិបានកាន់តែឆាប់រហ័ស។

គួរបញ្ជាក់ផងដែរថាគិតត្រឹមជំហានទី២ នៃការដាក់ឱ្យអនុវត្តគម្រោង FMIS ដែលបានគ្របដណ្តប់ស្មើរទូទាំងប្រទេសហើយនេះ ប្រព័ន្ធ FMIS ក៏បានធ្វើសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យសំខាន់ៗដទៃទៀតដែលរួមមាន ÷

- ❖ ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ និងប្រព័ន្ធអេឡិចត្រូនិចគយ (ASYCUDA & E-Customs)
- ❖ ប្រព័ន្ធធនាគាររបស់ធនាគារជាតិ នៃកម្ពុជា និង របស់ធនាគារពាណិជ្ជដូចជា ធនាគារអេស៊ីលីដា, ធនាគារ JTrust, ធនាគារស្ថាបនា, ធនាគារកាណាឌីយ៉ា
- ❖ ប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ (DMFAS)
- ❖ ប្រព័ន្ធគ្រប់គ្រង់ចំណូលមិនមែនសារពើពន្ធ (NRMIS) ៕■

*រៀបចំដោយ÷ ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*



ពិធីប្រកាស់ដាក់ឱ្យដំណើរការសន្ទានកម្មរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០

# ការចែករំលែកបទពិសោធស្តីពីការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈជូនគណៈប្រតិភូមីយ៉ាន់ម៉ា

*នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ អគ្គលេខាធិការដ្ឋានដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) បានដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំស្តីពី ការចែករំលែកបទពិសោធការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតជាសំខាន់លើការរៀបចំស្ថាប័ន និងដំណើរការកសាងសមត្ថភាពតបតាមសំណើរបស់គណៈប្រតិភូមីយ៉ាន់ម៉ានៃ Myanmar PFM Academy ក្រោមការសម្របសម្រួលពីធនាគារពិភពលោកប្រចាំប្រទេសមីយ៉ាន់ម៉ា និងប្រចាំប្រទេសកម្ពុជា។*

កិច្ចប្រជុំចែករំលែកបទពិសោធនេះ ត្រូវរៀបចំតាមរយៈប្រព័ន្ធវីដេអូ (Video Conference) ដែលបានដឹកនាំដោយឯកឧត្តម **មាស សុខសេនសាន** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការ នៃ **អ.គ.ហ.** អមដោយមន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីជំនាញនៃ **អ.គ.ហ.** និងមានការចូលរួមពីតំណាងវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាតំណាងភាគីកម្ពុជា ព្រមទាំងការចូលរួមពីគណៈប្រតិភូមីយ៉ាន់ម៉ានៃ Myanmar PFM Academy ដែលដឹកនាំដោយអគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងផែនការនិងហិរញ្ញវត្ថុ ដែលជាតំណាងភាគីនៃប្រទេសមីយ៉ាន់ម៉ា។

Myanmar PFM Academy ជាអង្គភាពមួយក្នុងចំណោមអង្គភាពទាំង៥ នៃគម្រោង Myanmar Modernization of Public Financial Management (MMPFM) ដែលទើបតែបានបង្កើតឡើងនៅដើមឆ្នាំ២០២០ ជាមួយនឹងចក្ខុវិស័យនៃការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការប្រកបដោយទំនួលខុសត្រូវ ដើម្បីពង្រឹងការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព។ តាមរយៈកិច្ចប្រជុំនេះ Myanmar PFM Academy បានស្នើសុំការចែករំលែកបទពិសោធននៃការងារកែទម្រង់របស់ប្រទេសកម្ពុជា ដែលផ្តោតជាចម្បងលើការរៀបចំ និងកិច្ចដំណើរការនៃការកសាងសមត្ថភាពរបស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជាការចែករំលែក ឯកឧត្តម **មាស សុខសេនសាន** បានធ្វើបទបង្ហាញពីវឌ្ឍនភាព និងការវិវត្តនៃប្រព័ន្ធសេដ្ឋកិច្ចរបស់កម្ពុជាតាំងពីទសវត្សទី៥០ រហូតដល់ដំណាក់កាលនៃការបង្កើតកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដោយរំលេចពីកត្តាជោគជ័យ បញ្ហាប្រឈម និងទិសដៅទៅថ្ងៃខាងមុខ។ ជាមួយគ្នានោះ តំណាង នៃ



ឯកឧត្តម **មាស សុខសេនសាន** អគ្គលេខាធិការរងនៃ អ.គ.ហ. ក្នុងកិច្ចប្រជុំចែករំលែកបទពិសោធស្តីពីការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈជូនគណៈប្រតិភូ តាមប្រព័ន្ធ Video នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ ។

វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើបទបង្ហាញចែករំលែកអំពីចំណុចសំខាន់មួយចំនួន ជូនគណៈប្រតិភូមីយ៉ាន់ម៉ា ដូចខាងក្រោម៖

**❶. ការរៀបចំរចនាសម្ព័ន្ធ និងប្រភពថវិកានៃវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖** វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៧ និងត្រូវបានដំឡើងជាអគ្គនាយកដ្ឋាន នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៥ ដែលមាននាយកដ្ឋានចំនួន៣ សម្រាប់គាំទ្ររួមមាន នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្មវិធី, នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ព្រមទាំងនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ។ វិទ្យាស្ថានមានប្រភពគាំទ្រហិរញ្ញវត្ថុពីថវិការដ្ឋ ថវិកា

នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងថវិការបស់ដៃគូនានាអាស្រ័យលើកិច្ចសហការនៃប្រភេទការងារផ្សេងៗគ្នា។

**❷. ការរៀបចំកម្មវិធីសិក្សានិងវគ្គបណ្តុះបណ្តាល÷** ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាទិសដៅ នៃការរៀបចំកម្មវិធីបណ្តុះបណ្តាល។ កម្មវិធីបណ្តុះបណ្តាលត្រូវបានបែងចែកជា៣ ធំៗ រួមមាន វគ្គបណ្តុះបណ្តាលរយៈពេលវែង មធ្យម និងខ្លី។ ដើម្បីទទួលបានធាតុចូល ក្នុងការរៀបចំផែនការបណ្តុះបណ្តាលប្រចាំឆ្នាំនីមួយៗ វិទ្យាស្ថានតែងតែរៀបចំកម្រងសំណួរដើម្បីចុះស្ទាបស្ទង់មតិពីមន្ត្រីរាជការ ទាំងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងវិភាគទិន្នន័យ ដើម្បីកំណត់នូវតម្រូវការបណ្តុះបណ្តាលជាអាទិភាព ។ គុណវុឌ្ឍិរបស់សិក្ខាកាមបន្ទាប់ពីវគ្គបណ្តុះបណ្តាលត្រូវបានត្រួតពិនិត្យ និងវាយតម្លៃ ដោយប្រើប្រាស់ម៉ូដែល Kirkpatric, 2006 ដែលផ្តោតលើភាពពេញចិត្តរបស់សិក្ខាកាមលើវគ្គបណ្តុះបណ្តាល, ចំណេះដឹង និងជំនាញដែលសិក្ខាកាមទទួលបាន, ប្រសិទ្ធភាពនៃការប្រើប្រាស់ចំណេះដឹងទៅនឹងការអនុវត្តជាក់ស្តែង និងការវិភាគលើលទ្ធផលចុងក្រោយ។

*ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាទិសដៅ នៃការរៀបចំកម្មវិធីបណ្តុះបណ្តាល ។*




*កិច្ចប្រជុំចែករំលែកបទពិសោធស្តីពីការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈជូនគណៈប្រតិភូ តាមប្រព័ន្ធ Video នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០ ។*

**❸. បញ្ហាប្រឈម÷** តាមរយៈការអនុវត្តកន្លងមក វិទ្យាស្ថាននៅតែប្រឈមនឹងផលវិបាកធំៗមួយចំនួនក្នុងការរៀបចំវគ្គបណ្តុះបណ្តាល ដូចជាការរៀបចំវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអេឡិចត្រូនិច ដូចជា e-learning និង digital platform ដោយសារពុំទាន់មានសម្ភារគាំទ្រគ្រប់គ្រាន់, ការរៀបចំមុខវិជ្ជាជំនាញ ឯកសារ និងសម្ភារបណ្តុះបណ្តាល និងវិក្រឹតការ ស្របតាមតម្រូវការសិក្ខាកាមនៅមានកម្រិត និងកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធលើការគាំទ្រក្នុងការផ្តល់ធនធានមនុស្ស និងការគាំទ្រលើការរៀបចំវគ្គបណ្តុះបណ្តាលក៏នៅមានកម្រិត។

**❹. មតិយោបល់របស់វិទ្យាស្ថានសម្រាប់ Myanmar PFM Academy÷** វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានផ្តល់អនុសាសន៍ និងការណែនាំ Myanmar PFM Academy ឱ្យគិតគូរ និងរៀបចំផែនការយុទ្ធសាស្ត្រកសាងសមត្ថភាព និងផែនការសកម្មភាពប្រតិបត្តិប្រចាំឆ្នាំជាមុន ព្រោះវាជាផែនទីចង្អុលទិសដែលមានសារៈប្រយោជន៍ក្នុងការកំណត់គោលដៅនៃការកសាងសមត្ថភាពមន្ត្រីទៅថ្ងៃក្រោយ ជាពិសេសពង្រឹងការងារត្រួតពិនិត្យ និងវាយតម្លៃសមត្ថភាពមន្ត្រីយ៉ាងមានប្រសិទ្ធភាព៕■




*រៀបចំដោយ÷ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.*





# ផ្នែកទី ២

# អត្ថបទ

# ការអនុវត្តគោលការណ៍ស័ក្តិសិទ្ធភាពនៃកិច្ចសហការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*រាជរដ្ឋាភិបាលកម្ពុជាតែងរក្សានូវកិច្ចសហការល្អជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ ក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជាតិ និងកម្មវិធីកែទម្រង់វិស័យសាធារណៈ ប្រកបដោយឥរិយាបថទន់ភ្លន់ តែម៉ឺងម៉ាត់។ បើទោះជាកិច្ចសហការមានការវិវត្តអាស្រ័យនឹងបរិការណ៍ និងអាទិភាពនៃទិសដៅអភិវឌ្ឍន៍ក្តី, រាជរដ្ឋាភិបាលនៅតែប្រកាន់នូវជំហរ និងឥរិយាបថស្របតាមគោលការណ៍ស័ក្តិសិទ្ធភាពនៃកិច្ចសហការអភិវឌ្ឍន៍ រួមមាន (១) ការគោរពភាពជាម្ចាស់របស់រាជរដ្ឋាភិបាល, (២) ការអនុវត្តយន្តការភាពជាដៃគូ, និង (៣) ការផ្តោតកិច្ចសហការលើលទ្ធផលអភិវឌ្ឍន៍ សម្រាប់តម្រង់ទិសការអនុវត្តកិច្ចសហការអភិវឌ្ឍន៍រវាងអង្គភាពជាស្ថាប័នរាជរដ្ឋាភិបាល និងអង្គភាពជាតំណាងរបស់ដៃគូអភិវឌ្ឍន៍។*

ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) បានអនុវត្តគោលការណ៍របស់រាជរដ្ឋាភិបាល ដោយបានបង្កើតអភិក្រមការងារ, រៀបចំយន្តការសម្របសម្រួល និងប្រើប្រាស់ឧបករណ៍ប្រតិបត្តិ ដែលសំដៅលើកកម្ពស់ "វប្បធមិសន្ទុនា និងសមិទ្ធកម្ម"។ ជាប្រព័ន្ធគ្រប់គ្រង, **គ.ហ.ស.** អនុវត្តអភិក្រម ការគ្រប់គ្រងផ្អែកលើលទ្ធផល ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់នេះ តាមរយៈការដាក់ចេញនូវចក្ខុវិស័យ, យុទ្ធសាស្ត្រ និងក្របខ័ណ្ឌផែនការសកម្មភាពរួម ហើយអង្គភាពអនុវត្តទាំងអស់ត្រូវរៀបចំផែនការសកម្មភាពរបស់អង្គភាពសាមី ដើម្បីឈានទៅសម្រេចនូវគោលដៅនោះ។ ផ្អែកតាមកិច្ចពិភាក្សាជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍អាចផ្តល់ការគាំទ្រតាមទម្រង់នៃកិច្ចសហការបែបណាមួយ ដែលខ្លួនប្រមើលឃើញថាមានគុណប្រយោជន៍ដល់គោលបំណងនៃកិច្ចសហការ។

ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលបានទទួលការគាំទ្រពីដៃគូអភិវឌ្ឍន៍សំខាន់ៗជាច្រើនរួមមាន÷ សហភាពអឺរ៉ុប (EU), ទីភ្នាក់ងារអភិវឌ្ឍន៍អាល្លឺម៉ង់, ដាណឺម៉ាក់, ស៊ុយអែត, ជប៉ុន, អូស្ត្រាលី, អង់គ្លេស, និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដូចជា ធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិរូបិយវត្ថុអន្តរជាតិផងដែរ។ ដើម្បីតម្រឹមការគាំទ្រពីដៃគូអភិវឌ្ឍន៍ឱ្យមានសង្គតិភាព និងសុខដុមនីយកម្មល្អទៅនឹងគោលដៅ នៃកម្មវិធីកែទម្រង់, **គ.ហ.ស.** ផ្តល់សមត្ថកិច្ចជូនអគ្គលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



(**អ.គ.ហ.**) ជាសេនាធិការក្នុងការកៀរគរធនធានទាំងហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស ហើយនឹងសម្របសម្រួលកិច្ចសហការរវាងក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ជាមួយដៃគូអភិវឌ្ឍន៍ ដោយប្រើប្រាស់យន្តការពិគ្រោះយោបល់ រួមទាំងឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈជាច្រើនរូបភាព ។

តួយ៉ាង, ការអនុវត្តកិច្ចសហការជាមួយសហភាពអឺរ៉ុបបង្ហាញថា **អ.គ.ហ.** បានសម្របសម្រួលរៀបចំក្របខ័ណ្ឌលទ្ធផលនៃកិច្ចព្រមព្រៀងមូលនិធិទ្រទ្រង់ថវិកា[១] ជាមួយគ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដោយផ្តោតលើកិច្ចការអាទិភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ។ ជំហានបន្ទាប់, ការតាមដានការអនុវត្តគោលដៅសូចនាករសមិទ្ធកម្មនោះ ត្រូវធ្វើជាទៀងទាត់តាមកិច្ចប្រជុំប្រចាំខែ, ប្រចាំត្រីមាស និងឆ្នាំ ។






ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៣ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមតម្រូវការចាំបាច់ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ

**សម្រេច**

**ប្រការ ១.** –

ត្រូវបានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដូចមានឯកសារភ្ជាប់នឹងសេចក្តីសម្រេចនេះ សម្រាប់លើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ។



**ប្រការ ២.** –

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវរៀបចំសេចក្តីណែនាំសម្រាប់អនុវត្តយន្តការ និងឧបករណ៍ ដែលមានចែងក្នុងយុទ្ធសាស្ត្រនេះ ដើម្បីស្នើជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ពិនិត្យ និងសម្រេច ។

**ប្រការ ៣.** –

ប្រគល់ភារកិច្ចជូនឯកឧត្តម **ឈឿង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីសម្របសម្រួល និងតាមដានការអនុវត្ត ហើយត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ និងពាក់កណ្តាលអាណត្តិស្តីពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រនេះ ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ពិនិត្យ និងផ្តល់អនុសាសន៍ ។

**ប្រការ ៤.** –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ, រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ដៃគូអភិវឌ្ឍន៍, វិស័យឯកជន, អង្គការមិនមែនរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀត ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃសុក្រ ៦ កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ផ្អែកតាមការពិភាក្សា នៃកិច្ចប្រជុំនីមួយៗ, **អ.គ.ហ.** កំណត់នូវវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការដោះស្រាយនៅកម្រិតប្រតិបត្តិ ដែលជាក់ស្តែង ដូចជាការកៀរគរ និងផ្តល់ជំនួយបច្ចេកទេសសម្រាប់គាំទ្រអង្គភាពអនុវត្តជាដើម ។ បញ្ហាប្រឈម

*១ មូលនិធិទ្រទ្រង់ថវិកាគឺជាទម្រង់មួយនៃកិច្ចសហការអភិវឌ្ឍន៍ ដែលរាជរដ្ឋាភិបាលសម្រេចចុះកិច្ចព្រមព្រៀងរួមគ្នាជាមួយសហភាពអឺរ៉ុប ក្នុងការទទួលបានថវិកាមកចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងឆ្នាំ២០១៩ និង២០២០ ។ ក្នុងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ, សហភាពអឺរ៉ុបនឹងបើកផ្តល់ហិរញ្ញប្បទានឥតសំណងប្រមាណ ១៤ លានអឺរ៉ូ ផ្អែកលើលទ្ធផលសម្រេចបានប្រចាំឆ្នាំ។*

*តារាងទី២៖ គោលដៅសូចនាករសមិទ្ធកម្មនៃកិច្ចព្រមព្រៀងមូលនិធិទ្រទ្រង់ថវិកាឆ្នាំ២០២០*

| គោលដៅសូចនាករសមិទ្ធកម្ម | | ក្រសួង ស្ថាប័នអនុវត្ត |
|---|---|---|
| ១. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពនៃក្របខ័ណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ឆ្នាំ២០២១-២០២៥ ត្រូវបានអនុម័តត្រឹមត្រីមាសទី១ ឆ្នាំ២០២១ | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃ កសហវ. |
| ២.១. | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានដាក់ឱ្យប្រើប្រាស់នៅគ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត | ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃ កសហវ. |
| ២.២. | ម៉ូឌុលថ្មីនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចំនួន ២ ត្រូវបានអភិវឌ្ឍ ។ (១) ម៉ូឌុលលទ្ធកម្មពេញលេញត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមួយផ្សេងទៀតក្នុងឆមាសទី១ ឆ្នាំ២០២១ (២) ម៉ូឌុលរៀបចំថវិកាត្រូវបានដាក់ឱ្យអនុវត្តសាកល្បងក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមួយផ្សេងទៀតក្នុងឆមាសទី១ ឆ្នាំ២០២១ សម្រាប់រៀបចំថវិកាឆ្នាំ២០២២ | ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃ កសហវ. |
| ៣. | រដ្ឋបាលខេត្តទាំង២៤ អនុវត្តថវិកាកម្មវិធីក្នុងឆ្នាំ២០២០ | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃ កសហវ. |
| ៤. | កម្មវិធី និងឯកសារសម្រាប់បណ្តុះបណ្តាលលើសវនកម្មសមិទ្ធកម្មត្រូវបានរៀបចំក្នុងឆ្នាំ២០២០ | អាជ្ញាធរជាតិសវនកម្ម |
| ៥. | សេចក្តីព្រាងច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានបញ្ជូនទៅក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យក្នុងឆ្នាំ២០២០ | អគ្គនាយកដ្ឋានថវិកា នៃ កសហវ. |
| ៦.១. | អនុក្រឹត្យស្តីពីនីតិវិធីប្រតិបត្តិរួមសម្រាប់គ្រប់គ្រងវិនិយោគសាធារណៈនៃគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជនត្រូវបានអនុម័តក្នុងឆ្នាំ២០២០ | អង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនថ្នាក់ជាតិ នៃ កសហវ. |

| | | |
|---|---|---|
| ៦.២. | សេចក្តីព្រាងចុងក្រោយនៃប្រកាសស្តីពីនីតិវិធីប្រតិបត្តិរួមសម្រាប់គ្រប់គ្រងវិនិយោគសាធារណៈនៅរដ្ឋបាលថ្នាក់ជាតិត្រូវបានដាក់ពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នក្នុងឆ្នាំ២០២០ | អគ្គនាយកដ្ឋានថវិកា នៃ កសហវ. |
| ៦.៣. | សេចក្តីព្រាងចុងក្រោយនៃប្រកាសស្តីពីនីតិវិធីប្រតិបត្តិរួមសម្រាប់គ្រប់គ្រងវិនិយោគសាធារណៈនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដាក់ពិគ្រោះយោបល់ជាមួយរដ្ឋបាលរាជធានី-ខេត្តក្នុងឆ្នាំ២០២០ | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃ កសហវ. |
| ៧. | ថេរវេលាជាមធ្យមនៃការបង្វិលសងអាករលើតម្លៃបន្ថែមក្នុងឆ្នាំ២០២០ ត្រូវសម្រេចត្រឹម៣៥ ថ្ងៃនៃថ្ងៃធ្វើការ (កម្រិតអគ្គនាយកដ្ឋានពន្ធដារ) | អគ្គនាយកដ្ឋានពន្ធដារ នៃ កសហវ. |
| ៨. | ស្ថិតិលទ្ធកម្មនៃគម្រោងទទួលហិរញ្ញប្បទានពីថវិកាជាតិត្រូវបានចងក្រង និងផ្សព្វផ្សាយលើគេហទំព័រនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈក្នុងឆ្នាំ២០២០ | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃ កសហវ. |

ដែលពុំអាចដោះស្រាយបាន ត្រូវបន្តការតាមដាន និងលើកស្នើទៅសុំកិច្ចអន្តរាគមន៍ពីថ្នាក់ដឹកនាំ។ ប្រព័ន្ធសម្របសម្រួលកិច្ចសហការខាងលើនេះ មិនត្រឹមតែបង្កើនជវភាពនៃការអនុវត្តកិច្ចសហការតែប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំងជំរុញឱ្យតួអង្គពាក់ព័ន្ធទាំងអស់ធ្វើការងាររួមគ្នាឆ្ពោះទៅសម្រេចសូចនាករសមិទ្ធកម្ម ដែលជាឧបករណ៍ធានានូវគណនេយ្យភាពផងដែរ។

បន្ថែមពីនេះ, អនុលោមតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ០៩ សរ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី "វិធាន និងនីតិវិធី នៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" ដៃគូអភិវឌ្ឍន៍ក៏ត្រូវបានស្វាគមន៍ឱ្យចូលរួម និងផ្តល់មតិយោបល់ក្នុងកិច្ចប្រជុំពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូលជាប្រចាំថែមទៀតផង។ម្យ៉ាងទៀត, តំណាងដៃគូអភិវឌ្ឍន៍ក៏អាចលើកនូវលទ្ធផល នៃការសិក្សា ការវាយតម្លៃ និងអនុសាសន៍ផ្ទាល់ខ្លួនដើម្បីពិភាក្សា និងស្នើសុំការពិចារណាផងដែរ។ ក្នុងន័យនេះ, ការរៀបចំកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយដៃគូអភិវឌ្ឍន៍ បានក្លាយជាវេទិកាពិគ្រោះយោបល់កម្រិតគោលនយោបាយដ៏សំខាន់ ក្នុងការកំណត់គោលដៅ និងទិសដៅកែទម្រង់នេះ។

ជារួម, ការអនុវត្តកិច្ចសហការអភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានសន្និដ្ឋានថាបានប្រព្រឹត្តទៅ ស្របតាមគោលការណ៍នៃកិច្ចសហការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលពោលគឺរក្សាភាពជាម្ចាស់និងភាពទន់ភ្លន់តែមុឹងម៉ាត់ ដើម្បីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព៕■

*ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលបានទទួលការគាំទ្រពីដៃគូអភិវឌ្ឍន៍សំខាន់ៗរួមមាន÷ សហភាពអឺរ៉ុប (EU), ទីភ្នាក់ងារអភិវឌ្ឍន៍អាឡឺម៉ង់, ដាណាម៉ាក់, ស៊ុយអែត, ជប៉ុន, អូស្ត្រាលី, អង់គ្លេស, និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដូចជាធនាគារពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិរូបិយវត្ថុអន្តរជាតិផងដែរ។*

*រៀបចំដោយ÷ ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ នៃ អ.គ.ហ.*

# វឌ្ឍនភាពនៃការដាក់ឱ្យអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មគយ

*ស្របតាមកម្មវិធីកែទម្រង់ដ៏មុតស្រួច ក៏ដូចជាយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, យុទ្ធសាស្ត្រកំណែទម្រង់ និងទំនើបកម្មគយ ឆ្នាំ២០១៩-២០២៣, និងយុទ្ធសាស្ត្របច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានឆ្នាំ២០២០-២០២៤ សំដៅបន្តអភិវឌ្ឍបន្ថែមទៀត តាមរយៈការធ្វើទំនើបកម្មរដ្ឋបាលរបស់ខ្លួន ដោយប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្នុងន័យឆ្លើយតបបានទាំងប្រសិទ្ធភាពការងារប្រមូលចំណូល ការបង្កលក្ខណៈដល់បរិយាកាសធុរកិច្ច និងកិច្ចសម្រួលពាណិជ្ជកម្មកាន់តែប្រសើរឡើងថែមទៀត។*

## ❶. ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា)

ដោយទទួលបានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (**អ.គ.រ.**) ដែលនាពេលនោះជាទីចាត់ការគយនិងរដ្ឋាករ បានចុះហត្ថលេខាលើឯកសារគម្រោងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ ឬហៅកាត់ថា អាស៊ីគូដា (រើល) ជាមួយអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្ម និងការអភិវឌ្ឍ (UNCTAD) នាថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៦ ក្រោមគម្រោងគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ដែលសម្របសម្រួលដោយធនាគារពិភពលោក តាមរយៈគម្រោងកិច្ចសម្រួលពាណិជ្ជកម្ម និងប្រកួតប្រជែង (Trade Facilitation and Competitiveness Project/TFCP) បន្ទាប់មកក្រោមកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (Trade Development Support Program/TDSP)។ ការអនុវត្តគម្រោងត្រូវបានបែងចែកចេញជាដំណាក់កាលៗ រួមមាន÷ការកសាង គំរូ "Prototype", ការដាក់ឱ្យអនុវត្តសាកល្បង "Pilot Site" និងការពង្រីកបន្ថែម (Roll out) ឱ្យគ្របដណ្តប់នៅទូទាំងប្រទេស។

ជាលទ្ធផលសំខាន់ដែលសម្រេចបាន, ឯកសាររដ្ឋបាលតែមួយហៅថាប្រតិវេទន៍គយ (Single Administrative Document - SAD) ដែលរាល់កូដយោងនានាមានលក្ខណៈស្តង់ដារអន្តរជាតិ និងអនុលោមតាមអនុសញ្ញាអន្តរជាតិនានាស្តីពីគយ ត្រូវបានកសាងរួចរាល់ និងត្រូវបានដាក់ឱ្យអនុវត្តដោយដៃនៅទូទាំងប្រទេសនាថ្ងៃទី០១ ខែមករា ឆ្នាំ២០០៨។ ឯកសារ SAD នេះ និងឯកសារផ្សេងៗមួយចំនួនទៀតមានជាអាទិ៍ តារាងពន្ធគយកម្ពុជា, វិធាននៃការគណនាប្រាក់ពន្ធបញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់, លក្ខណៈវិនិច្ឆ័យជ្រើសរើសសម្រាប់កំណត់ហានិភ័យ, កូដក្រុមហ៊ុន និងកូដយោងនានា ត្រូវកសាង និងដាក់បញ្ចូលទៅក្នុងប្រព័ន្ធអាស៊ីគូដា។ ក្រោយពីបានកសាងរួច ប្រព័ន្ធអាស៊ីគូដានេះត្រូវបានប្រកាសដាក់ឱ្យអនុវត្តសាកល្បងនៅមាត់ច្រកកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ **នាថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៨**។ បន្ទាប់មកប្រព័ន្ធនេះត្រូវបានពង្រីកបន្ថែមនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងនៅផែស្ងួតចំនួនពីរបន្ថែមទៀត នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០។

បន្ថែមលើនេះ, **អ.គ.រ.** បានយកចិត្តទុកដាក់ខ្ពស់បំផុតកិច្ចប្រតិបត្តិការប្រចាំថ្ងៃ និងថែទាំប្រព័ន្ធបានល្អប្រសើរដោយខ្លួនឯងពីខែមករា ឆ្នាំ២០១០ រហូតមកដល់ខែមីនា ឆ្នាំ២០១១ ទើបមានក្រុមហ៊ុន Webb Fontaine Group FZ-LLC ដែលបានឈ្នះក្នុងការដេញថ្លៃ និងបានចុះកិច្ចសន្យាជាមួយក្រសួងពាណិជ្ជកម្ម មកផ្តល់សេវាគម្រោងពង្រីកប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយនេះ បន្តពីអ្នកជំនាញការ UNCTAD។ ក្រុមហ៊ុននេះ មានដៃគូជាមួយក្រុមហ៊ុនក្នុងស្រុកឈ្មោះ Resolvo Cambodia ជា Sub-Consultants។ ក្រុមហ៊ុននេះ ក៏បានបញ្ចប់បេសកកម្មរបស់ខ្លួន នៅក្នុងអំឡុងខែកក្កដា ឆ្នាំ២០១២ ដោយបានធ្វើមជ្ឈការប្រព័ន្ធ (Centralized Server), ប្រព័ន្ធ Disaster Recovery Site (DRS), ពង្រីកបន្ថែមប្រព័ន្ធទៅមាត់ច្រកគយចំនួន ១៩ កន្លែងបន្ថែមទៀត, ដាក់ឱ្យសាកល្បងមុខងារប្រព័ន្ធនិវេទន៍ប័ណ្ណ (Manifest)

*គិតមកដល់បច្ចុប្បន្ន ប្រព័ន្ធអាស៊ីគូដាត្រូវបាន ពង្រីកវិសាលភាព និងដាក់ឱ្យអនុវត្តនៅ នាយកដ្ឋានសាខា និងការិយាល័យគយនិង រដ្ឋាករបំពេញបែបបទទាំងអស់ចំនួន៨៤ កន្លែងទូទាំងប្រទេស ដែលគ្របដណ្តប់ ទាំងស្រុងលើអង្គភាពគយនិងរដ្ឋាករដែលមាន កិច្ចប្រតិបត្តិការនាំចេញ-នាំចូល។*

នៅមាត់ច្រកកំពង់ផែភ្នំពេញ, និងមុខងារ ភណ្ឌាគារគយមានដែនកំណត់។

ក្រោមគម្រោង Trade Development Support Program -TDSP) ចាប់ពីខែ កក្កដា ឆ្នាំ២០១២ សម្រាប់រយៈពេល១៨ ខែ **អ.គ.រ.** បានបន្តអនុវត្តគម្រោងនេះ រហូតមកដល់ចុងខែមិថុនា ឆ្នាំ២០១៦។ ដើម្បីធានាបាននិរន្តរភាពកិច្ចប្រតិបត្តិការ ប្រចាំថ្ងៃ ការថែរក្សា និងការគ្រប់គ្រងហេដ្ឋា-រចនាសម្ព័ន្ធគាំទ្រគម្រោងប្រព័ន្ធអាស៊ីគូដា, ចាប់ពីខែកក្កដា ឆ្នាំ២០១៦ មកដល់បច្ចុប្បន្ន គម្រោងនេះត្រូវបានប្រើប្រាស់ថវិការដ្ឋទាំង ស្រុងលើសម្ភារៈ បរិក្ខារសម្រាប់បំពាក់បន្ថែម និងសម្រាប់ផ្លាស់ជំនួសថ្លៃសេវាខ្សែកាប អុបទិក, ប្រាក់ខែជួលបុគ្គលិកជាប់កិច្ចសន្យា, និងការចំណាយផ្សេងៗ។

គិតមកដល់បច្ចុប្បន្ន ប្រព័ន្ធអាស៊ីគូដា ត្រូវបានពង្រីកវិសាលភាព និងដាក់ឱ្យ អនុវត្តនៅនាយកដ្ឋានសាខា និងការិយាល័យ គយនិងរដ្ឋាករបំពេញបែបបទទាំងអស់ សរុបចំនួន៨៤ កន្លែង ទូទាំងប្រទេស ដែល គ្របដណ្តប់ទាំងស្រុងលើអង្គភាពគយនិង រដ្ឋាករដែលមានកិច្ចប្រតិបត្តិការនាំចេញ-នាំចូល ។ មុខងារសំខាន់ៗរបស់ប្រព័ន្ធ អាស៊ីគូដា ដែលបានដាក់ឱ្យអនុវត្តរួមមាន÷

## ❷. ប្រព័ន្ធអេឡិចត្រូនិកគយ(E-Customs)

- ស្វ័យប្រវត្តិកម្មប្រតិវេទន៍គយ (នាំចេញ-នាំចូល)
- គ្រប់គ្រងប័ណ្ណបញ្ចេញទំនិញពីគយ
- គ្រប់គ្រងភណ្ឌាគារគយមានដែនកំណត់
- គ្រប់គ្រងបង្កាន់ដៃពន្ធយានយន្ត
- គ្រប់គ្រងគណនេយ្យ (ទូទាត់ និងបង្វិលសង)
- គណនាប្រាក់ពន្ធតាមគ្រប់ទម្រង់ដោយស្វ័យប្រវត្តិ
- គ្រប់គ្រងលក្ខណៈវិនិច្ឆ័យជ្រើសរើសហានិភ័យ
- វាយតម្លៃប្រព្រឹត្តកម្មប្រតិវេទន៍គយតាមកម្រិតហានិភ័យ
- សន្ទានកម្មជាមួយប្រព័ន្ធបញ្ជរតែមួយជាតិ
- គ្រប់គ្រងនិវេទនប័ណ្ណនិងអញ្ញត្តិប័ណ្ណ
- កត់ត្រាលទ្ធផលត្រួតពិនិត្យរូបវន្តទំនិញ
- មុខងារបំពេញបែបបទមុនទំនិញមកដល់
- តាមដានការកែសម្រួលឯកសារ
- គ្រប់គ្រងតារាងពន្ធគយ (HS Code)
- គ្រប់គ្រងអត្រាប្តូរប្រាក់
- គ្រប់គ្រងគណនីប្រើប្រាស់ប្រព័ន្ធ
- គ្រប់គ្រងកូដយោងនានា
- ផលិតរបាយការណ៍

ទន្ទឹមនឹងវឌ្ឍនភាពនៃប្រព័ន្ធអាស៊ីគូដា ខាងលើនេះ, ប្រព័ន្ធអេឡិកត្រូនិកគយ (e-Customs) ក៏ត្រូវបានអភិវឌ្ឍឡើង ដើម្បីគាំទ្រ និងបំពេញបន្ថែមលើប្រព័ន្ធ អាស៊ីគូដានូវនីតិវិធីគយជាក់លាក់មួយចំនួន ផងដែរ។ ជាលទ្ធផល, ប្រព័ន្ធអេឡិកត្រូនិក គយ ត្រូវបានដាក់ឱ្យអនុវត្តនៅតាមនាយក-ដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករ ទាំងអស់សរុបមានចំនួន៩៣ កន្លែងទូទាំង ប្រទេសផងដែរ។មុខងារសំខាន់ៗនៃប្រព័ន្ធ អេឡិកត្រូនិកគយដែលបានដាក់ឱ្យអនុវត្ត មានដូចជា÷

*១. គ្រប់គ្រងលិខិតអនុញ្ញាតដឹកជញ្ជូនសម្រាប់ ទំនិញទូទៅ*
*២. គ្រប់គ្រងលិខិតអនុញ្ញាតដឹកជញ្ជូនសម្រាប់ ទំនិញផលិតផលតេលសិលា*
*៣. គ្រប់គ្រងបង្កាន់ដៃទទួលប្រាក់កក់*
*៤. គ្រប់គ្រងអត្រាប្តូរប្រាក់*
*៥. គ្រប់គ្រងឯកសារគតិយុត្ត*
*៦. គ្រប់គ្រងបញ្ជីសារពើភណ្ឌ*
*៧. ស្វ័យប្រវត្តិកម្មប្រកាសកញ្ចប់បញ្ញើរហ័ស ឬទំនិញតម្លៃទាប*
*៨. សន្ទានកម្មសលាកប័ត្របង់ចំណូលចូល ថវិកាជាតិជាមួយប្រព័ន្ធគ្រប់គ្រងហិរញ្ញ វត្ថុសាធារណៈ (FMIS)*
*៩. សន្ទានកម្មព័ត៌មានបង្កាន់ដៃពន្ធយាន-យន្ត ជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មដឹក-ជញ្ជូនផ្លូវគោកក្រសួងសាធារណៈការ និងដឹកជញ្ជូន (MPWT)*
*១០. គ្រប់គ្រងទំនិញល្មើស ដែលមិនបាន បំពេញកាតព្វកិច្ចពន្ធ*
*១១. គ្រប់គ្រង និងតាមដានការប្រើប្រាស់ ប័ណ្ណសម្គាល់លើមធ្យោបាយដឹកជញ្ជូន ផលិតផលតេលសិលា*
*១២. តាមដាន និងបង្ហាញស្ថានភាពប្រព្រឹត្ត-កម្មប្រតិវេទន៍គយ*
*១៣. ស្វ័យប្រវត្តិកម្មប្រតិវេទន៍គយសង្ខេប*
*១៤. ស្វ័យប្រវត្តិកម្មប្រតិវេទន៍គយឆ្លងកាត់ (ជាតិនិងអន្តរជាតិ)*
*១៥. គ្រប់គ្រង និងកត់ត្រាលទ្ធផលស្កែន កុងតឺន័រ*
*១៦. ទូទាត់តាមមធ្យោបាយអេឡិកត្រូនិក*
*១៧. គ្រប់គ្រងទិន្នន័យមន្ត្រីរាជការគយនិង រដ្ឋាករ*
*១៨. ស្នើសុំគណនីសម្រាប់មន្ត្រីប្រើប្រាស់ ប្រព័ន្ធ*
*១៩. សន្ទានកម្មជាមួយប្រព័ន្ធបញ្ជរតែមួយ ជាតិ*
*២០. សន្ទានកម្មផ្លាស់ប្តូរទិន្នន័យជាមួយ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយក-ដ្ឋានពន្ធដារ*
*២១. គ្រប់គ្រងការចុះបញ្ជីតាមដានការប្រើ ប្រាស់ប័ណ្ណសម្គាល់យានយន្តដឹកជញ្ជូន ឆ្លងកាត់ដើម្បីនាំចេញរបស់វិនិយោគិន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់*
*២២. គ្រប់គ្រងលិខិត និងព័ត៌មានកិច្ចប្រជុំ*

*២៣. គ្រប់គ្រងមធ្យោបាយធ្វើដំណើរទេសចរណ៍ឆ្លងកាត់ព្រំដែនបណ្តោះអាសន្ន*

*២៤. កត់ត្រាបង្កាន់ដៃពន្ធយានយន្តសរសេរដោយដៃ*

បន្ថែមលើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមរយៈកុំព្យូទ័រ, **អ.គ.រ.** បានបង្កើត និងដាក់ឱ្យការប្រើប្រាស់ ទូរស័ព្ទដៃឆ្លាតវៃដែលមានសារសំខាន់និងចាំបាច់ផងដែរ ។ បច្ចុប្បន្ននេះ ទូរស័ព្ទដៃឆ្លាតវៃសម្រាប់ប្រតិបត្តិការ iOS និងប្រតិបត្តិការ Android ដែល **អ.គ.រ.** បានប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់ជួយគាំទ្រដល់ការត្រួតពិនិត្យអនុលោមភាព និងជាគុណប្រយោជន៍ដល់សាធារណជន មានជាអាទិ៍ កម្មវិធីតារាងពន្ធគយឆ្នាំ២០១៧, កម្មវិធីកម្រងអត្ថបទនីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ, កម្មវិធីសម្រាប់ផ្ទៀងផ្ទាត់ឯកសារបោះពុម្ពសម្រាប់មន្ត្រីគយ, និងកម្មវិធីផ្ទៀងផ្ទាត់បង្កាន់ដៃយានយន្តសម្រាប់សាធារណជនជាដើម។

### ❸. ប្រព័ន្ធគ្រប់គ្រងទិន្នន័យហានិភ័យគយ

ការគ្រប់គ្រងហានិភ័យគយ ការអនុវត្តនីតិវិធីក្នុងការត្រួតពិនិត្យរូបវន្តលើទំនិញនាំចេញនាំចូល បានជួបប្រទះនូវបញ្ហាអសកម្ម និងការមិនយល់គ្នាជាច្រើន ជាពិសេសពាក់ព័ន្ធនឹងការសម្រួលបែបបទបញ្ចេញទំនិញពីគយ។ ក្នុងន័យនេះ, ប្រព័ន្ធគ្រប់គ្រងទិន្នន័យហានិភ័យគយ (CRMDS) ដែលជាប្រព័ន្ធនៅដាច់ដោយឡែកពីប្រព័ន្ធអាស៊ីគូដាបានដាក់ឱ្យអនុវត្ត ដែលមានមុខងារចាត់ថ្នាក់ច្រកប្រព្រឹត្តិកម្មប្រតិវេទន៍គយទៅតាមកម្រិតហានិភ័យ ជាច្រកប្រព្រឹត្តិកម្ម ពណ៌ក្រហម, លឿង, ខៀវ, និង បៃតង ។ លក្ខណៈពិសេស នៃប្រព័ន្ធ CRMDS អាចចាត់ថ្នាក់ច្រកពណ៌ប្រព្រឹត្តិកម្មក្រហមទៅជា៤កម្រិត ស្របតាមកម្រិតហានិភ័យខ្ពស់របស់ប្រតិវេទន៍គយនីមួយៗ រួមមាន៖ ក្រហមកម្រិតទី១, ទី២, ទី៣, និងទី៤។ បច្ចុប្បន្ននេះ ប្រព័ន្ធ CRMDS កំពុងដាក់ឱ្យប្រើប្រាស់នៅតាមសាខា និងការិយាល័យគយនិងរដ្ឋាករបំពេញបែបបទសំខាន់ៗចំនួន១០កន្លែងទូទាំងប្រទេស។

### ❹. ប្រព័ន្ធផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ

ប្រព័ន្ធទិន្នន័យប្រតិវេទន៍តម្លៃគិតពន្ធគយ (CVDS) គឺជាការអភិវឌ្ឍជំនាន់ថ្មីនៃប្រព័ន្ធ CVSS ដែលជាប្រព័ន្ធជំនួយដល់មន្ត្រីតម្លៃគិតពន្ធគយក្នុងការស្វែងរកទិន្នន័យតម្លៃពិចារណារបស់ទំនិញនានា និងទិន្នន័យប្រតិវេទន៍តម្លៃដែលធ្លាប់បានឯកភាពពីមុនមក។ ប្រព័ន្ធ CVDS នេះ ត្រូវបានអភិវឌ្ឍឡើងដើម្បីផ្តល់កិច្ចសម្រួលពាណិជ្ជកម្មបន្ថែមទៀតដល់ប្រតិវេទករ ក៏ដូចជាដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងប្រតិវេទន៍តម្លៃគិតពន្ធគយ តាមរយៈមុខងារដាក់ស្នើ និងបោះពុម្ពប្រតិវេទន៍តម្លៃគិតពន្ធគយ, មុខងាររក្សាទុកវិញ្ញាបនបត្រចុះបញ្ជីពន្ធដារនិងពន្ធប៉ាតង់ប្រចាំឆ្នាំ, មុខងារកំណត់លំហូរនីតិវិធីផ្ទៃក្នុងរបស់មន្ត្រីមានសមត្ថកិច្ច, មុខងារបោះពុម្ពកំណត់បង្ហាញមតិរបស់មន្ត្រី, មុខងារចុះបញ្ជិកាលេខចេញ និងធ្វើការរក្សាទុកប្រតិវេទន៍តម្លៃគិតពន្ធគយដែលបានសម្រេចរួចក្នុងទម្រង់អេឡិចត្រូនិកជាដើម។

ជាការសន្និដ្ឋាន, ដើម្បីឆ្លុះបញ្ចាំង និងវាស់វែងប្រសិទ្ធភាព **អ.គ.រ.** បានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី, អង្គការគយពិភពលោក, និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន បានធ្វើការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញពីគយកាលពីឆ្នាំ២០១៣ ដែលលទ្ធផលបង្ហាញថារយៈពេលបំពេញបែបបទគយត្រឹម ១ម៉ោង ៥៧នាទី។ ស្របតាមកំណើនទំហំពាណិជ្ជកម្មរបស់កម្ពុជា គួរឱ្យកត់សម្គាល់ គឺការនាំចេញមានការកើនឡើងប្រមាណ៨៥% និងការនាំចូលមានកំណើនប្រមាណ៨១% យោងតាមរបាយការណ៍ទិន្នន័យរបស់អាស៊ាន ក្នុងឆ្នាំ២០១៤ ធៀបជាមួយទិន្នន័យឆ្នាំ២០១៨, នៅឆ្នាំ២០១៩ **អ.គ.រ.** បានធ្វើការសិក្សារយៈពេលបំពេញបែបបទបញ្ចេញទំនិញពីគយបានថយចុះជាមធ្យមប្រហែលជា ៥២នាទី ពី ១ម៉ោង ៥៧នាទី នៅឆ្នាំ២០១៣ មកនៅត្រឹម



ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា




១ម៉ោង ០៥នាទី។

ទោះជាមានវឌ្ឍនភាពគួរឱ្យកត់សំគាល់, ក៏ **អ.គ.រ.** នៅមានកិច្ចការជាច្រើនទៀត ដែលត្រូវអនុវត្តបន្តសំដៅសម្រួលឱ្យបាន ជាអតិបរមានីតិវិធីបំពេញបែបបទគយ, ពង្រីកបន្ថែមការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិ-កម្មគយទៅប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួង-ស្ថាប័នជំនាញ, និងត្រូវប្រកាន់យកអភិក្រមគ្រប់គ្រងតាមបែបបុរេសកម្ម ដែលឆ្លុះបញ្ចាំងអំពីឆន្ទៈដ៏មោះមុតនូវសារនយោបាយជាយុទ្ធសាស្ត្ររបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** គឺ “**បើកែទម្រង់គឺរស់, តែបើមិនកែទម្រង់ គឺស្លាប់**” ក្នុងគោលបំណងឈានទៅសម្រេចបាននូវចក្ខុវិស័យ និងបេសកកម្មរបស់ **អ.គ.រ.** ក្នុងការអភិវឌ្ឍខ្លួន ឱ្យក្លាយជារដ្ឋបាលគយទំនើបឈានមុខ និងរក្សាបាននូវសង្គតិភាពនឹងបទប្បញ្ញត្តិ និងគោលនយោបាយរបស់រាជរដ្ឋាភិបាលការអនុវត្តល្អជាអន្តរជាតិ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការធុរកិច្ច៕■

*រៀបចំដោយ÷ ផ្នែកចំណូលសារពើពន្ធ នៃ អ.គ.ហ. និងក្រុមការងារកែទម្រង់ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា*

# វិធីសាស្ត្រអនុវត្តការប្រមូលពន្ធលើចំណេញមូលធន

*ស្របតាមយុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣ ដើម្បីធានាបានចីរភាពនៃកំណើនចំណូល ចីរភាពនៃកំណើនសេដ្ឋកិច្ច, ការប្រកួតប្រជែងដោយស្មើភាព និងសមធមិសង្គម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសម្រេចដាក់ចេញនូវវិធាន និងនីតិវិធីគ្រប់គ្រងប្រមូលពន្ធលើចំណេញមូលធន តាមរយៈប្រកាសលេខ ៣៤៦.សហវ.ប្រក. ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០។*

ពន្ធនេះ មិនមែនជាប្រភេទពន្ធទើបត្រូវបានបង្កើតថ្មីទេ គឺពន្ធនេះត្រូវបានកំណត់ឱ្យប្រមូលដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលបានធ្វើវិសោធនកម្ម មាត្រា ៧ នៃច្បាប់ស្តីពីសារពើពន្ធទៅជាមាត្រា ៧ ថ្មី និងត្រូវបានធ្វើវិសោធនកម្មម្តងទៀតដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ទៅជាមាត្រា ៧ ថ្មី (មួយ) ដោយបានចែងថា "ប្រាក់ចំណូលជាប់ពន្ធគឺជាប្រាក់ចំណូលសុទ្ធដែលសម្រេចបានពីសកម្មភាពអាជីវកម្ម និងសកម្មភាពនានាក្រៅពីអាជីវកម្មរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល។ ជាមួយគ្នានេះ, ប្រាក់ចំណូលជាប់ពន្ធក៏រួមបញ្ចូលទាំងចំណេញមូលធន, ការប្រាក់, ថ្លៃឈ្នួល, សួយសារ ព្រមទាំងចំណូលពីទ្រព្យហិរញ្ញវត្ថុ ឬទ្រព្យវិនិយោគ រាប់ទាំងអចលនទ្រព្យផង"។

មុននឹងដាក់ចេញនូវគោលនយោបាយអនុវត្តពន្ធលើចំណេញមូលធន (Capital Gain Tax) រដ្ឋបាលសារពើពន្ធបានសិក្សាលើការអនុវត្តពីបណ្តាប្រទេសជិតខាងនានា ទាំងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍរួមមាន÷ ប្រទេសសឹង្ហបុរី, ហុងកុង, ម៉ាឡេស៊ី, វៀតណាម, មីយ៉ាន់ម៉ា, ឥណ្ឌា, ហ្វីលីពីន, អូស្ត្រាលី, ថៃ, ស៊ុយអ៊ែត, កូរ៉េខាងត្បូង ដើម្បីជាមូលដ្ឋានក្នុងការរៀបចំបទប្បញ្ញត្តិឱ្យស្របទៅនឹងបរិបទកម្ពុជា។

ប្រកាសស្តីពីពន្ធលើចំណេញមូលធននេះមានវិសាលភាពកំណត់ការយកពន្ធលើចំណេញមូលធនចំពោះតែរូបវន្តបុគ្គលនិវាសនជន និងអនិវាសនជន ព្រមទាំងនីតិបុគ្គលអនិវាសនជនតាមអត្រា២០% នៃចំណេញមូលធនពីការលក់ ឬផ្ទេរមូលធនរួមមាន÷ អចលនទ្រព្យ, ភតិសន្យា, ទ្រព្យវិនិយោគ, កេរ្តិ៍ឈ្មោះ, អាជីវកម្ម, កម្មសិទ្ធិ






បញ្ញា និងរូបិយប័ណ្ណបរទេស ។ រីឯនីតិបុគ្គលនិវាសនជនដែលបានចុះបញ្ជីពន្ធដារ និងប្រកាសបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរួចរាល់ មិនមានបន្ទុកពន្ធនេះបន្ថែមទៀតទេ ដូចជា ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅ-

ឋានជាដើម។ ពន្ធលើចំណេញមូលធននេះប្រមូលលើចំណេញមូលធនដែលសម្រេចបាននៅពេលមានប្រតិបត្តិការលក់ ឬផ្ទេរមូលធនដែលមានប្រាក់ចំណេញតែប៉ុណ្ណោះ បើមិនមានចំណេញទេពុំមានកាតព្វកិច្ចបង់ពន្ធនោះទេ។

លើសពីនេះ, ការគណនាប្រាក់ពន្ធលើចំណេញមូលធន គឺយកចំណេញមូលធន (ចំណូលពីការលក់ ឬផ្ទេរមូលធន ដកការកាត់កងចំណាយដែលអនុញ្ញាត) គុណនឹងអត្រា ២០%។ ចំពោះមូលធនជាអចលនទ្រព្យ អ្នកជាប់ពន្ធអាចជ្រើសរើសវិធាននៃការកាត់កងចំណាយចំនួនពីរ គឺ÷

❶.វិធីកាត់កងចំណាយតាមការកំណត់គឺអនុញ្ញាតឱ្យកាត់កងចំណាយ ៨០% នៃប្រាក់ចំណូលពីការលក់ ឬផ្ទេរអចលនទ្រព្យ ឬ

❷.វិធីកាត់កងតាមចំណាយជាក់ស្តែងគឺត្រូវបានអនុញ្ញាត ឱ្យធ្វើការកាត់កងចំណាយ ដែលបានកើតឡើងជាក់ស្តែង



ដោយមានវិក្កយបត្រ ឬឯកសារភស្តុតាងបញ្ជាក់អំពីហេតុការណ៍ និងលទ្ធផលនៃសកម្មភាពសេដ្ឋកិច្ច ដែលទាក់ទិននឹងបន្ទុកចំណាយ និងចំនួនទឹកប្រាក់ដែលបានចំណាយ។ ចំពោះមូលធនដទៃទៀត អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយ តែតាមវិធីកាត់កងតាមចំណាយជាក់ស្តែងប៉ុណ្ណោះ។

**ឧទាហរណ៍,** លោក“ **ក**” ជាអ្នកជាប់ពន្ធនិវាសនជន ទទួលបានចំណេញមូលធនពីការលក់ផ្ទះល្វែងចំនួន ៣៤០ ០០០ ០០០ រៀល។

| | |
|---|---|
| **ពន្ធលើចំណេញមូលធន** | = ចំណេញមូលធន អត្រាថេរ x ២០% |
| | = ៣៤០ ០០០ ០០០ x ២០% |
| | = ៦៨ ០០០ ០០០រៀល |

**ឧទាហរណ៍,** លោក“ **ខ**” ជាអ្នកជាប់ពន្ធអនិវាសនជនទទួលបានចំណេញមូលធនពីការលក់ភាគហ៊ុនក្នុងក្រុមហ៊ុននៅព្រះរាជាណាចក្រកម្ពុជាចំនួន ៤០០ ០០០ ០០០ រៀល។

| | |
|---|---|
| **ពន្ធលើចំណេញមូលធន** | = ចំណេញមូលធន x អត្រាថេរ ២០% |
| | = ៤០០ ០០០ ០០០ x ២០% |
| | = ៨០ ០០០ ០០០រៀល |

ពន្ធលើចំណេញមូលធនត្រូវបានលើកលែងចំពោះការលក់ ឬផ្ទេរមូលធនមួយចំនួនរួមមាន÷

①.ទ្រព្យដែលជាកម្មសិទ្ធិរបស់ស្ថាប័នរដ្ឋ

②.ទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃ

③.និវាសនដ្ឋានជាគោលដើម របស់អ្នកជាប់ពន្ធ ដែលបានកាន់កាប់ក្នុងរយៈពេលយ៉ាងតិចប្រាំ (៥) ឆ្នាំមុនពេលលក់ ឬផ្ទេរ។ ក្នុងករណីមាននិវាសនដ្ឋានច្រើនជាងមួយ ឬអ្នកជាប់ពន្ធនិងសហព័ទ្ធមាននិវាសនដ្ឋានផ្សេងពីគ្នា និវាសនដ្ឋានតែមួយប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតជានិវាសនដ្ឋានជាគោលដើម

④.អចលនទ្រព្យក្នុងរង្វង់ញាតិដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធប្រថាប់ត្រា វៀរលែងតែការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត រវាងឪពុក-ម្តាយក្មេកនិងកូនប្រសា និងរវាងយាយ-តាក្មេកនិងចៅប្រសា

⑤.ទ្រព្យដែលត្រូវបានលក់ ឬផ្ទេរដើម្បីប្រយោជន៍សាធារណៈ ស្របតាមច្បាប់ស្តីពីអស្សាមិករណ៍ (អស្សាមិករណ៍សំគាល់ ដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់ រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈរួមមាន ដីសំណង់ និងដំណាំដាំដុះ សម្រាប់ដំណើរការស្ថាបនាស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបំរើផលប្រយោជន៍សាធាណៈ និងផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និងយុត្តិធម៌)។ បន្ថែមលើនេះ, រាជរដ្ឋាភិបាលក៏បានសម្រេចលើកលែងពន្ធលើចំណេញមូលធនចំពោះការលក់ ឬផ្ទេរប្រភេទដីកសិកម្មជាកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់របស់ប្រជាពលរដ្ឋដែលជាកសិករកំពុងបង្កបង្កើនផលពិតប្រាកដ និងមានលំនៅឋានស្ថិតនៅ ក្នុងឃុំ/សង្កាត់ ដែលដីកសិកម្មនោះស្ថិតនៅ ។

អ្នកជាប់ពន្ធ ត្រូវដាក់លិខិតប្រកាសពន្ធតាមទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធ និងបង់ពន្ធលើចំណេញមូលធនតាមប្រតិបត្តិការនីមួយៗជូនរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេលមិនលើសពី០៣ខែ បន្ទាប់ពីសម្រេចបានចំណេញមូលធន។ ចំពោះទ្រព្យដែលស្ថិតនៅរាជធានីភ្នំពេញ អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ។ ដោយឡែកទ្រព្យដែលស្ថិតនៅតាមបណ្តាខេត្ត អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាស និងបង់

ពន្ធនៅសាខាពន្ធដារខេត្តដែលទ្រព្យស្ថិតនៅ ឬនៅអគ្គនាយកដ្ឋានពន្ធដារតាមការស្នើសុំរបស់អ្នកជាប់ពន្ធ។ ក្នុងករណីមិនបានដាក់លិខិតប្រកាស និងបង់ពន្ធតាមពេលកំណត់ អ្នកជាប់ពន្ធត្រូវទទួលរងនូវទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធជាធរមាន។

***សេចក្តីសន្និដ្ឋាន,***

អគ្គនាយកដ្ឋានពន្ធដារត្រៀមអនុវត្តប្រមូលពន្ធលើចំណេញមូលធន និងបានរៀបចំរួចជាស្រេចដោយផ្តោតចំណុចសំខាន់ ០៣ រួមមាន÷ ១). ការរៀបចំផែនការផ្សព្វផ្សាយ និងណែនាំបទប្បញ្ញត្តិស្តីពីពន្ធលើចំណេញមូលធន ឱ្យបានទូលំទូលាយដល់សាធារណជន និងអ្នកជាប់ពន្ធមានជាអាទិ៍÷ ផ្សព្វផ្សាយប្រកាសស្តីពីពន្ធលើចំណេញមូលធន តាមរយៈគេហទំព័រ (www.tax.gov.kh) និងបណ្តាញទំនាក់ទំនងសង្គម (Facebook) នៃអគ្គនាយកដ្ឋានពន្ធដារ និងបណ្តាញព័ត៌មានផ្សេងៗ, វីដេអូឃ្លីបពាក់ព័ន្ធនឹងការបង់ពន្ធលើចំណេញមូលធន, ផ្សាយផ្ទាល់កម្មវិធីពន្ធដារ (GDT Live Show) និងវេទិកាសំណួរ-ចម្លើយ តាមរយៈ Live Chat និង Call Center, រៀបចំសេចក្តីណែនាំបន្ថែមស្តីពីការដាក់លិខិតប្រកាស និងបង់ពន្ធលើចំណេញមូលធន, រៀបចំកម្មវិធីសិក្ខាសាលាជូនដល់អ្នកជាប់ពន្ធ និងអាជ្ញាធរពាក់ព័ន្ធនៅតាមរាជធានី-ខេត្ត, បញ្ចូលមេរៀនស្តីពីពន្ធលើចំណេញមូលធនក្នុងកម្មវិធីវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារនៅសាលាជាតិពន្ធដារ។ ២). ការពង្រឹងសមត្ថភាពមន្ត្រី តាមរយៈកម្មវិធីបណ្តុះបណ្តាល និងរៀបចំលំហូរការងារ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងប្រមូលពន្ធ។ ៣). ការពង្រឹងការអនុវត្តច្បាប់ សម្រាប់អ្នកជាប់ពន្ធបំពេញ

*ពន្ធលើចំណេញមូលធននេះ ប្រមូលលើចំណេញមូលធន ដែលសម្រេចបាននៅពេលមានប្រតិបត្តិការលក់ ឬផ្ទេរមូលធន ដែលមានប្រាក់ចំណេញតែប៉ុណ្ណោះ។ បើមិនមានចំណេញទេ ពុំមានកាតព្វកិច្ចបង់ពន្ធនោះទេ។*

អនុលោមភាពតាមច្បាប់ដោយស្មើភាពគ្នាតាមរយៈយន្តការត្រួតពិនិត្យឡើងវិញនូវមូលដ្ឋានគិតពន្ធ និងប្រាក់ពន្ធត្រូវបង់ ក្នុងករណី ដែលអ្នកជាប់ពន្ធមិនផ្តល់ឯកសារពាក់ព័ន្ធត្រឹមត្រូវ។

ការអនុវត្តប្រមូលពន្ធ លើចំណេញមូលធននេះត្រូវបានរាជរដ្ឋាភិបាលសម្រេចពន្យារពេលរហូតដល់ដំណាច់ឆ្នាំ ២០២១ ដោយចាប់ផ្តើមប្រមូលពន្ធនេះពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ ៕■




*គេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ÷ www.tax.gov.kh*

*រៀបចំដោយ÷ ផ្នែកចំណូលសារពើពន្ធនៃ អ.គ.ហ. និងក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានពន្ធដារ*

# ដំណើរឆ្ពោះទៅរកការបោះផ្សាយមូលបត្ររដ្ឋនៅកម្ពុជា

*ច្បាប់ថ្មីស្តីពីមូលបត្ររដ្ឋ ដែលត្រូវបានអនុម័តដោយរដ្ឋសភា កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ដើម្បីជំនួសឱ្យច្បាប់ចាស់ ដែលបានចូលជាធរមាន តាំងពីឆ្នាំ២០០៧ រហូតមកដល់ពេលបច្ចុប្បន្ន ក្នុងគោលបំណងត្រួសត្រាយផ្លូវធ្វើការបោះផ្សាយមូលបត្ររដ្ឋ។*




*រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា*

ការអនុម័តច្បាប់ថ្មីនេះ ដោយរដ្ឋសភា គឺដើម្បីកៀរគរហិរញ្ញប្បទានក្នុងស្រុក និងធ្វើពិពិធកម្មប្រភពទុនរបស់រដ្ឋ ដែលអាចឆ្លើយតបនឹងតម្រូវការជាក់ស្តែងនៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ជាមួយគ្នានេះ ដោយពិនិត្យឃើញនូវបញ្ហាប្រឈមពីកត្តាខាងក្នុង និងខាងក្រៅមួយចំនួន ដែលអាចមានផលប៉ះពាល់ជាយថាហេតុលើស្ថានភាពបំណុលសាធារណៈ ជាមួយនឹងគោលដៅនៃការធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានស្របតាមភាពរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា ព្រមទាំងចក្ខុវិស័យមុតស្រួចរបស់រាជរដ្ឋាភិបាលឆ្ពោះទៅរកការប្រែក្លាយពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប (Lower-middle income country) ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ (Upper-middle income country) នៅឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់ (High income country) នៅឆ្នាំ២០៥០។ ការចាប់ផ្តើមសាកល្បងបោះផ្សាយមូលបត្ររដ្ឋ ដើម្បីកៀរគរទុនពីផ្សារមូលបត្រក្នុង និងក្រៅប្រទេស មកបំពេញសេចក្តីត្រូវការធនធាន និងហិរញ្ញប្បទានបានក្លាយជាកាលានុវត្តភាព និងអាទិភាពថ្មីសម្រាប់កម្ពុជា។

ទន្ទឹមនេះ, ច្បាប់ថ្មីនេះជាមូលដ្ឋានគតិយុត្តដែលអាចអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើការបោះផ្សាយមូលបត្រតាមរយៈការកំណត់នូវវិសាលភាព, ការសម្រេចលើការបោះផ្សាយ, ការកំណត់ទំហំ, ទម្រង់នៃការបោះផ្សាយ, អ្នកចូលរួមក្នុងទីផ្សារដំបូង, វិធីសាស្ត្រ, បែបបទ និងដំណើរការនៃការបោះផ្សាយ, គណនីគ្រប់គ្រង, សិទ្ធិរបស់អ្នកកាន់កាប់ ព្រមទាំងទោសប្បញ្ញត្តិជាដើម។

ច្បាប់ថ្មីនេះមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតបខ្ពស់ទៅនឹងបរិការណ៍បច្ចុប្បន្ន និងនិន្នាការប្រែប្រួល នៃការអភិវឌ្ឍរបស់កម្ពុជា តាមរយៈការកំណត់នូវក្របខ័ណ្ឌរួម សម្រាប់គ្រប់គ្រងការបោះផ្សាយ, ការជួញដូរ និងការគ្រប់គ្រងមូលបត្ររដ្ឋរួមទាំងការកំណត់នូវគោលបំណងជាក់លាក់ក្នុងការឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទានជាពិសេស សម្រាប់អភិវឌ្ឍហេដ្ឋារចនា-



*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងកិច្ចប្រជុំរដ្ឋសភា លើកទី៥ នីតិកាលទី៦ ថ្ងៃទី២៥ វិច្ឆិកា ឆ្នាំ២០២០*

សម្ព័ន្ធ, ការពង្រឹងការគ្រប់គ្រងតម្រូវការសាច់ប្រាក់, ការអភិវឌ្ឍវិស័យមូលបត្រ និងហិរញ្ញវត្ថុ និងការគាំទ្រគម្រោងអាទិភាពព្រមទាំងភាពចាំបាច់នានាតាមរយៈយន្តការកៀរគរហិរញ្ញប្បទានបន្ថែមពីវិស័យឯកជនជាជាងការពឹងផ្អែកទៅលើការផ្តល់ជំនួយបរទេសទាំងស្រុង ដែលមានហានិភ័យខ្ពស់។ ច្បាប់ថ្មីនេះ មានវិសាលភាពអនុវត្តចំពោះការបោះផ្សាយ ការជួញដូរ និងការគ្រប់គ្រងមូលបត្ររដ្ឋ ដែលបោះផ្សាយទាំងក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា។ ការបោះផ្សាយមូលបត្ររដ្ឋ ជាសិទ្ធិអំណាចផ្តាច់មុខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្រោមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ [១]។ ទន្ទឹមនេះ មាត្រា៦៧នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ក៏បានបញ្ជាក់ដែរថាស្ថិតក្រោមកម្រិតកំណត់នៃច្បាប់ហិរញ្ញវត្ថុ និងក្រោមអំណាចរបស់នាយករដ្ឋមន្ត្រី មានតែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែមួយគត់ ដែលមានសិទ្ធិក្នុងការខ្ចីប្រាក់ពីគេ, ការបោះផ្សាយមូលបត្ររដ្ឋ, ការទទួលហិរញ្ញប្បទានឥតសំណង, ការវិនិយោគលើអចលនកម្មហិរញ្ញវត្ថុ, ការធានា និងការសន្យាផ្នែកហិរញ្ញវត្ថុនានា ហើយមានសិទ្ធិក្នុងការឱ្យប្រាក់គេខ្ចីទាំងក្នុងប្រទេស និងក្រៅប្រទេស។ ដូចនេះ ច្បាប់ថ្មីនេះគឺបានផ្តល់សិទ្ធិអំណាច តាមរយៈការចាត់ឱ្យមានការបោះផ្សាយលក់មូលបត្ររដ្ឋនេះផងដែរ។

គួរគូសបញ្ជាក់ផងដែរថា នៅឆ្នាំ១៩៩៣ ដែលជាឆ្នាំដំបូងនៃការចាប់ផ្តើមខ្ចីឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍នៅក្រៅប្រទេស



**ព្រះរាជក្រម**

នស/រកម/១២២០/០៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីមូលបត្ររដ្ឋ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE ព្រះបរមរាជវាំង REGISTRE DU PALAIS ROYAL

១/៧

*ច្បាប់ថ្មីនេះមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតបខ្ពស់ទៅនឹងបរិការណ៍បច្ចុប្បន្ន និងនិន្នាការប្រែប្រួលនៃការអភិវឌ្ឍរបស់កម្ពុជា តាមរយៈការកំណត់នូវក្របខ័ណ្ឌរួម សម្រាប់គ្រប់គ្រងការបោះផ្សាយ, ការជួញដូរ និងការគ្រប់គ្រងមូលបត្ររដ្ឋ និងការកំណត់នូវគោលបំណងជាក់លាក់ក្នុងការឆ្លើយតបទៅនឹងតម្រូវការហិរញ្ញប្បទាន ជាពិសេសសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, ការពង្រឹងការគ្រប់គ្រងតម្រូវការសាច់ប្រាក់, ការអភិវឌ្ឍន៍វិស័យមូលបត្រ និងហិរញ្ញវត្ថុ*

មកការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាល គឺមានភាពប្រយ័ត្នប្រយែង ច្បាស់លាស់ និងម៉ត់ចត់ ដោយផ្អែកលើគោលការណ៍គន្លឹះ មានចំនួន៤ ដូចជា[២]៖

- ខ្ចីឥណទានក្នុងទំហំសមស្រប ដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន
- ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬ លក្ខខណ្ឌអនុគ្រោះខ្ពស់
- ខ្ចីសម្រាប់វិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ច និងវិស័យផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម
- ប្រើប្រាស់ឥណទានប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់បំផុត។

ច្បាប់មូលបត្ររដ្ឋ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ និង ឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទ **នរោត្តម សីហមុនី** កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០៕■

*រៀបចំដោយ៖ ផ្នែកអនុវត្តថវិកានៃ អ.គ.ហ.*

---

*[១] មាត្រា៣៨ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨ ចែងថា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងចំណូលចំណាយ ការខ្ចី ការឱ្យខ្ចី និងការធានារបស់រដ្ឋ ដែលត្រូវបានអនុញ្ញាតដោយច្បាប់។*

*[២] ឈរលើគោលការណ៍គន្លឹះទាំង៤ នេះ, រាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ចំនួន៣លើក គឺ៖ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១១-២០១៨, យុទ្ធសាស្ត្របច្ចុប្បន្នកម្មស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៥-២០១៨, និងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៩-២០២៣។*

# ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការថវិកា

*នៅក្នុងដំណើរការនៃការលើកកម្ពស់អភិបាលកិច្ចថ្នាក់មូលដ្ឋាន, ការចូលរួមរបស់ប្រជាពលរដ្ឋអាចត្រូវបានចាត់ទុកថា ជាយន្តការ ឬជាឧបករណ៍មួយដ៏សំខាន់ ក្នុងការជំរុញការផ្តល់សេវាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព និងភាពឆ្លើយតប។*

## *ហេតុអ្វីបានជាការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការថវិកាមានសារសំខាន់?*

ការចូលរួមរបស់ប្រជាពលរដ្ឋពិតជាមានសារសំខាន់ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការពង្រឹងសមិទ្ធកម្ម និងគណនេយ្យភាពនៃការិយាល័យធិបតេយ្យ។ ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាដំណើរការចូលរួមក្នុងដំណាក់កាលនីមួយៗ នៃដំណើរការថវិការួមមានការវិភាជធនធាន, ការរៀបចំថវិកា, និងការវាយតម្លៃថវិកា។ រាជរដ្ឋាភិបាល គឺជាតួអង្គដ៏សំខាន់ក្នុងការជំរុញ និងលើកកម្ពស់ ឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន។

ការចូលរួមរបស់ប្រជាពលរដ្ឋ ដែលអាចនិយាយបានថា ជាសិទ្ធិ, កាតព្វកិច្ច, ករណីកិច្ច, និងជាកម្លាំងចលករក្នុងការពង្រឹងអភិបាលកិច្ចល្អ ក៏ដូចជាការគាំទ្រដល់ដំណើរការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច-សង្គមឱ្យកាន់តែរីកចម្រើន និងរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ អាចនិយាយម្យ៉ាងទៀតបានថា ការចូលរួមរបស់ប្រជាពលរដ្ឋ អាចជួយធ្វើឱ្យគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈកាន់តែប្រសើរឡើង តាមរយៈការតាមដានការអនុវត្តគម្រោងនានា ដែលប្រើប្រាស់ថវិកាសម្រាប់អភិវឌ្ឍថ្នាក់មូលដ្ឋាន។

*ប្រជាពលរដ្ឋអាចចូលរួមពិគ្រោះយោបល់, ពិនិត្យ និងតាមដានចំណូល និងចំណាយ, ចូលរួមពិភាក្សាគម្រោងអភិវឌ្ឍ និងចូលរួមពិនិត្យ និងតាមដានការអនុវត្តគម្រោងថ្នាក់មូលដ្ឋាន ដើម្បីឱ្យមានការឆ្លើយតបទៅនឹងតម្រូវការរបស់ខ្លួន។*



*ប្រភព៖ អង្គការផែក កម្ពុជា*




*ប្រភព÷ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*

ក្នុងន័យនេះ, ប្រជាពលរដ្ឋអាចចូលរួមពិគ្រោះយោបល់, ពិនិត្យ និងតាមដានចំណូលចំណាយ, ចូលរួមពិភាក្សាគម្រោងអភិវឌ្ឍន៍ និងចូលរួមពិនិត្យ តាមដានការអនុវត្តគម្រោងថ្នាក់មូលដ្ឋានដើម្បីឱ្យមានការឆ្លើយតបទៅនឹងតម្រូវការ រួមទាំងភាពចាំបាច់របស់ខ្លួន។

មាត្រា១១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានចែងពីគោលការណ៍សំខាន់ៗ នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលក្នុងនោះ ក៏បានបញ្ជាក់ពីការពិគ្រោះយោបល់ការចូលរួម, ការឆ្លើយតប និងគណនេយ្យភាពជាដើម ដែលជាសមាសភាពដ៏សំខាន់ ក្នុងការជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋាន និងជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

ជាមួយគ្នានេះ, ថវិកាប្រជាពលរដ្ឋ (Citizen Budget) ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ជាព័ត៌មានហិរញ្ញវត្ថុសាធារណៈ ចំពោះសាធារណជនទូទៅ ហើយប្រជាពលរដ្ឋអាចយល់ដឹងពីថវិកា ដែលមានឥទ្ធិពលលើជីវិតរស់នៅប្រចាំថ្ងៃ របស់ពួកគេ។ ហេតុដូច្នេះ, ថវិកាប្រជាពលរដ្ឋបានជំរុញ ឱ្យមានការយល់ដឹងពីថវិកាសាធារណៈ។ ថវិកាប្រជាពលរដ្ឋជាច្រកឆ្ពោះទៅរកព័ត៌មានបន្ថែម និងបង្ហាញប្រជាពលរដ្ឋឱ្យដឹងនូវអ្វីដែលពួកគេចាំបាច់ត្រូវចូលរួម និងធ្វើឱ្យរាជរដ្ឋាភិបាលកាន់តែមានគណនេយ្យភាពក្នុងការគ្រប់គ្រងថវិកាសាធារណៈ ដើម្បីប្រសិទ្ធភាពនៃការផ្តល់សេវាធារណៈជូនប្រជាពលរដ្ឋផ្ទាល់។

*ថវិកាប្រជាពលរដ្ឋ (Citizen Budget) ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ជាព័ត៌មានហិរញ្ញវត្ថុសាធារណៈចំពោះសាធារណជនទូទៅ ហើយប្រជាពលរដ្ឋអាចយល់ដឹងពីថវិកា ដែលមានឥទ្ធិពលលើជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ ហេតុដូចនេះ, ថវិកាប្រជាពលរដ្ឋបានជំរុញ ឱ្យមានការយល់ដឹងពីថវិកាសាធារណៈ។*

ថវិកាប្រជាពលរដ្ឋក៏រួមបញ្ចូលផងដែរនូវព័ត៌មានអំពីការរៀបចំ និងអនុវត្តថវិកា និងអ្នកទទួលខុសត្រូវនៅក្នុងដំណាក់កាលនីមួយៗ។ លើសពីនេះ, ថវិកាប្រជាពលរដ្ឋអាចបង្ហាញពីគោលនយោបាយរបស់រាជរដ្ឋាភិបាលនៅក្នុងវិស័យជាក់លាក់ដូចជាវិស័យអប់រំ, វិស័យសុខាភិបាល, និងបញ្ជាក់ពីកម្រិតរដ្ឋបាល (ថ្នាក់ជាតិ, ថ្នាក់ក្រោមជាតិ) ដែលទទួលខុសត្រូវក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ។

ថវិកាប្រជាពលរដ្ឋត្រូវបង្ហាញព័ត៌មានអំពីថវិកាឱ្យបានច្បាស់លាស់ និងងាយយល់ជូនប្រជាពលរដ្ឋ។ រដ្ឋាភិបាលប្រើប្រាស់ថវិកាប្រជាពលរដ្ឋ ដើម្បីផ្សារភ្ជាប់ជាមួយប្រជាពលរដ្ឋ នៅក្នុងដំណើរការថវិកា។ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំ និងអនុវត្តថវិកា ជាការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋបាលក្នុងពេលបំពេញការងាររបស់ខ្លួន ដែលការណ៍នេះក៏ជាទិសដៅការងារកែទម្រង់ ដែលមានភាពប្រទាក់ក្រឡាគ្នារបស់រដ្ឋាភិបាលផងដែរ៕■

*រៀបចំដោយ÷ ផ្នែកអនុវត្តថវិកានៃ អ.គ.ហ.*

# អភិបាលកិច្ចនៃសាលាបឋមសិក្សាវត្តបូព៌

*យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួន គឺបន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយមាន “**អភិបាលកិច្ចល្អ**” ជាស្នូលនៃយុទ្ធសាស្ត្រ។ ក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ “**អភិបាលកិច្ចល្អ**” ត្រូវបានកំណត់ថាជា គោលដៅនៃការទម្រង់រដ្ឋបាលសាធារណៈ ដោយផ្តោតលើការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័នសាធារណៈ ជាពិសេសគឺការពង្រឹងសមត្ថភាពលើភាពជាអ្នកដឹកនាំរបស់ថ្នាក់ដឹកនាំអង្គភាពក្នុងរដ្ឋបាលសាធារណៈ ដើម្បីប្រសិទ្ធភាពស្ថាប័នសាធារណៈ។*

សាលាបឋមសិក្សាវត្តបូព៌ មានលេខកូដ ១៧១០០៤០១០១៩ ស្ថិតនៅក្នុងភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ត្រូវបានបើកជាសាលាបឋមសិក្សាពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា២០១៧-២០១៨ ដោយប្រកាសលេខ ៨២៦ អយក.ប្រក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបើកសាលាបឋមសិក្សាវត្តបូព៌ ជាសាលាបឋមសិក្សាពេញលក្ខណៈ។ បច្ចុប្បន្ន ស្ថិតក្រោមការដឹកនាំរបស់លោកនាយក **ពិង គិមឆេន** សាលាបឋមសិក្សាវត្តបូព៌ បានធ្វើកំណែទម្រង់ការដឹកនាំ និងការគ្រប់គ្រងរបស់ខ្លួនជាបន្តបន្ទាប់ រហូតទទួលបានការចូលរួមយ៉ាងសកម្មពីលោកគ្រូ អ្នកគ្រូ សិស្ស និងសហគមន៍ ដែលជាតួអង្គគន្លឹះយ៉ាងសំខាន់ក្នុងការអភិវឌ្ឍនិងកំណែទម្រង់សាលាបឋមសិក្សាវត្តបូព៌។

សាលាបឋមសិក្សាវត្តបូព៌ មានចក្ខុវិស័យមុតស្រួច និងច្បាស់លាស់ គឺ “**បណ្តុះគ្រាប់ពូជជាធនធានមនុស្សកម្រិតបឋមសិក្សាប្រកបដោយគុណភាពខ្ពស់ មានឥរិយាបថថ្លៃថ្នូរនិងសុខុមាលភាពល្អប្រសើរ ដើម្បីចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិ ឱ្យមានការរីកចម្រើនដូចបណ្តាប្រទេសក្នុងតំបន់និងពិភពលោក**”។ ទន្ទឹមនឹងនេះ សាលាបឋមសិក្សាវត្តបូព៌ មានយុទ្ធសាស្ត្រជាសរសរស្តម្ភ ចំនួន ៣ គឺ ÷ សាលារៀន សិស្សានុសិស្ស និងសហគមន៍។


*ទិដ្ឋភាពនាពេលព្រឹកគោរពទង់ជាតិ នៅសាលាបឋមសិក្សាវត្តបូព៌*

## ក. សាលារៀន

### ❶.រចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រង

សាលាបឋមសិក្សាវត្តបូព៌ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយនាយក ១ រូប អមដោយនាយករង ចំនួន ២ រូប និងលេខាធិការ ចំនួន ១ រូប។ ទន្ទឹមនេះ សាលាបឋមសិក្សាវត្តបូព៌ បានបង្កើតគណៈកម្មការទ្រទ្រង់សាលា ដែលតំណាងឱ្យសហគមន៍ក្នុងការសម្របសម្រួល និងអភិវឌ្ឍសាលារៀន ដើម្បីធានាប្រសិទ្ធភាពនៃការដឹកនាំ និងការអភិវឌ្ឍសាលា ប្រកបដោយភាពរលូនតម្លាភាព និងគណនេយ្យភាព។

គណៈកម្មការទ្រទ្រង់សាលារៀន មានភារកិច្ច ចូលរួមរៀបចំផែនការអភិវឌ្ឍសាលារៀន ស្វែងរកថវិកា ដើម្បីទ្រទ្រង់ការអភិវឌ្ឍសាលារៀន បំផុសចលនាមហាជន ចូលរួមគាំទ្រសាលារៀន និងចូលរួមគ្រប់កម្មវិធីរបស់សាលា តាមការអញ្ជើញរបស់គណៈគ្រប់គ្រងសាលា។

ទន្ទឹមនេះ រចនាសម្ព័ន្ធគ្រប់គ្រងសាលាបឋមសិក្សាវត្តបូព៌ ត្រូវបានចែកចេញ ជា ២ ក្រុមគឺ ក្រុមស្វយ័តទី១ និងក្រុមស្វយ័តទី២ ដោយក្រុមស្វយ័តទាំង ២ ត្រូវទទួលបន្ទុកលើការគ្រប់គ្រង និងការសម្របសម្រួលការបង្រៀន និងការរៀនសិក្សា ព្រមទាំងការប្រព្រឹត្តទៅជាទូទៅនៃជីវភាពប្រចាំថ្ងៃនៃសេវាអប់រំរបស់សាលា ដោយក្រុមស្វយ័តមួយ ទទួលបន្ទុកលើវេនពេលព្រឹក ហើយក្រុមស្វយ័តមួយទៀត ទទួលបន្ទុកលើវេនល្ងាច។ ក្រុមស្វយ័តនីមួយៗ ត្រូវបានរៀបចំបន្តជា ១០ ផ្នែក ដែលរួមមាន ÷

**រចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រងសាលាបឋមសិក្សាវត្តបូព៌**




## ❷.គុណតម្លៃរបស់សាលារៀន

● **វិញ្ញាណរបស់អ្នកដឹកនាំ** ១ មិន និង ៥ មាន គឺជាវិញ្ញាណនៃអ្នកដឹកនាំ (អ្នកដឹកនាំទាំងឡាយមិនត្រូវមានភាពអាត្មានិយម និងត្រូវប្រតិបត្តិនូវការដឹកនាំប្រកបដោយឆន្ទៈ មានភាពអត់ធ្មត់ មានការព្យាយាម មានភាពស្មោះត្រង់ និងមានការលះបង់)

● **លក្ខណៈសម្បត្តិរបស់អ្នកដឹកនាំ** អ្នកដឹកនាំ ត្រូវមានលក្ខណៈសម្បត្តិចំនួន ១០ គឺ ចំណេះដឹងពិត ឥរិយាបថថ្លៃថ្នូរ ស្មារតីលះបង់ ការសម្រេចចិត្តចំគោលដៅ សម្រេចផលមុនទទួលផលក្រោយ ធ្វើជាគំរូល្អ ភាពជាម្ចាស់ ស្មោះត្រង់ និងមិនពុករលួយកេងប្រវ័ញ្ច យុត្តិធម៌គ្មានការស្រឡាញ់ និងបង្កើតបរិយាកាសរីករាយ

● **គោលការណ៍ប្រចាំជីវិតរបស់អ្នកដឹកនាំ** អ្នកដឹកនាំ ត្រូវប្រកាន់ខ្ជាប់និងប្រតិបត្តិនូវគោលការណ៍ប្រចាំជីវិតចំនួន៨ គឺព្យាយាមរៀនជាប្រចាំ សម្រេចឆន្ទៈ ត្រូវមានគំនិតថ្មី ត្រូវច្នៃប្រឌិត សិក្សាបរិយាកាសសង្គម ធ្វើជាគំរូ ចាត់ទុកខ្លួនឯងជាមនុស្សមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ និងស្វែងរកកិច្ចសហការទាំងក្នុង និងក្រៅប្រទេស

● **លក្ខណសម្បត្តិនៃសេវាអប់រំ** អ្នកផ្តល់សេវាអប់រំ ជូនដល់អ្នកទទួលសេវា រួមមានសិស្សានុសិស្ស មាតាបិតា អាណាព្យាបាល និងសហគមន៍ ត្រូវមានលក្ខណសម្បត្តិចំនួន ៥ ប្រការ គឺផ្តល់ទំនុកចិត្តដល់អ្នកទទួលសេវា បំពេញភារកិច្ចអស់ពីសមត្ថភាព រក្សាសមធម៌ក្នុងការសិក្សា ចៀសវាងការកេងប្រវ័ញ្ច និងពុករលួយ និងប្រតិបត្តិក្រមសីលធម៌គ្រូបង្រៀន។

## ❸.ការគ្រប់គ្រងធនធានគ្រូបង្រៀន

ក្នុងឆ្នាំសិក្សា២០១៨-២០១៩ សាលាបឋមសិក្សាវត្តបូព៌ មានគ្រូបង្រៀនសរុបចំនួន ១៣០ នាក់ ក្នុងនោះមាន លោកគ្រូចំនួន ៣១ នាក់ និងអ្នកគ្រូចំនួន ៩៩ នាក់ ដែលត្រូវបង្រៀនសិស្សានុសិស្ស សរុបប្រមាណ ៦៥០០ នាក់។ នៅក្នុងការងារដឹកនាំ និងគ្រប់គ្រងធនធានគ្រូបង្រៀន ទាមទារចាំបាច់នូវគ្រូបង្រៀនមានសាមគ្គីភាព មានវិន័យ មានការជឿជាក់លើការដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលា។ ដូចនេះ នាយកសាលាបានប្រើប្រាស់យុទ្ធសាស្ត្រ ឬប្រើប្រាស់អំណាច ចំនួន ២ គឺ÷ ទី១. អំណាចរឹង សំដៅដល់អំណាចតួនាទី គឺ អំណាចជាសមត្ថកិច្ច ដែលថ្នាក់លើបានប្រគល់ឱ្យថ្នាក់ក្រោមទៅតាមវិធាន និងនីតិវិធីនៃច្បាប់ជាធរមាន និងទី២.អំណាចស្រទន់ សំដៅដល់សមត្ថភាពរបស់បុគ្គលផ្ទាល់ពោល គឺសមត្ថភាពចំណេះដឹង ឥរិយាបថ ភាពជាគំរូ ដែលអំណាចនេះ នាយកសាលាត្រូវមានជាមុន និងត្រូវធ្វើមុនគេ សម្រាប់ឱ្យអ្នកក្រោមឱវាទប្រតិបត្តិ និងយកគំរូតាម។

*សាលាបឋមសិក្សាវត្តបូព៌មានចក្ខុវិស័យមុតស្រួច និងច្បាស់លាស់គឺ “បណ្តុះគ្រាប់ពូជជាធនធានមនុស្ស កម្រិតបឋមសិក្សាប្រកបដោយគុណភាពខ្ពស់ មានឥរិយាបថថ្លៃថ្នូរ និងសុខុមាលភាពល្អប្រសើរ ដើម្បីចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិ ឱ្យមានការរីកចំរើនដូចបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក”*

## ❹.ការគ្រប់គ្រងធនធានគ្រូបង្រៀន

នៅក្នុងសាលាបឋមសិក្សាវត្តបូព៌ មានរបបប្រជុំចំនួន ៣ ប្រភេទ គឺ÷

● **កិច្ចប្រជុំបច្ចេកទេស** គឺជាកិច្ចប្រជុំពិនិត្យពិភាក្សាលើបញ្ហាប្រឈម និងស្វែង



*សកម្មភាពកិច្ចប្រជុំរវាងលោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលា នៅសាលាបឋមសិក្សាវត្តបូ*



ពិធីអបអរសាទរ ទិវាអប់រំកាយ និងកីឡាសិស្ស នៅសាលាបឋមសិក្សាវត្តបូព៌ិ

រកដំណោះស្រាយកែលម្អវិធីសាស្ត្រនៃការបង្រៀន, ការរៀបចំ និងអនុវត្តកម្មវិធីសិក្សា, ខ្លឹមសារមេរៀន និងការរៀនសូត្ររបស់សិស្សានុសិស្ស។

● **កិច្ចប្រជុំដើមសប្តាហ៍** គឺជាកិច្ចប្រជុំសាមញ្ញ រៀបចំឡើងដើម្បីពិនិត្យពិភាក្សាលើបញ្ហាប្រឈម និងស្វែងរកដំណោះស្រាយពាក់ព័ន្ធការបង្រៀននឹងការរៀនសូត្ររបស់សិស្ស ដែលបានប្រព្រឹត្តទៅរយៈពេល ១ សប្តាហ៍កន្លងទៅ។

● **កិច្ចប្រជុំវិសាមញ្ញ** ប្រព្រឹត្តទៅក្នុងករណីចាំបាច់ណាមួយដែលនាយកសាលាអាចកោះហៅសមាជិកចូលរួមកិច្ចប្រជុំជាបន្ទាន់បាន ដើម្បីពិនិត្យពិភាក្សាលើបញ្ហាប្រឈម និងដាក់ចេញនូវយន្តការដោះស្រាយបន្ទាន់ ជាយថាហេតុ។



ពិ

ចំពោះការរៀបចំផែនការថវិកា របស់សាលាបឋមសិក្សាវត្តបូព៌ិ គឺអនុលោមតាមវិធាន និងនីតិវិធីជាធរមាន នៃការរៀបចំថវិកាជាតិ ដូចសាលាផ្សេងៗផងដែរ ក្រោមការដឹកនាំ ចាត់ចែង និងសម្របសម្រួលរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានមន្ទីរអប់រំ យុវជន និងកីឡា ហើយនឹងការិយាល័យអប់រំ យុវជន និងកីឡា ខេត្តសៀមរាបជាសេនាធិការ។ ថវិកានៅក្នុងការគ្រប់គ្រងសាលាបឋមសិក្សាវត្តបូព៌ិមានប្រភពយ៉ាងតិចចំនួន ៣ សំខាន់ៗ គឺថវិកាជាតិ ថវិកាអំណោយ និងថវិកាចំណូលផ្ទាល់ពីការគ្រប់គ្រងសាលា។

## ខ. សិស្សានុសិស្ស

### ❶. ការអប់រំសមាសភាគទាំង ៥

សីលធម៌ល្អ លុះត្រាតែមានការអប់រំសមាសភាគទាំង ៥ គឺការអប់រំបញ្ញា ការអប់រំពលកម្ម ការអប់រំសោភ័ណ ការអប់រំសិល្បៈ និងការអប់រំកាយ និងកីឡា។ កាលណាសិស្សានុសិស្ស ប្រតិបត្តិបានខ្ជាប់ខ្ជួននូវការអប់រំសមាសភាគទាំង ៥ បានល្អប្រសើរនោះ នឹងទទួលបានសីលធម៌ល្អ និងមានសន្តិភាពទាំងផ្លូវកាយ ក្រៅផ្លូវកាយ ព្រមទាំងផ្លូវចិត្ត។

● **ការអប់រំបញ្ញា** បណ្តុះវិជ្ជាបណ្តាលឱ្យកើនបញ្ញា បណ្តុះយ៉ាងណា ឱ្យសិស្សានុសិស្សក្លាយជាមនុស្សល្អពិតប្រាកដ។ ការអប់រំបញ្ញា ផ្តោតសំខាន់លើមុខវិជ្ជាសំខាន់ៗ ចំនួន ៤ គឺ ផ្នែកភាសាខ្មែរ ផ្នែកគណិតវិទ្យា ផ្នែកសិក្សាសង្គម និងផ្នែកវិទ្យាសាស្ត្រ ដែលបានកំណត់ដោយកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។

● **ការអប់រំពលកម្ម** មិនសំដៅទៅលើការអប់រំដោយការប្រើប្រាស់កម្លាំងតែម្យ៉ាងនោះទេ ពោលគឺសំដៅលើការអប់រំបរិស្ថាន និងការអប់រំកសិកម្ម។ ការអប់រំបរិស្ថាន មាន ២ប្រភេទគឺ បរិស្ថានបុគ្គល (ការអប់រំបរិស្ថានធម្មជាតិ និងបរិស្ថានខ្លួនប្រាណ ដែលត្រូវគិតពីបរិស្ថានក្នុងសាលា រួមទាំងបុគ្គលខ្លួនឯងផ្ទាល់តែម្តង) និងបរិស្ថានសង្គម (បណ្តុះស្មារតីឱ្យចេះយកចិត្តទុកដាក់ និងមានកង្វល់ពីបញ្ហាបរិស្ថាននៅក្នុងសង្គមជាតិទាំងមូល)។ រីឯ ការអប់រំកសិកម្ម គឺជាការអប់រំមួយបែប ដែលបង្រៀនឱ្យសិស្សានុសិស្សចេះដាំដំណាំគ្រប់ប្រភេទ។

● **ការអប់រំសិល្បៈ** សំដៅទៅលើការអប់រំផ្នែកច្រៀង រាំរបាំ លេងតូរ្យតន្ត្រី គូររូប និពន្ធទំនុកច្រៀង និងសម្តែង ជាដើម ត្រូវបានបង្ហាត់ និងបង្រៀនផ្ទាល់ដោយលោកគ្រូ និងអ្នកគ្រូ នៃសាលាបឋមសិក្សាវត្តបូព៌ិ។

● **ការអប់រំកាយនិងកីឡា** ផ្តល់ឱកាសដល់សិស្សានុសិស្ស ក្នុងការអភិវឌ្ឍ និងអប់រំចំណេះដឹងផ្នែកសុខភាពរូបរាងកាយ អាកប្បកិរិយា និងរបៀបរស់នៅក្នុងសង្គម ជាដើម។ ការអប់រំកាយ និងកីឡា ចំពោះសិស្សានុសិស្ស មានដូចជា ការធ្វើអត្តពលកម្ម បាល់បោះ បាល់ទះ បាល់ទាត់ ការអប់រំកាយជាមួយចង្វាក់ភ្លេង និងកាយសម្ព័ន្ធ ជាដើម។

● **ការអប់រំសោភ័ណ** សុភាវធម៌ និងឥរិយាបថថ្លៃថ្នូរ គឺជាកញ្ចក់ឆ្លុះបញ្ចាំងនូវការគោរពវិន័យ របស់សាលាបឋមសិក្សាវត្តបូព៌ិ ដែលជាស្នូលគ្រឹះ នៃការអប់រំសោភ័ណ។ សិស្សានុសិស្ស នៃសាលាបឋម



*សកម្មភាពអប់រំកាយ និងកីឡា របស់សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ នៅសាលាបឋមសិក្សាវត្តបូព៌*

សិក្សាវត្តបូព៌ ត្រូវបានបង្រៀននិងអប់រំ ឱ្យមានសុភាវធម៌ល្អ ចេះគោរពចាស់ព្រឹទ្ធាចារ្យ និងប្រកាន់ខ្ជាប់នូវឥរិយាបថថ្លៃថ្នូរ ក្នុងការរស់នៅក្នុងសង្គម ទាំងការ “**ដេក ដើរ ឈរ អង្គុយ**” ដោយសិស្សានុសិស្ស ត្រូវប្រើប្រាស់ឥរិយាបថទាំងបួន នេះប្រកបដោយភាពសមរម្យ សុជីវធម៌ មិនឆ្គាំឆ្គង ដោយអំណរ និងមិនស្តាយក្រោយ។

**❷. សាសនា និងការអប់រំ**

ព្រះពុទ្ធសាសនា គឺជាសាសនាដែលទាក់ទងនឹងជីវិតរស់នៅរបស់មនុស្ស។ សាលាបឋមសិក្សាវត្តបូព៌ បានដាក់បញ្ចូលការអប់រំតាមបែបព្រះពុទ្ធសាសនា ទៅក្នុងកម្មវិធីអប់រំរបស់ខ្លួន។ ការបង្កើតកម្មវិធីអប់រំតាមបែបពុទ្ធសាសនានេះ គឺកើតចេញពីកិច្ចសហការរវាងសាលាបឋមសិក្សាវត្តបូព៌ និងវត្តរាជបូណ៌។ ជារៀងរាល់សប្តាហ៍ថ្ងៃព្រហស្បតិ៍ ព្រះសង្ឃនៃវត្តរាជបូព៌ តែងតែនិមន្តទៅបង្ហាត់បង្រៀនអប់រំដល់សិស្សានុសិស្ស ព្រមទាំងលោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលា ដោយផ្តោតសំខាន់លើសីល សមាធិ បញ្ញា ឬធម៌វិន័យ ពោលគឺការបង្រៀន ឱ្យលះបង់នូវទង្វើអាក្រក់ ការប្រព្រឹត្តនូវសេចក្តីល្អ និងការជម្រះចិត្តឱ្យស្អាត ។ ទន្ទឹមនេះ, សិស្សានុសិស្ស ក៏ត្រូវបានទទួលការអប់រំ នៃការប្រើប្រាស់សង្ឃសព្ទ នៃព្រះពុទ្ធសាសនា ការសូត្រធម៌ ការយល់ដឹងអំពីព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ផងដែរ។

**❸. គោលការណ៍ប្រតិបត្តិទាំង៥**

គោលការណ៍ប្រតិបត្តិទាំង ៥ គឺជាគោលការណ៍ “អំពើល្អមនុស្សសកល ៥ ប្រការ” ដែលអាចធ្វើឱ្យបុគ្គលមួយរូប ក្លាយជាមនុស្សម្នាក់ដែលមានវិន័យ និងសីលធម៌ខ្ពស់។ គោលការណ៍ប្រតិបត្តិទាំង ៥ ប្រការ រួមមាន÷**ទី១- ស្អាត÷** ស្អាតទាំងផ្លូវកាយ ក្រៅផ្លូវកាយ និងផ្លូវចិត្ត **ទី២-របៀប÷** ជាការរៀបចំខ្លួនឱ្យត្រឹមត្រូវ មានវិន័យ និងមានសណ្តាប់ធ្នាប់ ទាំងរបៀប ដេក ដើរ ឈរ អង្គុយ និងការស្លៀកពាក់ **ទី៣- សុភាព÷** គឺ“ សុភាពកាយ សុភាពវាចា និងសុភាពចិត្ត” **ទី៤-ទៀងពេល÷** ប្រកាន់គំនិត “ពេលវេលាជាមាសប្រាក់” **ទី៥- សមាធិ÷** គឺជាការអប់រំផ្លូវចិត្ត ការតម្កល់ចិត្តឱ្យនឹងនរ រៀនគិតនឹងរៀនធ្វើ ដើម្បីឆ្ពោះទៅកាន់សន្តិភាពផ្លូវចិត្ត។

**❹. មិត្តអប់រំមិត្ត**

បន្ទាប់ពីការគោរព និងច្រៀងចម្រៀងជាតិចប់ តំណាងសិស្សានុសិស្ស ១ រូប ឬ ២ រូប តែងតែឡើងផ្តល់មតិយោបល់អប់រំនានា ហៅថាកម្មវិធី “ដំណឹងជីវិត” ដើម្បីប្រាប់ទៅកាន់មិត្តភក្តិរបស់ខ្លួន តាមរយៈការបង្ហើរសំឡេងតាមមេក្រូ ដោយបន្លឺនូវពាក្យពេចន៍ប្រកបដោយការអប់រំ ពាក់ព័ន្ធសីលធម៌ក្នុងការរស់នៅ ទង្វើដែលមិនគួរប្រតិបត្តិ ចំណេះដឹងទូទៅផ្សេងៗ សំដៅបង្កើតបរិយាកាសមិត្តអប់រំមិត្ត។

**❺. ការត្រួតពិនិត្យវិន័យ**

គណៈគ្រប់គ្រងសាលា លោកគ្រូ និងអ្នកគ្រូ គឺជាតួអង្គសំខាន់ក្នុងការតាមដាន និងត្រួតពិនិត្យការគោរពវិន័យរបស់សិស្សានុសិស្ស។ ទន្ទឹមនេះ សាលាបឋមសិក្សាវត្តបូព៌ បានរៀបចំយន្តការបង្កើតក្រុមប្រឹក្សាកុមារ ដើម្បីបង្កើននិងធានាប្រសិទ្ធភាពនៃការគោរពវិន័យនៅក្នុងសាលារៀន។ ក្រុមប្រឹក្សាកុមារ មាន ២ កម្រិត គឺក្រុមប្រឹក្សាកុមារកម្រិតថ្នាក់ និងក្រុមប្រឹក្សាកុមារកម្រិតសាលារៀន។

**❻. ការលើកទឹកចិត្តសិស្សានុសិស្ស**

ការលើកទឹកចិត្តសិស្សានុសិស្ស នៃសាលាបឋមសិក្សាវត្តបូព៌ ត្រូវបានធ្វើឡើងក្រោមរូបភាពដូចជា ការលើកទឹកចិត្តសិស្សក្នុងការរៀនសូត្រ ការលើកទឹកចិត្តដល់សិស្សានុសិស្សដែលសម្រេចបានលទ្ធផលល្អក្នុងការសិក្សា និងការជួយសិស្សជួបការលំបាកជាដើម។

## គ. សហគមន៍

សាលាបឋមសិក្សាវត្តបូព៌ មានដំណើរការនៃការដឹកនាំ ក៏ដូចជាការអនុវត្តការងារទាំងឡាយ បានទទួលសមិទ្ធផលដូចពេលបច្ចុប្បន្ន គឺដោយមានការចូលរួមយ៉ាងសកម្ម ទាំងពីសហគមន៍ជាតិ និងសហគមន៍អន្តរជាតិ។

**❶. សហគមន៍ជាតិ**

ការចូលរួមគាំទ្រពីសហគមន៍ជាតិ ជាពិសេសពីសំណាក់រដ្ឋអំណាចភូមិឃុំ និងអង្គការមួយចំនួន គឺជាកត្តាគន្លឹះសំខាន់បំផុត ដែលធ្វើឱ្យសាលាបឋមសិក្សាវត្តបូព៌ ទទួលបានសមិទ្ធផលដូចសព្វថ្ងៃ ពិសេសលើការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានា។ ការចូលរួមគាំទ្រពីសហគមន៍ជាតិ មានជា



*សកម្មភាពបង្ហាត់បង្រៀន អប់រំតាមបែបព្រះពុទ្ធសាសនា ដល់លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលា នៅសាលាបឋមសិក្សាវត្តបូព៌*

អាទិ៍÷

-ការចូលជាសមាជិកសមាគមមាតាបិតាសិស្ស

-ការនិមន្តព្រះសង្ឃផ្សព្វផ្សាយតាមបែបព្រះពុទ្ធសាសនា

-ផ្តល់ជាថវិកាផ្ទាល់ខ្លួន ដើម្បីធ្វើការស្ថាបនាសាលារៀន

-ការឧបត្ថម្ភជាសម្ភារ ឬជាការបញ្ចុះតម្លៃពីក្រុមហ៊ុនឯកជនក្នុងស្រុក

-ចូលរួមចែករំលែកចំណេះដឹង ផ្សព្វផ្សាយ និងបញ្ជ្រាបនូវព័ត៌មានផ្សេងៗ ជូនសាលា រួមមានបុគ្គលិក និងសិស្សានុសិស្សផ្ទាល់

-ឧបត្ថម្ភដល់ជីវភាព សម្រាប់ការបង្រៀនរាល់ថ្ងៃព្រហស្បតិ៍។

ទន្ទឹមនេះ សាលាបឋមសិក្សាវត្តបូព៌ ក៏មានការរៀបចំកម្មវិធីជាក់លាក់នានា ក្នុងគោលដៅទាក់ទាញការគាំទ្រពីសហគមន៍ទាំងនេះ រួមមាន÷ កម្មវិធីជួបជុំមាតាបិតាសិស្ស កម្មវិធីបុណ្យផ្កាប្រាក់ ការគាំទ្រពីវត្តរាជបូណ៌ (ខេត្តសៀមរាប) និងការចូលរួមឧបត្ថម្ភចំពោះកិច្ចផ្សេងៗ។

### ❷. សហគមន៍អន្តរជាតិ

សាលាក៏មានកិច្ចសហការផ្ទាល់ពីអង្គការនានា នៅក្រៅប្រទេសផងដែររួមមានប្រទេស ថៃ ជប៉ុន កូរ៉េ និងតៃវ៉ាន់ ព្រមទាំងប្រទេសមួយចំនួនទៀតនៅសហគមន៍អឺរ៉ុប តាមរយៈ÷

-អ្នកស្ម័គ្រចិត្តមកជួយបណ្តុះបណ្តាលបន្ថែមផ្នែកសិល្បៈតន្ត្រី សុខភាព អនាម័យ បរិស្ថាន និងសុខុមាលភាព

-រៀបចំឱ្យមានទស្សនកិច្ចសិក្សានៅក្រៅប្រទេស

-រៀបចំឱ្យមានការបណ្តុះបណ្តាលបន្ថែមរយៈពេលខ្លីលើផ្នែកបច្ចេកវិទ្យាដល់បុគ្គលិក និងសិស្សានុសិស្ស

-បណ្តុះបណ្តាល លើការប្រគំតន្ត្រីដល់បុគ្គលិកនិងសិស្សានុសិស្ស

-ផ្តល់ជាសម្ភារសិក្សា សម្លៀកបំពាក់សិក្សា មធ្យោបាយធ្វើដំណើរ និងថវិកាខ្លះៗ ដល់សិស្សានុសិស្សដែលជួបការលំបាក ជាប្រចាំឆ្នាំសិក្សា

-ចូលរួមផ្តល់មតិយោបល់ខ្លះ និងចូលរួមជួយដោះស្រាយបញ្ហាផ្សេងៗ ដែលពាក់ព័ន្ធក្នុងការអភិវឌ្ឍសាលារៀន។

## ឃ. ទស្សនៈវិស័យ

### ❶. ភាពជាគំរូ

សាលាបឋមសិក្សា "វត្តបូព៌" គឺជាសាលាបឋមសិក្សាមួយ មានវិន័យល្អ និងគោរពគោលការណ៍ប្រយោជន៍រួមជាធំ ជាពិសេសគឺមានភាពច្នៃប្រឌិតខ្ពស់ ក្នុងប្រព័ន្ធអប់រំសិស្សានុសិស្ស ដែលធ្វើឱ្យអាណាព្យាបាលគោរពកោតសរសើរ អំពីឆន្ទៈ និងភាពជាម្ចាស់របស់គណៈគ្រប់គ្រងសាលា។ តាមរយៈនេះ ស្ថាប័នឯកជន និងស្ថាប័នរដ្ឋមួយចំនួន បានចុះមកធ្វើទស្សនកិច្ចសិក្សាឈ្វេងយល់អំពីប្រព័ន្ធគ្រប់គ្រងរបស់សាលាបឋមសិក្សានេះ ដើម្បីដកពិសោធន៍យកទៅអនុវត្តនៅសាលាបឋមសិក្សារបស់ខ្លួន។ ទន្ទឹមនេះ ស្ថាប័នក្រៅប្រទេស មួយចំនួនចាប់អារម្មណ៍អំពីវឌ្ឍនភាព និងភាពលេចធ្លោរបស់សាលាបឋមសិក្សានេះ ផងដែរ ដោយមានការចុះមកថតយកនូវសកម្មភាពនៃការអប់រំ ដើម្បីធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានសង្គម ដែលកិត្តិនាមនេះល្បីល្បាញរហូតដល់ប្រទេសមួយចំនួនចុះមកធ្វើទស្សនកិច្ចសិក្សាហើយឧបត្ថម្ភនូវថវិកា និងសម្ភារសិក្សាមួយចំនួនដើម្បីទ្រទ្រង់ដល់កិច្ចដំណើរការរបស់សាលា ។

*សាលាបឋមសិក្សាវត្តបូព៌ អាចចាត់ទុកជាសាលាគំរូនៃគុណធម៌ និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាគំរូអភិបាលកិច្ចដ៏ជោគជ័យមួយ។ គំរូអភិបាលកិច្ចនេះ នឹងត្រូវយកលំនាំយ៉ាងឆាប់រហ័ស ដោយបណ្តាសាលាផ្សេងៗទៀតនៅកម្ពុជា។*

### ❷. ការបន្តវេន

របៀបដឹកនាំ និងគ្រប់គ្រងរបស់អ្នកដឹកនាំស្ថាប័នមួយនេះ បង្កបាននូវប្រព័ន្ធប្រតិតុល្យការមួយ សម្រាប់កំណត់នូវលក្ខណសម្បត្តិរបស់អ្នកដឹកនាំបន្តវេនរបស់ខ្លួនរួចទៅហើយ តាមរយៈវត្តមានស្រាប់នៃភាពជាអ្នកដឹកនាំស្មារតី ឆន្ទៈ ទំនួលខុសត្រូវ និងទស្សនៈអភិវឌ្ឍខ្លួនឯងក្នុងស្រទាប់គ្រូបង្រៀន និងគណៈគ្រប់គ្រងគ្រប់ស្រទាប់របស់សាលាបឋមសិក្សាវត្តបូព៌។

សាលាបឋមសិក្សាវត្តបូព៌ អាចចាត់ទុកជាសាលាគំរូនៃគុណធម៌ និងត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថា ជាគំរូអភិបាលកិច្ចដ៏ជោគជ័យមួយ។ គំរូអភិបាលកិច្ចនេះនឹងត្រូវយកលំនាំយ៉ាងឆាប់រហ័សដោយបណ្តាសាលាផ្សេងៗទៀតនៅកម្ពុជា៕■

*រៀបចំដោយ÷ ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ អ.គ.ហ.*

# វឌ្ឍនភាពនៃការអនុវត្តគម្រោង FMIS ឆ្នាំ២០២០

*កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management Reform Program - PFMRP) ត្រូវបានដាក់ប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្នុងឆ្នាំ២០០៤ ដឹកនាំការអនុវត្តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបែងចែកជា៤ ដំណាក់កាល គឺដំណាក់កាលទី១ "ភាពជឿទុកចិត្តនៃថវិកា", ដំណាក់កាលទី២ "គណនេយ្យភាពហិរញ្ញវត្ថុ", ដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" និង ដំណាក់កាលទី៤ "គណនេយ្យភាពចំពោះសមិទ្ធកម្ម"។ ស្ថិតក្នុងដំណាក់កាលទី២ "គណនេយ្យភាពហិរញ្ញវត្ថុ" នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបានប្រកាស់ដាក់ឱ្យអនុវត្តជាផ្លូវការក្នុងឆ្នាំ២០១៤។*

គិតត្រឹមឆ្នាំ២០២០, ការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ នៅអគ្គនាយកដ្ឋានគន្លឹះ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, រតនាគាររាជធានី-ខេត្ត ទាំង ២៥, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ទាំង ២៥, និងគ្រប់ក្រសួង-ស្ថាប័នទាំង៣៧ រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលចំនួន២៤។ ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ២០២០-២០២៥ និងផែនការសកម្មភាពគ្រប់គ្រងការផ្លាស់ប្តូរ ទទួលបានការអនុម័តពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ ២០២០។ នៅក្នុងការអនុវត្តនីតិវិធីថ្មីនេះ ឯកសារជាក្រដាសស្នាមនានារួមមាន សំណុំឯកសារអាណត្តិបើកប្រាក់ និង ឯកសារយោងផ្សេងៗទៀត មិនត្រូវបានរៀបចំ ចុះហត្ថលេខា និងបញ្ជូនពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀតឡើយ នៅតាមអង្គភាពទាំងឡាយដែលប្រើប្រាស់ប្រព័ន្ធ FMIS ចាប់ពីដំណាក់កាលអង្គភាពថវិការហូតដល់ដំណាក់កាលអគ្គនាយកដ្ឋានរតនាគារជាតិ ដោយអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុង ភ្ជាប់ជាមួយនឹងការស្កេនឯកសារយោងពីអង្គភាពថវិកា ។ ការអនុវត្តនីតិវិធីតម្រង់ទិសថ្មីតាមប្រព័ន្ធ FMIS ទាំងស្រុងនេះ បានចូលរួមចំណែកដ៏ធំធេងក្នុងការកាត់បន្ថយចំណាយរដ្ឋបាល (មិនប្រើប្រាស់ក្រដាស និងឧបករណ៍សម្ភារការិយាល័យមួយចំនួន) ចំណេញពេលវេលា (មិនប្រើពេលរត់ឯកសារឆ្លងពីដំណាក់កាលមួយទៅមួយ) និងពង្រឹងតម្លាភាព (លំហូរនៃប្រតិបត្តិការចំណាយថវិកាបង្ហាញទាំងស្រុងនៅក្នុងប្រព័ន្ធ FMIS) ពង្រឹងគណនេយ្យភាព និងបង្កើនប្រសិទ្ធភាព រួមទាំងភាពស័ក្តិសិទ្ធិ នៃការអនុវត្តថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបានចូលរួមចំណែកក្នុងការអនុវត្តគោលការណ៍គម្លាតសង្គម ព្រមទាំងចូលរួមធ្វើឱ្យប្រទេសកម្ពុជាប្រែក្លាយទៅជារដ្ឋាភិបាលឌីជីថលក្នុងវិស័យហិរញ្ញវត្ថុសាធារណៈក្នុងបរិការណ៍បដិវត្តន៍ឧស្សាហកម្មទី៤.០ ផងដែរ ។

● *ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*




*(FMIS) ២០២០-២០២៥ នឹងអនុវត្តទៅលើនីតិវិធីអនុវត្តការងារចំនួន៤ ប្រភេទ÷*

*១. នីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងធានា*

*ចំណាយនិងទូទាត់ចំណាយថវិកា*

*២. នីតិវិធីអនុវត្តការងារលើការធ្វើចលនាឥណទានចំណាយថវិកា*

*៣. នីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងការកត់ត្រាចំណូលថវិកា*

*៤. នីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម។*

*● នីតិវិធីអនុវត្តការងារទាំង៤ ខាងលើនឹងត្រូវអនុវត្តជាដំណាក់កាល ដោយផ្អែកលើកម្រិតនៃហានិភ័យ ឬវេទយិតភាព ទាំង៣ កម្រិត÷កម្រិត១ ឬទាប, កម្រិត២ ឬមធ្យម, កម្រិត៣ ឬខ្ពស់ ។*




*-**កម្រិត១ ឬទាប÷** មុខសញ្ញាចំណាយដែលប្រគល់សិទ្ធិសម្រេច និងទទួលខុសត្រូវត្រឹមប្រធានស្ថាប័ន ឬមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង-ស្ថាប័ន ក្នុងនាមជាអភិបាលហិរញ្ញវត្ថុ។*




*-**កម្រិត២ ឬមធ្យម÷** មុខសញ្ញាចំណាយដែលបានប្រគល់សិទ្ធិសម្រេច និងទទួលខុសត្រូវត្រឹមប្រធាននាយកដ្ឋានហិរញ្ញកិច្ចនៃអគ្គ.ថវិកា កសហវ. ឬអគ្គនាយក នៃអគ្គ.ថវិកា កសហវ. ក្នុងនាមជាអភិបាលហិរញ្ញវត្ថុ។*

*-**កម្រិត៣ ឬខ្ពស់÷** មុខសញ្ញាចំណាយដែលបានប្រគល់សិទ្ធិសម្រេច និងទទួលខុសត្រូវដល់ ឯកឧត្តម អនុរដ្ឋលេខាធិការ ឬរដ្ឋលេខាធិការ នៃកសហវ. ឬឯកឧត្តមឧបនាយករដ្ឋមន្ត្រី កសហវ. ក្នុងនាមជាអភិបាលហិរញ្ញវត្ថុ។*

ជាវឌ្ឍនភាព, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នចំនួន៧[១] ត្រូវបានដាក់អនុវត្តនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS សម្រាប់ការបើកផ្តល់បៀវត្ស, ការចំណាយលើបន្ទុកបុគ្គលិកផ្សេងៗ ក្រៅពីបៀវត្សដែលមានគោលរបបកំណត់ច្បាស់លាស់ និងការចំណាយទូទាត់ត្រង់ ដែលមានហានិភ័យទាបផ្សេងទៀត ជាផ្លូវការ។ ជាមួយគ្នានេះ, ចំណាត់ថ្នាក់ថវិកាទាំង៧ រួមមាន÷ ចំណាត់ថ្នាក់សេដ្ឋកិច្ច, កម្មវិធី, រដ្ឋបាល, ប្រភពមូលនិធិ, ភូមិសាស្ត្រ, មុខងារ និងគម្រោង) ត្រូវបានដាក់ឱ្យអនុវត្តក្នុងប្រព័ន្ធ FMIS។ រាល់ទិន្នន័យតាមចំណាត់ថ្នាក់ថវិកាទាំង៧ ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ និងត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំទៅលើលេខកូដ ហើយនឹងសេចក្តីបរិយាយស្របតាមការកែសម្រួលពីអង្គភាពពាក់ព័ន្ធ។

លើសពីនេះ, ប្រព័ន្ធ FMIS ក៏បានធ្វើសន្ទានកម្មផ្លាស់ប្តូរទិន្នន័យជាមួយប្រព័ន្ធផ្សេងៗជាច្រើនទៀតដូចជា÷ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ និងប្រព័ន្ធអេឡិចត្រូនិកគយ (ASYCUDA) នៃអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា, ប្រព័ន្ធគ្រប់គ្រងបំណុលសាធារណៈ (DMFAS) នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល, ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) នៃអគ្គនាយកដ្ឋានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ដែលត្រូវបានដាក់ឱ្យដំណើរជាផ្លូវការនៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០២០ ។ សន្ទានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធ NRMIS គឺដើម្បីទាញបញ្ចូលទិន្នន័យ និងបង្កើតប្រតិបត្តិការដោយស្វ័យ

*[១] ក្រសួង-ស្ថាប័នទាំង ៧ រួមមាន÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងមុខងារសាធារណៈ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និងកីឡា*

ប្រវត្តិក្នុងប្រព័ន្ធ FMIS លើចំណូលថវិកាដែលបានពីការប្រមូលចំណូលមិនមែនសារពើពន្ធ និងបានកត់ត្រារួចរាល់ក្នុងប្រព័ន្ធ NRMIS ។ ក្នុងន័យនេះ ក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច-និងហិរញ្ញវត្ថុទាំងអស់ដែលកំពុងប្រើប្រាស់ប្រព័ន្ធ FMIS មិនតម្រូវឱ្យធ្វើការកត់ត្រាសលាកបត្របង់ចំណូលថវិកាតាមប្រព័ន្ធ NRMIS លើកលែងតែមានករណីដោយឡែក នៅមានសលាកបត្របង់ចំណូលថវិកាដែលរៀបចំខាងក្រៅប្រព័ន្ធ NRMIS គឺត្រូវនៅរក្សាចុះប្រតិបត្តិការចំណូលថវិកាតាមប្រព័ន្ធ FMIS ដដែល។ ព័ត៌មាននៃការបង់ចំណូលថវិកាទាំងអស់ ដែលក្រសួង-ស្ថាប័ន ឬអង្គភាពប្រមូលចំណូលមិនមែនសារពើពន្ធ ធ្វើការកត់ត្រានៅក្នុងប្រព័ន្ធ NRMIS នឹងត្រូវផ្ទេរចូលប្រព័ន្ធ FMIS ដោយស្វ័យប្រវត្តិតាមរយៈប្រព័ន្ធសន្ទាន-




*មុខងារស្នូលទាំង៦ (បញ្ជាទិញ, សៀវភៅធំ, គ្រប់គ្រងសាច់ប្រាក់, គណនេយ្យត្រូវសង, គណនេយ្យត្រូវទារ, និងវិភាជន៍ថវិកា) និងមុខងារពីរ បន្ថែមថ្មី (រៀបចំថវិកា និងលទ្ធកម្មពេញលេញ) នៅក្នុងប្រព័ន្ធ FMIS ។ ដោយឡែក មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងគ្រប់គ្រងសន្និធិ គ្រោងនឹងអភិវឌ្ឍនាពេលអនាគត។*

កម្ម។ សន្ទានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធធនាគាររបស់ធនាគារជាតិនៃកម្ពុជា ហើយនឹងធនាគារពាណិជ្ជដៃគូជាច្រើន, និងថ្មីៗនេះប្រព័ន្ធ FMIS បានធ្វើសន្ទានកម្មជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារដែលត្រូវបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០។ ប្រព័ន្ធទាំងពីរ បានធ្វើសន្ទានកម្មទៅលើមុខងារចំនួន២ គឺ÷

❶. ការបញ្ជូនទិន្នន័យចំណូលថវិកាចេញពីប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារទៅប្រព័ន្ធ FMIS ជំនួសឱ្យការចេញក្រដាសសលាកបត្របង់ប្រាក់ចូលថវិកាជាតិ និងថ្នាក់ក្រោមជាតិដែលពីមុនត្រូវការពេលវេលាយូរដោយការប្រើប្រាស់ក្រដាសស្នាម និងមាននីតិវិធីស្មុគស្មាញជាច្រើន។

❷. ការបញ្ជូនទិន្នន័យពន្ធដារ ដែលបានកាត់ទុកដោយអគ្គនាយដ្ឋានរតនាគារជាតិ និង រតនាគាររាជធានី-ខេត្តចេញពីប្រព័ន្ធ FMIS ទៅប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារដោយបែងចែកយ៉ាងលម្អិតច្បាស់លាស់តាមប្រភេទពន្ធ និងអាករនានា ។

ទន្ទឹមនឹងការប្រើប្រាស់នូវមុខងារស្នូលទាំង៦ នៅក្នុងប្រព័ន្ធ FMIS (មុខងារវិភាជន៍ថវិកា, មុខងារសៀវភៅធំ, មុខងារគណនីត្រូវសង, មុខងារគណនីត្រូវទារ, មុខងារការទិញ និងមុខងារគ្រប់គ្រងសាច់-ប្រាក់) ដែលត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការទៅកាន់អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធគន្លឹះ តាំងពីដំណាក់-កាលទី១ នៅក្នុងឆ្នាំ២០១៥, មុខងារថ្មីចំនួន២ បន្ថែមទៀតក៏កំពុងត្រូវបានរៀបចំដាក់ឱ្យអនុវត្ត គឺមុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញ។ ការអភិវឌ្ឍនូវមុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញ នៅក្នុងប្រព័ន្ធ FMIS សម្រេចបាននូវលទ្ធផលសំខាន់ៗមួយចំនួនរួមមាន÷ បានអភិវឌ្ឍ និងធ្វើតេស្តសាកល្បងរួចរាល់ដោយក្រុមការងារតំណាង នៃអគ្គនាយកដ្ឋាន និងអង្គភាព ដែលជាអ្នកប្រើប្រាស់ពាក់ព័ន្ធ។ ឧបករណ៍សម្រាប់អ្នកប្រើប្រាស់ និងបណ្តាញតភ្ជាប់ និងអគ្គិសនី សម្រាប់ការប្រើប្រាស់មុខងារទាំងពីរត្រូវបានរៀបចំ ហើយដាក់ដំឡើងរួចរាល់ នៅទីតាំងអ្នកប្រើប្រាស់នៅអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងអង្គភាពលទ្ធកម្ម នៃក្រសួងសេដ្ឋកិច្ចនិង-ហិរញ្ញវត្ថុ។ មុខងាររៀបចំផែនការថវិកាសម្រាប់ជំហានទី១a ត្រូវបានអភិវឌ្ឍរួច-រាល់ និងបានធ្វើតេស្តសាកល្បង ដោយកំពុងបន្តធ្វើការកែសម្រួលបន្ថែម។ ចំពោះមុខងារលទ្ធកម្មពេញលេញត្រូវបានរៀបចំព្រមទាំងធ្វើតេស្តសាកល្បងរួចរាល់លើផ្នែកគ្រប់គ្រងបញ្ជីអ្នកដេញថ្លៃ និងផ្នែកផែនការលទ្ធកម្ម។ បច្ចុប្បន្នកំពុងបន្តធ្វើការកែសម្រួលមួយចំនួនបន្ទាប់ពីធ្វើតេស្ត និងបន្តរៀបចំលើផ្នែកពីរបន្ទាប់ទៀតគឺ ផ្នែកគ្រប់គ្រងដំណើរការដេញថ្លៃព្រមទាំងការគ្រប់គ្រងកិច្ចសន្យា។ មុខងារទាំង២នេះនឹងត្រូវបញ្ចប់ការអភិវឌ្ឍនៅក្នុងប្រព័ន្ធ FMIS នៅក្នុងឆ្នាំ២០២០ ព្រមទាំងដាក់ឱ្យអនុវត្តសាកល្បងនៅឆ្នាំ២០២១ នៅកសហវ. និងក្រសួងស្ថាប័នចំនួន១ បន្ថែមទៀតគឺ




ក្រសួងព័ត៌មាន។

ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច (EFT) ដែលជាមុខងារមួយនៅក្នុងប្រព័ន្ធ FMIS ប្រើប្រាស់សម្រាប់ការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិចជូនក្រុមហ៊ុនផ្គត់ផ្គង់ និងក្រសួង-ស្ថាប័ន ដោយមិនតម្រូវឲ្យមានការបោះផ្សាយមូលប្បទានប័ត្រដោយអគ្គ-នាយកដ្ឋានរតនាគារជាតិឡើយ។ ការទូទាត់តាមប្រព័ន្ធ EFT នេះត្រូវបាន រាជរដ្ឋាភិបាលកម្ពុជាប្រកាសដាក់ឱ្យដំណើការកាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ ។ រហូតមកដល់ឆ្នាំ២០២០ នេះ, ការទូទាត់តាម EFT ត្រូវបានដាក់ឱ្យអនុវត្តនៅអគ្គនាយកដ្ឋានរតនាគារជាតិ សម្រាប់ការទូទាត់ពីប្រព័ន្ធ FMIS ទៅកាន់គណនីអ្នកទទួលផលនៅថ្នាក់កណ្តាល តាមរយៈធនាគារជាតិនៃកម្ពុជា និងធនាគារពាណិជ្ជជាដៃគូផ្សេងទៀត ហើយកំពុងពង្រីកវិសាលភាពនេះទៅថ្នាក់មូលដ្ឋាន (រតនាគាររាជធានី-ខេត្ត) ដែលគ្រោងដាក់ឱ្យដំណើរការនៅឆ្នាំ២០២១ ។

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS បានគូសបញ្ជាក់នៅក្នុងពិធីប្រកាសដាក់ឱ្យដំណើរការនូវសន្ទានកម្មរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងប្រព័ន្ធគ្រប់គ្រងទិន្នន័យពន្ធដារ កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០ ការធ្វើសន្ទានកម្មប្រព័ន្ធទាំងពីរនេះ គឺជាការសម្រេចបានដោយជោគជ័យនូវផែនការគន្លឹះមួយ នៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលដែលជាចក្ខុវិស័យដ៏មោះមុតរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ក្នុងការបង្កើនប្រសិទ្ធភាពដល់ការងារគ្រប់គ្រងការប្រមូលចំណូលថវិកាជាតិ, ការសន្សំសំចៃចំណាយថវិកាជាតិតាមរយៈការកាត់បន្ថយការប្រើប្រាស់ក្រដាស និងនីតិវិធីស្មុគស្មាញនានា, ចូលរួមបង្កើនផលិតភាពការងាររបស់មន្ត្រីពន្ធដារ និងរតនាគារ ហើយជាពិសេសគឺការផ្តល់ព័ត៌មានស្តីពីចំណូលថវិកាជាតិបានកាន់តែឆាប់រហ័ស។

ក្នុងអំឡុងពេលបំពេញបេសកម្មលើកទី៣ របស់ខ្លួន កាលពីថ្ងៃទី២៥ ខែមិថុនា ដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០២០ ទីប្រឹក្សាបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ លោក Holger van Eden ជំនាញការនៃមូលនិធិរូបិយវត្ថុអន្តរជាតិ បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលការងារនៃការអនុវត្តគម្រោង FMIS នៅកម្ពុជា ។ ជំនាញការបានកត់សម្គាល់ឃើញថា ក្រសួង-ស្ថាប័ន, រតនាគារ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត បានចូលរួមប្រើប្រាស់ប្រព័ន្ធ FMIS បានពេញលេញ។ ជំនាញការក៏បានរកឃើញថា របាយការណ៍ដែលផលិតចេញពី

*ផែនការតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២០២០-២០២៥ នឹងអនុវត្តទៅលើនីតិវិធីអនុវត្តការងារចំនួន៤ប្រភេទ÷ (១). នីតិវិធីអនុវត្តការងារលើការធ្វើចលនាឥណទានចំណាយថវិកា,(២). នីតិវិធីអនុវត្តការងារលើការធ្វើចលនាឥណទានចំណាយថវិកា, (៣). នីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងការកត់ត្រាចំណូលថវិកា, (៤). នីតិវិធីអនុវត្តការងារពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម*

ប្រព័ន្ធ FMIS មិនទាន់បានឆ្លើយតបទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់នៅតាមក្រសួង-ស្ថាប័ន, រតនាគារ និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្តនៅឡើយ ដោយសារអ្នកប្រើប្រាស់ខកខានមិនបានផ្តល់ព័ត៌មានអំពីតម្រូវការបានគ្រប់ជ្រុងជ្រោយ។ បន្ថែមពីនេះ, ជំនាញការ បានផ្តល់អនុសាសន៍ដល់លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS គួរសិក្សាអំពីតម្រូវការឱ្យបានលម្អិត និងពិនិត្យលទ្ធភាពអភិវឌ្ឍរបាយការណ៍បន្ថែម ដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់។ ជាមួយគ្នានេះផងដែរ អគ្គនាយកដ្ឋានពាក់ព័ន្ធ គួរតែពង្រីកការប្រើប្រាស់ចំណាត់ថ្នាក់រដ្ឋបាល នៃមាតិកាថវិកា ឱ្យបានលម្អិត ដើម្បីជាមូលដ្ឋានសម្រាប់ការត្រួតពិនិត្យ និងតាមដានការអនុវត្តថវិការបស់អង្គភាពថវិកា។ ដោយឡែកចំពោះការតម្រង់ទិសនីតិវិធីអនុវត្តការងារវិញ ជំនាញការបានកោតសរសើរលេខា-ធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS លើការតម្រង់ទិសនីតិវិធីអនុវត្តការងារប្រកបដោយយុទ្ធសាស្ត្រដែលមានការសិក្សា និងវិភាគគ្រប់ជ្រុងជ្រោយ គិតគូរទៅលើហានិភ័យនៃប្រតិបត្តិការ និងដាក់ឱ្យអនុវត្តជាជំហានៗ៕■

*រៀបចំដោយ÷ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍នៃ អ.គ.ហ. និងលេខា-ធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS*





# ផ្នែកទី ៣

# សុន្ទរកថា

# សុន្ទរកថារបស់ ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

*ថ្លែងក្នុងកម្មវិធីបើកសិក្ខាសាលាផ្សព្វផ្សាយសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយ រាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ។ ថ្ងៃពុធ ៨កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ នៅសណ្ឋាគារភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០។*

*- ឯកឧត្តម លោកជំទាវ ជាអភិបាល អភិបាលរង រាជធានី ខេត្ត*

*- លោក លោកស្រី ជានាយកទីចាត់ការហិរញ្ញវត្ថុសាលារាជធានី ខេត្ត និងប្រធានអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត*

*- លោក លោកស្រី ជាប្រធានមន្ទីរ ប្រធានរតនាគារ, តំណាងអគ្គនាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតំណាង អគ្គនាយដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ*

*- លោក លោកស្រី សមាជិកអង្គពិធីជាទីមេត្រី!*



ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីរីករាយយ៉ាងក្រៃលែង និងកិត្តិយស ដ៏ខ្ពង់ខ្ពស់ ដោយទទួលបានការអនុញ្ញាតពី ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យរៀបចំនិងថ្លែងសុន្ទរកថាបើកក្នុង «សិក្ខាសាលាផ្សព្វផ្សាយសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវា របស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាព ជំនាញរាជធានី ខេត្ត» ដែលប្រព្រឹត្តិទៅនាពេលរសៀលនេះ ដោយមានការចូលរួមដោយផ្ទាល់ពីរដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តព្រៃវែង រួមទាំងអង្គភាព និងមន្ទីរជំនាញពាក់ព័ន្ធ តាមរយៈប្រព័ន្ធវីឌីអូ (Video Conference) សម្រាប់រដ្ឋបាលខេត្តចំនួន២៣ ផ្សេងទៀត រួមនឹងអង្គភាព និងមន្ទីរជំនាញពាក់ព័ន្ធ ដោយមានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជួយសម្របសម្រួល។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍ចំពោះវត្តមានរបស់ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ដែលឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ និងការរួមគ្នាដោះស្រាយបញ្ហាប្រឈមនានា ដែលកើតមាននៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

សិក្ខាសាលានារសៀលនេះ មានគោលបំណងមិនត្រឹមតែដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តអនុក្រឹត្យលេខ ២៥អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវា របស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត នោះទេ, តែថែមទាំងដោះស្រាយបាននូវបញ្ហាដែលកំពុងប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការ



បែងចែកប្រាក់រង្វាន់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

ថ្វីត្បិតតែអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវា របស់អង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត ដោយរំពឹងថានឹងអាចដោះស្រាយបញ្ហាប្រឈមនេះបានក៏ដោយ, ប៉ុន្តែរហូតមកដល់ចុងត្រីមាសទី២ ឆ្នាំ២០២០, បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងការបែងចែកប្រាក់រង្វាន់ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅតែបន្តកើតមាន; ថវិកាមួយចំនួនធំ នៅតាមរដ្ឋបាលរាជធានី-ខេត្ត នៅមិនទាន់បានបង់ចូលគណនីប្រាក់បញ្ញើរបស់រដ្ឋបាលរាជធានី ខេត្ត នៅរតនាគាររាជធានី ខេត្ត នៅឡើយ, ដោយមូលហេតុមិនទាន់មានសារាចរណែនាំ ដែលចែងអំពីនីតិវិធីលម្អិតនៃការបែងចែក និងការបង់ចំណូល ព្រមទាំងការកត់ត្រាកិច្ចបញ្ជិកាគណនេយ្យ ។ ក្នុងស្មារតីនេះ ដោយប្រតិបត្តិតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ខ្ញុំបានចាត់ ឯកឧត្តម **យ៉េត វីណោល** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្របសម្រួលកិច្ចប្រជុំកម្រិតបច្ចេកទេសចំនួន៥ លើក ជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ ដើម្បីជំរុញការរៀបចំសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលបាននៅមន្ទីរអង្គភាពជំនាញរាជធានី-ខេត្ត។ ជាលទ្ធផល សារាចរនេះ ត្រូវបានទទួលការអនុម័តដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច-













និងហិរញ្ញវត្ថុ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ដែលមានអានុភាពអនុវត្ត ចាប់ពីខែមករា ឆ្នាំ២០២០។ ខ្លឹមសារនៃសារាចរនេះ ត្រូវបានបែងចែងលម្អិតទៅតាម ៩ ចំណុចដូចតទៅ ៖

1. *ចំណូលកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត*
2. *ចំណូលកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ដែលប្រមូលនៅមន្ទីរអង្គភាព ជំនាញរាជធានី ខេត្ត*
3. *ការគ្រោងចំណូលថវិកាពីកម្រៃសេវា,*
4. *ការគ្រោងឥណទានចំណាយថវិកានៃចំណូល ដែលប្រមូលបាននៅអង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត និងមន្ទីរ អង្គភាពជំនាញរាជធានី-ខេត្ត*
5. *ការដកប្រាក់រង្វាន់*
6. *ការបង់ចំណូលថវិកា*
7. *ការប្រើប្រាស់ និងការរៀបចំគម្រោងតម្រូវការបង្កាន់ដៃបង់ប្រាក់*
8. *វិធានការផ្ទេរចំណូលថវិកា ដែលមន្ទីរ អង្គភាពជំនាញរាជធានី-ខេត្ត បានបង់ចូលជាចំណូលថវិកាថ្នាក់ជាតិមុនមានសារាចរនេះ*
9. *កិច្ចបញ្ជិកាគណនេយ្យទាក់ទងចំណូលដែលជាគុណប្រយោជន៍ ដល់ថវិកា*

របស់រដ្ឋបាលរាជធានី-ខេត្ត។ ចំណូលពីសេវា ដែលប្រមូលបាននៅអង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត និងប្រមូលនៅមន្ទីរអង្គភាពជំនាញរាជធានី-ខេត្ត ។

### *ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

ក្នុងឱកាសដ៏មានសារៈសំខាន់នេះ ខ្ញុំសូមលើកទឹកចិត្ត និងសូមសំណូមពរដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាយកចិត្តទុកដាក់, ពិភាក្សា, និងចោទ-សួរ ទៅកាន់វាគ្មិនរបស់យើង រួមមាន ៖ តំណាងមកពី អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារ-ពើពន្ធ និងអគ្គនាយកដ្ឋានរតនាគារជាតិ ដែលជាអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតំណាងមកពីអគ្គនាយដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ, ក្នុងសិក្ខាសាលាផ្សព្វផ្សាយនេះ ដោយផ្តោតលើចំណុចគន្លឹះៗ ដូចតទៅ៖

**ទី១.** ការគ្រោងចំណូលថវិកាពីកម្រៃសេវារបស់អង្គភាពច្រកចេញ-ចូលតែមួយរាជធានី-ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី-ខេត្ត

**ទី២.** ការគ្រោងឥណទានចំណាយថវិកានៃចំណូលដែលប្រមូលបាននៅអង្គភាពច្រកចេញ-ចូលតែមួយរាជធានី-ខេត្ត និងមន្ទីរ អង្គភាពជំនាញរាជធានី-ខេត្ត

**ទី៣.** ការដកប្រាក់រង្វាន់ និងការបង់ចំណូលថវិកា

**ទី៤.** កិច្ចបញ្ជិកាគណនេយ្យទាក់ទងចំណូល



ដែលជាគុណប្រយោជន៍ ដល់ថវិការបស់រដ្ឋបាលរាជធានី-ខេត្ត (ចំណូលពីសេវា ដែលប្រមូលបាននៅអង្គភាពច្រកចេញចូលតែមួយរាជធានី-ខេត្ត និងប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី-ខេត្ត) ហើយជាពិសេសបញ្ហាប្រឈមជាក់ស្តែងនានា ដែលកំពុងកើតមានពាក់ព័ន្ធនឹងការ គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

ទន្ទឹមនេះ បន្ទាប់ពីបញ្ចប់សិក្ខាសាលាផ្សព្វផ្សាយនាថ្ងៃនេះ, ខ្ញុំសូមលើកទឹកចិត្តឯកឧត្តម លោកជំទាវ លោក លោកស្រី គិតគូរទៅលើ ៤ ចំណុចដូចខាងក្រោម÷

❶. ដោយអានុភាពគតិយុត្តនៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងចំណូលសេវារបស់អង្គភាពច្រកចេញចូលតែមួយ រាជធានី-ខេត្ត មានបច្ច័យដល់ការបែងចែកប្រាក់រង្វាន់ពីកម្រៃសេវានានាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, អគ្គនាយដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ សហការជាមួយអង្គភាពពាក់ព័ន្ធ គួរពិនិត្យមើលឡើងវិញអំពីប្រកាសរួម ឬប្រកាសអន្តរក្រសួង ស្តីពីការផ្តល់ថវិការង្វាន់លើការគ្រប់គ្រង និងការប្រមូលចំណូលកម្រៃសេវារបស់ក្រសួង-ស្ថាប័ន។

❷. អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ សហការជាមួយអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ និងអង្គភាពពាក់ព័ន្ធផ្សេងទៀត ពិនិត្យលើការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ថាតើគួរប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ របស់មន្ទីរជំនាញប្រមូលចំណូល ឬបង្កាន់ដៃបង់ប្រាក់របស់អង្គភាពច្រកចេញចូលតែមួយ។

❸. មន្ទីរជំនាញប្រមូលចំណូលមួយចំនួនមានភាពយឺតយ៉ាវក្នុងការរៀបចំសាលាកបត្របង់ចំណូលទូទាត់ប្រាក់រង្វាន់ ជាឯកសារផ្លូវការ ដែលបញ្ហានេះត្រូវបានលើកច្រើនសារួចមកហើយ ដោយអាជ្ញាធរសវនកម្មជាតិ ។ ដូចនេះ អង្គភាពពាក់ព័ន្ធគួរពង្រឹងយន្តការរៀបចំសាលាកបត្របង់ចំណូលជាឯកសារផ្លូវការ ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យបានទាន់ពេលវេលា ។



❹. ខ្ញុំយល់ថាសិក្ខាសាលាផ្សព្វផ្សាយថ្ងៃនេះមានរយៈពេលខ្លី ដូចនេះ ខ្ញុំសូមលើកទឹកចិត្តដល់រដ្ឋបាលរាជធានី ខេត្ត បន្តរៀបចំសិក្ខាសាលាផ្សព្វផ្សាយបន្តតាមបណ្តារដ្ឋបាលរាជធានី-ខេត្តសាមី ដើម្បីឱ្យការអនុវត្តសារាចរលេខ ០០៦ សហវ នេះ ឱ្យកាន់តែមានប្រសិទ្ធភាព ។

### *ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

មុននឹងបញ្ចប់, ខ្ញុំសូមយកឱកាសនេះវាយតម្លៃខ្ពស់ចំពោះកិច្ចសហការល្អរវាងអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ ក្នុងការរៀបចំសារាចរលេខ ០០៦ សហវ នេះឡើង សំដៅដោះស្រាយឱ្យបាននូវបញ្ហាដែលកំពុងប្រឈមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តម, លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងលោក លោកស្រី ជាអភិបាលរង, នាយកទីចាត់ការហិរញ្ញវត្ថុ, ប្រធានអង្គភាពច្រកចេញចូលតែមួយ, ប្រធានមន្ទីរ, និងប្រធានរតនាគារ ឆ្លៀតពេលដ៏មានតម្លៃចូលរួមសិក្ខាសាលាដ៏មានសារៈសំខាន់ថ្ងៃនេះ ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** សូមបានប្រកបដោយសុខភាពល្អបរិបូណ៌, កម្លាំងពលំមាំមួន និងសម្រេចបានជោគជ័យដ៏ត្រចះត្រចង់គ្រប់ភារកិច្ច។ ខ្ញុំសូមប្រកាសបើក «សិក្ខាសាលាផ្សព្វផ្សាយសារាចរស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី-ខេត្ត» ចាប់ពីពេលនេះតទៅ ៕■





## ផ្នែកទី ៤

# ទស្សនៈ និងមតិ



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ថ្លែងក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ
សាធារណៈ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២០ តាមរយៈប្រព័ន្ធ
វីដេអូ (Video Conference) នៅថ្ងៃទី៣០ ខែវិច្ឆិកា
ឆ្នាំ២០២០

*“ ឥឡូវនេះ, សភាពការណ៍កូវីដ-១៩ ចង្អុលអំពីភាពចាំបាច់ក្នុងការសម្របខ្លួន ទៅនឹងប្រក្រតីភាពថ្មី ដែលយើងក៏ត្រូវគិតគូរផងដែរ ពាក់ព័ន្ធទៅនឹងប្រព័ន្ធក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយយើងក៏ត្រូវការពេលខ្លះទៀត ដើម្បីសិក្សារៀនសូត្រ ពីបទពិសោធនៃការឆ្លងកាត់វិបត្តិមួយនេះ ដែលជាវិបត្តិធំ ហើយក៏ត្រូវការឱ្យយើងរៀនសូត្រ ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងវិបត្តិរបៀបនេះ ដែលអាចកើតឡើងនាពេលខាងមុខ ។ ”*



ប្រសាសន៍របស់ ឯកឧត្តម **ខឹ តាឃី**
រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធាន ក្រុមប្រឹក្សាជាតិគណនេយ្យ ថ្លែងក្នុង
ឱកាសកម្មវិធីដាក់ឱ្យដំណើរការជាផ្លូវការកម្មវិធីសិក្សា
គណនេយ្យជំនាញកម្ពុជា នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១

*“ ខ្ញុំមានកិត្តិយស ក្នុងការដឹកនាំការងាររៀបចំស្តង់ដារគណនេយ្យសាធារណៈ ហើយរាជរដ្ឋាភិបាលកំពុងធ្វើការកែសម្រួល ជាពិសេសការកែទម្រង់របាយការណ៍ហិរញ្ញវត្ថុ។ នៅថ្ងៃក្រោយ យើងអាចមើលរបាយការណ៍ហិរញ្ញវត្ថុរបស់ថវិកាជាតិកាន់តែងាយយល់ដូចគ្នានឹងរបាយការណ៍របស់ក្រុមហ៊ុនដែរ ពីព្រោះរបៀបរបបពន្យល់ងាយយល់ ។ ”*



ប្រសាសន៍ ឯកឧត្តមបណ្ឌិត **ជុំ គឹមឡេង** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្លែងក្នុងពិធីបើកសិក្ខាសាលាស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក នៅខេត្តសៀមរាប

*“ ការងារជាបន្ទាន់ និងចាំបាច់មួយចំនួនទៀត ដែលរាជរដ្ឋាភិបាល ត្រូវខិតខំសម្រេចឱ្យបាននាពេលខាងមុខ ដែលរួមមាន÷ការបណ្ដុះបណ្ដាលមន្ត្រី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសមន្ត្រីរបស់រដ្ឋបាលក្រុង ស្រុក ការពិនិត្យមើលនូវមុខងារចាំបាច់មួយចំនួន ដែលថ្នាក់ជាតិត្រូវផ្ទេរជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងការស្វែងរកប្រភពចំណូលសមស្របជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ”*

EUROPEAN UNION

មតិរបស់ដៃគូអភិវឌ្ឍន៍ លើរបាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២០

*“ ដៃគូអភិវឌ្ឍន៍សូមវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានសម្រេចនូវវឌ្ឍនភាពល្អប្រសើរនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងឆ្នាំ២០២០កន្លងទៅ ទោះបីជាស្ថិតក្នុងវិបត្តិនៃជំងឺរាតត្បាតកូវីដ-១៩ក៏ដោយ។ ក្រុមការងារបច្ចេកទេសដៃគូអភិវឌ្ឍន៍ បន្តផ្ដល់កិច្ចសហការ និងគាំទ្រសម្រាប់ការសម្រេចក្នុងការពន្យារពេលអនុវត្តដំណាក់កាលទី៣នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកិច្ចការ ទាំងនេះនឹងបន្តជំរុញឱ្យការកសាងនូវមូលដ្ឋានដ៏រឹងមាំដើម្បីធានានូវភាពជោគជ័យនៃការអនុវត្តក្នុងជំហានបន្ទាប់។ ”*

# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
# ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## គណៈគ្រប់គ្រង ៖

| | |
|---|---|
| រស់ សីលវ៉ា | អគ្គលេខាធិការ អ.គ.ហ. |
| បណ្ឌិត ហ៊ែល ចំរើន | អគ្គលេខាធិការរង អ.គ.ហ. |
| មាស សុខសេនសាន | អគ្គលេខាធិការរង អ.គ.ហ. |
| ប៉ែន ធីរុង្គ | អគ្គលេខាធិការរង អ.គ.ហ. |
| យ៉េត វីណែល | អគ្គលេខាធិការរង អ.គ.ហ. |
| ប៊ូ វង្សសុខា | អគ្គលេខាធិការរង អ.គ.ហ. |
| អ៊ុង លុយណា | អគ្គលេខាធិការរង អ.គ.ហ. |

## រៀបចំអត្ថបទដោយ ៖

ផ្នែកការងារកែទម្រង់ទាំង៣, គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ

| | |
|---|---|
| លី វ៉ុង | មន្ត្រីជំនាញជាន់ខ្ពស់ |
| រ៉ុទ្ធី សុត្រា | មន្ត្រីជំនាញ |
| ស៊ុន គឹមហេង | មន្ត្រីជំនាញ |

ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| គង់ ឆោមកែវវលក្ខណ៍ | មន្ត្រីជំនាញ |
| ស្រុន រដ្ឋា | មន្ត្រីជំនាញ |

ផ្នែកអនុវត្តថវិកា

| | |
|---|---|
| ប៉ុម លៃហេង | មន្ត្រីជំនាញជាន់ខ្ពស់ |
| ហៀង សូយ៉ារ៉ូ | មន្ត្រីជំនាញជាន់ខ្ពស់ |
| លឹម សុខហេង | មន្ត្រីជំនាញ |

ផ្នែកចំណូលសារពើពន្ធ

| | |
|---|---|
| អ៊ុង មករា | មន្ត្រីជំនាញជាន់ខ្ពស់ |
| រស់ ដាលីន | មន្ត្រីជំនាញ |

ផ្នែកគោលនយោបាយ និងរៀបចំថវិកា

| | |
|---|---|
| ម៉េត រ៉ាម៉ន | មន្ត្រីជំនាញ |
| ផេង សុខម៉ៃ | មន្ត្រីជំនាញ |

ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ

| | |
|---|---|
| អ៊ុំ យុទ្ធី | ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ ត្រួតពិនិត្យតាមដាន និងវាយតម្លៃ |
| អ៊ូច សោភ័ណ | មន្ត្រីជំនាញជាន់ខ្ពស់ត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| យន ម៉ាលីមឆេង | មន្ត្រីជំនាញជាន់ខ្ពស់ថវិកា |
| ឈុន ម៉ារឌី | មន្ត្រីជំនាញត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| ជា សុខផេង | មន្ត្រីជំនាញត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| អ៊ុង វលក្ខទេវី | ជំនួយការមន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |
| ឡេង ចាន់ភ្លួង | ជំនួយការមន្ត្រីត្រួតពិនិត្យតាមដាន និងវាយតម្លៃគម្រោង |

ការចូលរួមផ្សេងៗ៖

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានពន្ធដារ

ក្រុមការងារកែទម្រង់នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## នវានុវត្ត និងកែសម្រួលដោយ ៖

ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

| | |
|---|---|
| សុគន្ធ ចរិយា | មន្ត្រីជំនាញជាន់ខ្ពស់ |
| គង់ ឆោមកែវវលក្ខណ៍ | មន្ត្រីជំនាញ |
| ស្រុន រដ្ឋា | មន្ត្រីជំនាញ |

អាសយដ្ឋានទំនាក់ទំនង÷
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ:(៨៥៥) ៨៥ ៧៧៧ ៩២០
admin@pfm.gov.kh
www.pfm.gov.kh
www.facebook.com/gscpfm